របាយការណ៍
ស្តីពី
លទ្ធផលការងារវប្បធម៌ និងវិចិត្រសិល្បៈ ឆ្នាំ២០១៣

I.**សេចក្តីផ្តើម ៖**

អនុវត្តតាមកម្មវិធីនយោបាយ **យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២** របស់រាជរដ្ឋាភិបាល និងផែនការសកម្មភាពការងារវប្បធម៌ និងវិចិត្រសិល្បៈ ឆ្នាំ២០១៣ រយៈពេលមួយឆ្នាំនេះ គ្រប់អង្គភាពចំណុះក្រសួងបានខិតខំប្រឹងប្រែងបង្កើនកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍជាតិ-អន្តរជាតិ ជាពិសេសវិស័យឯកជនតាមគោលការណ៍របស់រាជរដ្ឋាភិបាលគឺ **រដ្ឋគាំទ្រ ដៃគូឯកជនជាអ្នកអនុវត្ត** ស្របតាម គោលនយោបាយ " **អភិរក្ស និងអភិវឌ្ឍវប្បធម៌ជាតិ** " ក្នុងគោលបំណងធ្វើឱ្យ " **វប្បធម៌ ក្លាយជាសេដ្ឋកិច្ចជាតិ** " ដោយជម្រុញបន្ថែមនូវការប្រើប្រាស់សក្តានុពលវប្បធម៌ជាតិជាថាមពលអភិវឌ្ឍសេដ្ឋកិច្ច តាមរយៈការពង្រឹង ការបង្កបង្កើនផលិតផលឧស្សាហកម្មវប្បធម៌ សម្រាប់គោលដៅពាណិជ្ជកម្ម និងទេសចរណ៍ ដោយបង្កើត ការងារ ពង្រឹងសីលធម៌សង្គម និងរបៀបរស់នៅថ្លៃថ្នូរ ធ្វើឱ្យខ្មែរមានគំនិតបង្កបង្កើត និងបង្កើននិន្នាការស្នេហាវប្បធម៌ជាតិ រួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ធ្វើឱ្យសង្គមទទួលបាននូវសុខដុមរមនា ដើម្បីឈានទៅសម្រេចគោលដៅ "**កម្ពុជា ៖ ព្រះរាជាណាចក្រនៃវប្បធម៌**" ។

II. **រចនាសម្ព័ន្ធ និងក្របខណ្ឌ ៖**

១.រចនាសម្ព័ន្ធ ៖

ក-ថ្នាក់ដឹកនាំក្រសួង ៖

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈដឹកនាំដោយ **រដ្ឋមន្ត្រី១រូប** អមដោយ**រដ្ឋលេខាធិការ៧រូប** និង**អនុរដ្ឋលេខា ធិការ៧រូប**។

ខ-ថ្នាក់រដ្ឋបាលកណ្តាល ៖

ថ្នាក់រដ្ឋបាលកណ្តាល ក្រសួងមាន ៖

-អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មាននាយកដ្ឋានចំនួន០៩ (នា.រដ្ឋបាល នា.បុគ្គលិក នា.ផែនការ ស្ថិតិ និងសរុប នា.គណនេយ្យ និងហិរញ្ញវត្ថុ នា.សំភារៈ និងបរិក្ខារ នា.នីតិកម្ម នា.សិទ្ធិអ្នកនិពន្ធ និងសិទ្ធិ ប្រហាក់ប្រហែល នា.សហប្រតិបត្តិការវប្បធម៌អន្តរជាតិ និងកិច្ចការអាស៊ាន សាលាបណ្តុះបណ្តាលក្របខណ្ឌ វប្បធម៌) ។

-អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ មាននាយកដ្ឋានចំនួន០៥ (នា.អភិវឌ្ឍវប្បធម៌ នា.សៀវភៅ ការអាន នា.សិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌ នា.សិល្បៈទស្សនីយភាព នា.សិល្បៈសូនរូប និងសិល្បៈសិប្បកម្ម) ។

-អគ្គនាយកដ្ឋានបេតិកភណ្ឌ មាននាយកដ្ឋានចំនួន០៤ (នា.បុរាណវត្ថុ នា.សារមន្ទីរ នា.បុរាណវិទ្យា និងបុរេប្រវត្តិវិទ្យា នា.គាំពារ និងអភិរក្សសំណង់បុរាណ) ។

ក្រៅពីនេះនៅមានអង្គភាពចំនួន ០៤ទៀត ដែលស្ថិតនៅក្រោមការដឹកនាំផ្ទាល់របស់រដ្ឋមន្ត្រី ៖

-សកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈដែលជាគ្រឹះស្ថានសាធារណៈ ថ្នាក់ស្មើអគ្គនាយកដ្ឋាន មានមហាវិទ្យាល័យចំនួន០៥ (មហា.បុរាណវិទ្យា មហា.ស្ថាបត្យកម្ម និងនគរូបនីយវិទ្យា មហា.សិល្បៈសូនរូប មហា.តូរ្យតន្ត្រី មហា.នាដសាស្ត្រ) និង មជ្ឈមណ្ឌលសិក្សាស្រាវជ្រាវវប្បធម៌វិទ្យាសាស្ត្រ១ ។

-នាយកដ្ឋានសវនកម្មផ្ទៃក្នុង

-អធិការដ្ឋាន ថ្នាក់ស្មើនាយកដ្ឋាន

-សាលាមធ្យមវិចិត្រសិល្បៈ ថ្នាក់ស្មើនាយកដ្ឋាន មានសាលាជំនាញចំនួន០៥ (សាលារបាំ សាលាសៀក សាលាសិល្បៈសូនរូប សាលាតូរ្យតន្ត្រី សាលាល្ខោន) ។

គ-ថ្នាក់រាជធានី-ខេត្ត ៖

ក្រសួងមានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី-ខេត្តចំនួន២៤ និង ការិយាល័យវប្បធម៌ និងវិចិត្រសិល្បៈក្រុង ខណ្ឌ ស្រុក ចំនួន១៦៦ការិយាល័យ ។

២.ក្របខណ្ឌមន្ត្រីរាជការ ៖

ក្រសួងមានមន្ត្រីរាជការសរុបចំនួន**២.៤៩២នាក់** ក្នុងនោះស្រី**៨៣៤នាក់** ចែកចេញជា ៖

-ថ្នាក់រដ្ឋបាលកណ្តាល មានចំនួន**១.៥៦១នាក់** ក្នុងនោះស្រី**៥៥៤នាក់**

-ថ្នាក់មន្ទីរវប្បធម៌រាជធានី-ខេត្ត មានចំនួន**១.០៣១នាក់** ក្នុងនោះស្រី**២៨០នាក់** ។

III. **សកម្មភាពការងារថ្នាក់ដឹកនាំក្រសួង ៖**

-ឯកឧត្តមរដ្ឋមន្ត្រី ថ្នាក់ដឹកនាំ និងមន្ត្រីជាន់ខ្ពស់ក្រសួង បានចូលរួមព្រះរាជពិធីរំកិល និងថ្វាយព្រះភ្លើង ព្រះបរមសព ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ "ព្រះបរមរតនកោដ្ឋ" និងព្រះរាជពិធីដង្ហែព្រះគង្គារ និងដង្ហែព្រះកោដ្ឋព្រះបរមរតនកោដ្ឋ

-ថ្នាក់ដឹកនាំក្រសួងបានទទួលជួបពិភាក្សាការងារក្នុងកិច្ចអភិរក្ស អភិវឌ្ឍវិស័យវប្បធម៌ និង អភិវឌ្ឍធនធានមនុស្សជាមួយតំណាងស្ថានទូត ភ្ញៀវជាតិ-អន្តរជាតិ អង្គការសមាគម ចូលរួមសិក្ខាសាលា ប្រជុំនៅក្រៅក្រសួង ចូលរួមអមដំណើរ **សម្តេចតេជោនាយករដ្ឋមន្ត្រី** និងចូលរួមជាកិត្តិយសក្នុងសកម្មភាពព្រឹត្តិការណ៍ ជាតិ-អន្តរជាតិសរុបមានចំនួន៤៩លើក។

IV. **លទ្ធផលការងារ ៖**

១.ការងារបម្រើព្រឹត្តិការណ៍សំខាន់ៗ ៖

-នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០១៣ វេលាម៉ោង៨:០០នាទី នៅទីស្តីការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈបានរៀបចំបើកសន្និបាតបូកសរុបការងារវប្បធម៌ និងវិចិត្រសិល្បៈឆ្នាំ២០១២ និងលើកផែនការសកម្មភាពការងារឆ្នាំ២០១៣ ក្រោមអធិបតីភាព **ឯកឧត្តមរដ្ឋមន្ត្រី** ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អញ្ជើញចូលរួមមាន ថ្នាក់ដឹកនាំក្រសួង ប្រធាន អនុប្រធាននាយកដ្ឋាន ប្រធាន អនុប្រធានមន្ទីរាជធានី-ខេត្ត សកលវិទ្យាធិការ សកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោកនាយក-នាយករងសាលា

មធ្យមវិចិត្រសិល្បៈ សរុប ចំនួន២៥០នាក់។ នៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៣ វេលាម៉ោង ១៤:០០នាទី នៅសាលសន្និសីទចតុមុខ បានប្រារព្ធពិធីបិទអង្គសន្និបាតក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **លោកជំទាវ ម៉ែន សំអន ឧបនាយក រដ្ឋមន្ត្រីប្រចាំការ**។ អញ្ជើញចូលរួមក្នុងពិធីបិទសន្និបាត មានឯកឧត្តមតំណាងក្រសួង ស្ថាប័ននានា អង្គការ យូណេស្កូ អភិបាលរងរាជធានី-ខេត្ត ថ្នាក់ដឹកនាំក្រសួង និងមន្ត្រីវប្បធម៌ ថ្នាក់រដ្ឋបាលកណ្តាល មន្ត្រីវប្បធម៌ ថ្នាក់មន្ទីរាជធានី-ខេត្ត សរុបមានចំនួន៧០០នាក់

-ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៣ នៅសាលសន្និសីទចតុមុខ ក្រសួងរៀបចំ **ប្រារព្ធទិវាវប្បធម៌ជាតិ ៣ មីនា លើកទី១៥** ប្រធានបទ " **អ្វីៗទាំងអស់ដើម្បីវឌ្ឍនភាពវប្បធម៌ជាតិ** " ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដោយមានការអញ្ជើញចូលរួមជាកិត្តិយសពីថ្នាក់ដឹកនាំជាន់ខ្ពស់បណ្តាក្រសួង-ស្ថាប័ន ភ្ញៀវជាតិ-អន្តរជាតិ ថ្នាក់ដឹកនាំ-មន្ត្រីរាជការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សិល្បករ-សិល្បការិនី និស្សិតសកលវិទ្យាល័យ ភូមិន្ទវិចិត្រសិល្បៈ សរុបចំនួន៧០០នាក់

-នៅថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៣ គណៈប្រតិភូក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដឹកនាំដោយ **ឯកឧត្តមរដ្ឋមន្ត្រី** បានចុះសួរសុខទុក្ខ ព្រមទាំងនាំយកគ្រឿងឧបភោគ បរិភោគមួយចំនួនជូនដល់កងវរសេនាតូចលេខ៧៩៥ តំបន់ប្រាសាទព្រះវិហារ និងកងវរសេនាតូចលេខ៩០៥ ដែលកំពុងឈរជើងនៅតំបន់អន្លង់វែង ដើម្បីការពារបូរណភាពទឹកដី

-រសៀលថ្ងៃទី២៣ ដល់ព្រឹកថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៣ ក្រសួងបានរៀបចំពិធីបុណ្យពុទ្ធាភិសេកព្រះពុទ្ធរូបទ្រង់ផ្ទាំងមារព្រះនាម "**ពុទ្ធលោកនាថ**" ដែលផ្តួចផ្តើមកសាងដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅវត្តព្រះមហោសថសុវណ្ណគិរីបឹងដែង ស្ថិតនៅភូមិបឹងដែង ឃុំព្រៃកកក់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។ រសៀលថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៣ កម្មវិធីបុណ្យពុទ្ធាភិសេក ក្រោមអធិបតីភាព **លោកជំទាវ ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយព្រឹទ្ធសភា-រដ្ឋសភា និងអធិការកិច្ច** តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**។ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៣ ពិធីថ្វាយដង្វាយមធុបាយាស និងពិធីបូជាគ្រឿងសក្ការៈពុទ្ធាភិសេក និងសូត្រជយន្តោដោយព្រះសង្ឃ៩អង្គ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ។

-នៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៣ នៅទីស្តីការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានប្រារព្ធពិធីផ្ទេរតំណែងរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **លោកជំទាវ ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងព្រឹទ្ធសភា-រដ្ឋសភា និងអធិការកិច្ច** តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**។ អញ្ជើញចូលរួមក្នុងឱកាសនោះមាន ឯកឧត្តម-លោកជំទាវរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ-អគ្គនាយក សកលវិទ្យាធិការ-លោក-លោកស្រីអគ្គនាយករង-សកលវិទ្យាធិការរង-ប្រធាននាយកដ្ឋាន-ព្រឹទ្ធបុរស-អនុប្រធាន នាយកដ្ឋាន-ព្រឹទ្ធបុរសរង-លោកនាយក-នាយករងសាលាមធ្យមវិចិត្រសិល្បៈ និងអធិការ-អធិការរង សរុប មានចំនួន១៦៣នាក់។

២-ការងាររដ្ឋបាល និងហិរញ្ញវត្ថុ ៖

២.១.ការងាររដ្ឋបាលទូទៅ ៖

-បានទទួលលិខិតចូលពីគ្រប់ស្ថាប័នចំនួន២.៨៩៦ច្បាប់ និង បញ្ជូនលិខិតចេញទៅគ្រប់ស្ថាប័នចំនួន ៣.០៨៥ច្បាប់

-បានតាក់តែងនិពន្ធអត្ថបទលិខិតរដ្ឋបាល និងលិខិតបទដ្ឋានបានចំនួន២៣០ច្បាប់ តាមតម្រូវការថ្នាក់ ដឹកនាំ

-បានរៀបចំទទួលភ្ញៀវជាតិ-អន្តរជាតិ និងកម្មវិធីប្រជុំផ្សេងៗបានទាន់ពេលវេលា

-កម្លាំងសន្តិសុខ និងនគរបាលយាមប្រចាំការពេលថ្ងៃ និងយប់សហការគ្នាបានល្អក្នុងការថែរក្សា សុវត្ថិភាព នៅទីស្តីការក្រសួង

-ផលិតលិខិតស្នាមផ្សេងៗជូនថ្នាក់ដឹកនាំក្រសួងស្របតាមតម្រូវការ ដោយបានបញ្ជូនចេញតាមរយៈ ច្រកចេញរដ្ឋបាលទៅគ្រប់គោលដៅ និងស្ថាប័នពាក់ព័ន្ធទាន់ពេលវេលាយ៉ាងរលូន

-បានធ្វើការចែកចាយសៀវភៅរាជកិច្ចជូនថ្នាក់ដឹកនាំ និងនាយកដ្ឋានតាមគោលការណ៍រៀងរាល់ខែ សរុបបានចំនួន៣.១៦៨ក្បាល

-បានរៀបចំបណ្ណាល័យក្រសួង និងបានដាក់ឱ្យដំណើរការជាប្រចាំ

-ការិយាល័យពត៌មានវិទ្យាបានដំណើរការជាធម្មតា តាមផែនការរបស់ថ្នាក់ដឹកនាំក្រសួង ។

***ការងារសម្រេចមិនបាន ៖** គឺកិច្ចការមួយចំនួនបន្ទាន់ពេក ហើយការងារខ្លះមានទំហំទ្រង់ទ្រាយធំ លើសពីសមត្ថកិច្ចរបស់នាយកដ្ឋាន ។

២.២.ការងារបុគ្គលិក ៖

-បានរៀបចំប្រឡងជ្រើសរើសក្របខ័ណ្ឌឆ្នាំ២០១៣ មាន ៖

+បេក្ខជនដាក់ពាក្យប្រឡងចំនួន១៤០នាក់

+បេក្ខជនបានប្រឡងជាប់ចំនួន៦៣នាក់

-បានធ្វើប្រកាសបែងចែកមន្ត្រីក្របខ័ណ្ឌថ្មីឆ្នាំ២០១៣ ចុះធ្វើកម្មសិក្សានៅតាមអង្គភាព និងមន្ទីរាជធានី ខេត្ត

-បានធ្វើសម្រង់ព័ត៌មានសម្រាប់ធ្វើបច្ចុប្បន្នភាពទិន្នន័យមន្ត្រីរាជការស៊ីវិល ដើម្បីបំពេញចូលក្នុងប្រព័ន្ធ ព័ត៌មានវិទ្យា

-បានផ្សព្វផ្សាយសារាចរណែនាំលេខ០៦ របស់រាជរដ្ឋាភិបាល ស្តីពីការធ្វើនិយ័តកម្មថ្នាក់-ហានន្តរសក្តិ មន្ត្រីរាជការស៊ីវិល តាមអតីតភាពការងារដល់គ្រប់អង្គភាព និងបានធ្វើការប្រជុំណែនាំអំពីនីតិវិធីក្នុងការអនុវត្ត សារាចរណែនាំនេះដល់មន្ត្រីទទួលបន្ទុកគ្រប់អង្គភាព

-បានតែងតាំងមន្ត្រីរាជការតាមព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាសចំនួន៧៧នាក់

-បានធ្វើសំណើសុំតម្លើងថ្នាក់ជូនវរមន្ត្រីទៅក្រសួងមុខងារសាធារណៈចំនួន០៧នាក់

-បានធ្វើសំណើសុំតម្លើងថ្នាក់ជូនឧត្តមមន្ត្រីទៅក្រសួងមុខងារសាធារណៈចំនួន០១នាក់

-បានស្នើសុំផ្តល់មេដាយជូនមន្ត្រីរាជការក្នុងឆ្នាំ២០១៣ ទៅគណៈរដ្ឋមន្ត្រី ក្នុងនោះមាន ៖ សម្រាប់ មន្ត្រី រាជការប្រចាំឆ្នាំចំនួន២៥៨នាក់ និងសម្រាប់សកម្មភាពនារីចំនួន៦១នាក់

-បានធ្វើសំណើសុំតម្លើងថ្នាក់ជូនមន្ត្រីរាជការចំនួន៩៩៧នាក់ (ថ្នាក់កណ្តាលចំនួន៧៨៣នាក់ និងថ្នាក់រាជធានី-ខេត្តចំនួន ២១៤នាក់)

-បានធ្វើសំណើសុំតម្លើងថ្នាក់តាមកម្រិតសញ្ញាបត្រជូនមន្ត្រីរាជការទៅក្រសួងមុខងារសាធារណៈ ចំនួន៨៨នាក់ និងបានធ្វើប្រកាសតាមកម្រិតសញ្ញាបត្រជូនមន្ត្រីរាជការចំនួន១៩នាក់

-បានធ្វើសំណើសុំតម្លើងកម្រិតប្រាក់មុខងារជូនមន្ត្រីរាជការចំនួន៥៨នាក់ និងធ្វើប្រកាសតម្លើងប្រាក់មុខងារចំនួន៨៩នាក់ ទៅក្រសួងមុខងារសាធារណៈ

-បានធ្វើប្រកាសជូនមន្ត្រីរាជការឱ្យចូលនិវត្តន៍ចំនួន៧១នាក់ (ថ្នាក់កណ្តាលចំនួន៣៨នាក់ និងថ្នាក់រាជធានី-ខេត្តចំនួន៣៣នាក់)

-បានធ្វើឧទ្ទេសនាមគ្រូបង្រៀនម៉ោងបន្ថែមនៅសាលាមធ្យមវិចិត្រសិល្បៈចំនួន៥០១នាក់

-បានធ្វើឧទ្ទេសនាមគ្រូបង្រៀនពេញពេលរបស់សាលាមធ្យមវិចិត្រសិល្បៈចំនួន២១៥នាក់

-បានធ្វើឧទ្ទេសនាមគ្រូបង្រៀនពេញពេលរបស់សកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈចំនួន៥៨នាក់

-បានធ្វើសំណើសុំគោលការណ៍ប្រឡងបញ្ចប់សញ្ញាបត្រសិល្បៈ និងស្នាតកបត្រសិល្បៈរបស់សាលាមធ្យមវិចិត្រសិល្បៈសម្រាប់ឆ្នាំ២០១២-២០១៣

-បានរៀបចំធ្វើគម្រូសញ្ញាបត្រថ្មី ទាំងសាលាមធ្យមវិចិត្រសិល្បៈ និងសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈតាមស្តង់ដាក្រសួងអប់រំ យុវជន និងកីឡា ។

***ចញ្ហាប្រឈម ៖**

-ការប្រឡងប្តូរក្របខណ្ឌមន្ត្រីរាជការមិនទាន់អនុវត្ត

-ការធ្វើបច្ចុប្បន្នភាពទិន្នន័យមន្ត្រីរាជការ ដើម្បីបំពេញក្នុងប្រព័ន្ធព័ត៌មានវិទ្យាសម្រេចបាន៥០ភាគរយ

-ការធ្វើនិយ័តកម្មថ្នាក់ ហានន្តរសក្តិមន្ត្រីរាជការ សម្រេចបាន៧០ភាគរយ ។

***សំណូមពរ ៖**

-ស្នើសុំបើកវគ្គបណ្តុះបណ្តាល ដើម្បីអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ ។

២.៣.ការងារនីតិកម្ម ៖

-សហការជាមួយអង្គភាពជំនាញសម្រេចបានលិខិតបទដ្ឋានចំនួន០១គឺ ប្រកាសស្តីពីការបែងចែកភារកិច្ច លើការគ្រប់គ្រង ការប្រមូលចំណូលពីការផ្តល់សេវាសាធារណៈ

-បានចងក្រងសៀវភៅបទដ្ឋានគតិយុត្ត ភាគទី៥

-ចុះបំពេញបេសកកម្មផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តបានចំនួន១០ខេត្ត ។

***ចញ្ហាប្រឈម ៖**

-ធនធានមនុស្ស មន្ត្រីមានចំនួនតិច ធ្វើការខុសជំនាញ ពុំមានចំណង់ និងជំនក់

-សម្ភារៈបច្ចេកទេស ខ្វះខាតច្រើន (ម៉ាស៊ីនថតរូប-សម្លេងបញ្ចាំងរូបភាពអ៊ីនធើណេត...)

-ពុំមានថវិកាចុះស្រាវជ្រាវដល់ទីកន្លែង ពិគ្រោះយោបល់ចុះផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានគតិយុត្ត

-តួនាទី ភារកិច្ច ការបំពេញការងារជាន់ដែនសមត្ថកិច្ចគ្នា ។

***សំណូមពរ ៖**

-ស្នើសុំមន្ត្រីក្របខណ្ឌថ្មីចំនួន០៣រូប

-សូមមានកិច្ចសហការពីគ្រប់អង្គភាព និងឋានានុក្រមពាក់ព័ន្ធជម្រុញឲ្យការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តឲ្យមានភាពរលូន

-សូមមានការលើកទឹកចិត្តដល់មន្ត្រីរាជការ ពិសេសខាងតាក់តែងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

-សូមថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់ឋានានុក្រមជួយពង្រឹង និងបង្កើនការយកចិត្តទុកដាក់ដល់ការកសាងហេដ្ឋារចនាសម្ព័ន្ធផ្នែកច្បាប់ និងលិខិតបទដ្ឋានគតិយុត្តគ្រប់គ្រងវិស័យវប្បធម៌ ។

២.៤.ការងារគណនេយ្យ និងហិរញ្ញវត្ថុ ៖

-បានសម្រេចការងារៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៤-២០១៦
និងផែនការថវិកាប្រចាំឆ្នាំ២០១៤

-ធ្វើប្រកាសអាណាប័ក្រផ្ទេរសិទ្ធិ និងផ្ទេរឥណទានជូនសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និងមន្ទីរវប្បធម៌រាជធានី-ខេត្ត សម្រាប់ការចំណាយថវិកាឆ្នាំ២០១៣

-សំណើសុំថវិកាសម្រាប់ប្រាក់បំណាច់ថ្នាក់ដឹកនាំ បៀវត្សមន្ត្រីរាជការសរុបចំនួន១.៣៥២នាក់ ប្រចាំឆ្នាំ២០១៣

-សុំថវិកាសម្រាប់បៀវត្សមន្ត្រីកិច្ចសន្យាចំនួន៧៩នាក់ និងពលករអណ្តែតចំនួន១៤០នាក់ ប្រចាំឆ្នាំ២០១៣

-សុំថវិកាសម្រាប់ឧបត្ថម្ភជីវភាពជូនព្រឹទ្ធាចារ្យសិល្បៈដែលជាមរតកមនុស្សរស់

-សុំថវិកាសម្រាប់ឧបត្ថម្ភមន្ត្រីរាជការព្យាបាលជម្ងឺ០៩នាក់ ក្នុងឆ្នាំ២០១៣

-សុំថវិកាសម្រាប់ឧបត្ថម្ភជូនអ្នករកឃើញវត្ថុបុរាណ និងបានប្រគល់ជូនសារមន្ទីរ នៅខេត្តក្រចេះ-កំពត កំពង់ស្ពឺ និងខេត្តកំពង់ចាម

-សុំថវិកាសម្រាប់ចំណាយជូនមន្ត្រីរាជការសម្រាលកូន២១នាក់ ចូលនិវត្តន៍៣៣នាក់ មរណៈភាព០១នាក់ និងលាឈប់ពីការងារ០១នាក់ ក្នុងឆ្នាំ២០១៣

-សុំថវិកាសម្រាប់រៀបចំប្រឡងជ្រើសរើសក្របខ័ណ្ឌថ្មីចំនួន៦២នាក់ ក្នុងឆ្នាំ២០១៣

-សុំថវិកាសម្រាប់ឧបត្ថម្ភគណៈកម្មការត្រួតពិនិត្យខ្លឹមសារស្នាដៃវីដេអូ

-ចំណាយថវិកាសម្រាប់ប្រាក់ម៉ោងបន្ថែមក្នុងឆ្នាំសិក្សា២០១២-២០១៣ ជូនលោកគ្រូ-អ្នកគ្រូសាលាមធ្យមវិចិត្រសិល្បៈ

-ចំណាយថវិកាសម្រាប់អាហារូបករណ៍សិស្សក្នុងឆ្នាំសិក្សា២០១២-២០១៣ របស់សាលាមធ្យមវិចិត្រសិល្បៈ

-ធ្វើរបាយការណ៍ និងសាលាកប័ត្របង់ចំណូលចូលថវិការដ្ឋពីខែមករា-ធ្នូ ឆ្នាំ២០១៣ ក្នុងនោះមាន ៖ ចំណូលពីការលក់សំបុត្រសារមន្ទីរ-ពីការត្រួតពិនិត្យវត្ថុសិល្បៈនាំចេញ-នាំចូល-ពីការសុំសិទ្ធិធ្វើអាជីវកម្មលើស្នាដៃគ្មានអ្នកទទួលមរតក-ពីការជួលទីតាំងមួយផ្នែករបស់នាយកដ្ឋានអភិវឌ្ឍវប្បធម៌-ពីការជួលទីតាំងរោងភាពយន្តលុច្ស-ពីការជួលទីតាំងរោងភាពយន្តខេមរិន្ទ និងពីការជួលទីតាំងមណ្ឌលរូបភាព (អាឡឺយ៉ង់)។

-បានធ្វើអាណត្តិបើកប្រាក់សម្រាប់ទូទាត់រដ្ឋទេយ្យបុរេប្រទានបាន០៦ដុំ និងបានធ្វើអាណត្តិបើកប្រាក់សម្រាប់ទូទាត់ និងចំណាយផ្សេងៗសរុបចំនួន៣៣លើក

-ធ្វើគម្រោងបេសកកម្មក្នុងប្រទេសជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការបានចំនួន៤២៣លិខិត

-រៀបចំប្រមូលឯកសារឆ្នាំ២០១២-២០១៣ ត្រួតពិនិត្យចងក្រងទុកសម្រាប់អធិការកិច្ច នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអាជ្ញាធរសវនកម្មជាតិត្រួតពិនិត្យ

-ធើរបាយការណ៍ទទូទាត់រដ្ឋទេយ្យបរេប្រទានបានចំនន០៦ដំ ។

២.៥.ការងារផែនការ ស្ថិតិ និងសរុប ៖

-បានរៀបចំរបាយការណ៍ ស្តីពីលទ្ធផលការងារវិស័យវប្បធម៌ និងវិចិត្រសិល្បៈប្រចាំឆ្នាំ២០១២ និងលើកផែនការឆ្នាំ២០១៣ និងបានរៀបចំប្រមូលចងក្រងឯកសារផ្សេងៗទៀត សម្រាប់ដំណើរការប្រារព្ធពិធីសន្និបាតបូកសរុបការងារវប្បធម៌ និងវិចិត្រសិល្បៈឆ្នាំ២០១២ និងលើកផែនការឆ្នាំ២០១៣ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី២២-២៣ ខែមករា ឆ្នាំ២០១៣ នៅទីស្តីការក្រសួង និងពិធីបិទសន្និបាតនៅសាលសន្និសីទចតុមុខ

-បានរៀបចំបើកវគ្គបណ្តុះបណ្តាល ស្តីពីការរៀបចំ និងសរសេរផែនការ

-បានរៀបចំរបាយការណ៍សង្ខេប ស្តីពីសមិទ្ធផលវិស័យវប្បធម៌ និងវិចិត្រសិល្បៈ (២០០៨-២០១២) សម្រេចបានក្នុងការអនុវត្តតាមកម្មវិធីនយោបាយ យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២ របស់រាជរដ្ឋាភិបាល ជូនទីស្តីការគណៈរដ្ឋមន្ត្រី

-កសាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០១៤-២០១៨ (ជូនក្រសួងផែនការ)

-បានប្រមូលទិន្នន័យចងក្រងសៀវភៅស្ថិតិឆ្នាំ២០១៣

-បានបូកសរុបរបាយការណ៍ ស្តីពីលទ្ធផលការងារវិស័យវប្បធម៌ និងវិចិត្រសិល្បៈប្រចាំខែ-ត្រីមាស ឆមាស-៩ខែ និងប្រចាំឆ្នាំ ដោយបានផ្ញើជូនទីស្តីការគណៈរដ្ឋមន្ត្រី ស្តាប័នពាក់ព័ន្ធបានទាន់ពេលវេលាកំណត់ និងត្រៀមរៀបចំជារបាយការណ៍រូបភាពប្រចាំឆ្នាំ២០១៣

-លើកគម្រោងផែនការសកម្មភាពការងារវប្បធម៌ និងវិចិត្រសិល្បៈឆ្នាំ២០១៤

-រៀបចំធ្វើតារាងសរុបស្តីពីគម្រោងវិនិយោគសាធារណៈដែលប្រើប្រាស់ថវិការដ្ឋ និងហិរញ្ញប្បទានផ្សេងៗរបស់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី-ខេត្ត ដែលក្រសួងបានទទួលក្នុងឆ្នាំ២០១៣

-បានរៀបចំធ្វើតារាងសរុបគម្រោងបញ្ចូលក្នុងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល (ឆ្នាំ២០១៤-២០១៦)។

*ការងារវិនិយោគសាធារណៈដែលប្រើប្រាស់ថវិការដ្ឋ និងហិរញ្ញប្បទានផ្សេងៗរបស់មន្ទីរខេត្ត ៖

១-មន្ទីរវប្បធម៌ខេត្តបន្ទាយមានជ័យ ទទួលទុនសរុបចំនួន**៥០០.០០០.០០០រៀល** ប្រភពទុន ៖ ថវិការដ្ឋ អនុវត្តគម្រោងកែលម្អ និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធវប្បធម៌ ។

២-មន្ទីរវប្បធម៌ខេត្តកំពង់ស្ពឺ ទទួលទុនសរុបចំនួន **១.៨៨០ដុល្លា** ប្រភពទុន ៖ សប្បុរសជន និងទុនចំនួន**៣.១០០.០០០រៀល** ប្រភពទុន ៖ ថវិការដ្ឋ អនុវត្តគម្រោងកែលម្អរមណីយដ្ឋានបុរាណវត្តភ្នំចាស់ និងគម្រោងដាំកូនឈើ នៅរមណីយដ្ឋានភ្នំចាស់ និងទួលគុហា។

៣-មន្ទីរវប្បធម៌ខេត្តក្រចេះ ទទួលទុនសរុបចំនួន**២.៨០០.០០០.០០០រៀល** ប្រភពទុន ៖ ថវិការដ្ឋ ជំពូក២របស់ក្រសួង អនុវត្តគម្រោងសាងសង់សាលាមធ្យមវិចិត្រសិល្បៈ សម្រាប់ភូមិភាគឥសាន្ត។

***ការងារសម្រេចមិនបាន ៖** នាយកដ្ឋានមានផែនការសកម្មភាពប្រចាំឆ្នាំចំនួន**០៨**ចំណុច ក្នុងនោះអនុវត្តបាន**០៦**ចំណុច នៅសល់**០២**ចំណុចអនុវត្តមិនបានគឺ ការងារបោះពុម្ព ដោយមូលហេតុ ៖

-ពុំមានថវិកាសម្រាប់បម្រើការបោះពុម្ពសៀវភៅរបាយការណ៍រូបភាព ស្តីពីលទ្ធផលការងារសំខាន់ៗវិស័យវប្បធម៌ និងវិចិត្រសិល្បៈប្រចាំឆ្នាំ២០១៣

-ពុំមានថវិកាសម្រាប់បម្រើការបោះពុម្ពសៀវភៅស្ថិតិវប្បធម៌ប្រចាំឆ្នាំ២០១៣។

នាយកដ្ឋានផែនការ ស្ថិតិ និងសរុប ជាសេនាធិការរបស់ក្រសួង ក្នុងការប្រមូលផ្តុំ ចងក្រងឯកសារនូវ រាល់សកម្មភាពវិស័យវប្បធម៌ជាតិនៅទូទាំងប្រទេស ដើម្បីធ្វើការបូកសរុប-កសាងផែនការ និងសម្រង់ ព័ត៌មាន បង្ហាញអំពីស្ថិតិវិស័យវប្បធម៌។ ការងារនេះយើងបានអនុវត្តជាប្រចាំដើម្បីបម្រើបុព្វហេតុស្តាប់ន វប្បធម៌។ ប៉ុន្តែ អកុសលឆ្នាំ២០១៣ នាយកដ្ឋាន**ពុំមានកញ្ចប់ថវិកាប្រចាំឆ្នាំគឺ "សូន្យ"** សម្រាប់បម្រើឱ្យ បុព្វហេតុនេះឡើយ គឺបានត្រឹមតែ**ធ្វើការបូកសរុប-កសាងផែនការ និងសម្រង់ស្ថិតិតែប៉ុណ្ណោះ** ។

២.៦.ការងារសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ៖

ក.ការងារទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ ៖

-ស្វែងរកជំនួយពីអង្គការ WIPO រៀបចំសិក្ខាសាលា

-ស្វែងរកជំនួយពីអង្គការ PEN រៀបចំកិច្ចប្រជុំជាមួយអ្នកនិពន្ធ ស្តីពីស្មាដៃអក្សរសាស្ត្រ

-ទំនាក់ទំនងជាមួយបរទេសដើម្បីទទួលបាននូវជំនួយពង្រឹងសមត្ថភាពមន្ត្រីទៅបណ្តុះបណ្តាលក្រៅ ប្រទេសចំនួន០៥លើក នៅប្រទេសថៃ និងប្រទេសជប៉ុន ។

ខ.ការរកជំនួយថវិកាសម្រាប់ការងារបណ្តុះបណ្តាល ៖

-ការបណ្តុះបណ្តាលនៅបរទេសមានចំនួន០៥លើក ទទួលថវិកាចំនួន៣៥.០០០ដុល្លាអាមេរិក

-ការរៀបចំសិក្ខាសាលាមានចំនួន០២លើក ទទួលថវិកាចំនួន៦.០០០ដុល្លាអាមេរិក ។

គ.ការងាររៀបចំបទប្បញ្ញត្តិ ៖

-រៀបចំសេចក្តីព្រាងអនុក្រឹត្យ ស្តីពីអង្គភាពគ្រប់គ្រងសិទ្ធិរួម និងបានចូលរួមពិភាក្សាឆ្លងនៅក្រុម ប្រឹក្សា អ្នកច្បាប់ចំនួន០៤លើក

-រៀបចំបាននូវប្រកាសលេខ១៥០ ស្តីពីការគ្រប់គ្រងអាជីវកម្មសេវាថតចម្លង

-រៀបចំបាននូវប្រកាសលេខ១៥១ ស្តីពីការគ្រប់គ្រងអាជីវកម្មឌីសអុបទិក និងឧបករណ៍ថតចម្លង

-រៀបចំបាននូវសេចក្តីណែនាំលេខ០៥ ស.ណ.ន ស្តីពីការអនុវត្តខ្លឹមសារប្រកាសលេខ១៥១ ។

ឃ.ការងារផ្តល់សេវា ៖

-ចុះបញ្ជីការពារស្មាដៃបាន៣៧ស្មាដៃ

-សុំសិទ្ធិធ្វើអាជីវកម្មបាន២២៦បទ

-ការអនុញ្ញាតបោះពុម្ពបាន០៨លេខ

-ការអនុញ្ញាតនាំចូលសៀវភៅបាន០១ចំណងជើង

*ទទួលថវិកាពីការផ្តល់សេវាបង់ចូលថវិកាជាតិសរុបមានចំនួន**៨.៨១៥.០០០រៀល** ។

***ឧបសគ្គ ៖**

-លិខិតចូលមិនបានឆ្លងនាយកដ្ឋានជំនាញផ្តល់មតិ ធ្វើឲ្យថ្នាក់ដឹកនាំមានការយល់ច្រឡំក្នុងការធ្វើ សេចក្តីសម្រេច

-ការទម្លាក់ឯកសារមកវិញមិនចំនាយកដ្ឋានសាមី ជាឧទាហរណ៍មន្ត្រីទៅចូលរួមប្រជុំនៅបរទេស ជាមន្ត្រីនាយកដ្ឋានសិទ្ធិអ្នកនិពន្ធ តែឯកសារទម្លាក់នៅនាយកដ្ឋាន RC

-ថវិកាអនុវត្តផែនការសកម្មភាពមានកម្រិតតិច

-មិនទាន់មានការផ្សព្វផ្សាយបទប្បញ្ញត្តិឲ្យបានទូលាយ

-កង្វះការសហការការងាររលើវិស័យកម្មសិទ្ធិបញ្ញាជាមួយមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី-ខេត្ត

-មិនទាន់សម្រេចបាននូវអនុក្រឹត្យអង្គភាពគ្រប់គ្រងសិទ្ធិរួម ព្រោះ CMO នេះជា Nex Work មួយ សម្រាប់ទំនាក់ទំនងរវាងអ្នកនិពន្ធ ជាមួយអ្នកប្រើប្រាស់ ។

***សំណូមពរ ៖**

-ស្នើសុំក្រសួងជួយជម្រុញឲ្យចេញអនុក្រឹត្យអង្គភាពគ្រប់គ្រងសិទ្ធិរួម ដោយមានកញ្ចប់ថវិកាពិសេសសម្រាប់ចំណាយ

-ស្នើសុំទៅស្ថាប័នគយជួយសហការវិស័យកម្មសិទ្ធិបញ្ញាលើការនាំចូល នាំចេញឌីសអុបទិក ឧបករណ៍ ថតចម្លង និងស្នាដៃគ្រប់ប្រភេទដែលយកមកធ្វើអាជីវកម្ម ត្រូវមានការអនុញ្ញាតពីក្រសួងវប្បធម៌ និងវិចិត្រ សិល្បៈ

-ស្នើសុំមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈជួយសហការលើការផ្តល់សេវាថតចម្លង និងផ្តល់របាយការណ៍មកនាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ឬសហការជាមួយនាយកដ្ឋានដើម្បីធ្វើការផ្សព្វផ្សាយ ពីវិស័យកម្មសិទ្ធិបញ្ញា និងការផ្តល់សេវាវប្បធម៌

-លិខិតចូលទាំងភាសាអង់គ្លេស ទាំងភាសាខ្មែរដែលទាក់ទងជំនាញកម្មសិទ្ធិបញ្ញា សូមបញ្ជូនលិខិតនោះមកនាយកដ្ឋានជំនាញផ្តល់មតិជាមុនសិន

-សូមផ្តល់កញ្ចប់ថវិកាដើម្បីអនុវត្តការងារតាមនាយកដ្ឋានឲ្យបានច្រើន ព្រោះការងារស្ថិតនៅនាយកដ្ឋានជំនាញ បើនាយកដ្ឋានមានគម្រោងថវិកាច្រើន គឺមានសកម្មភាពច្រើនដែលជាស្នាដៃនៃសកម្មភាពរបស់ក្រសួង

-ស្នើសុំមន្ត្រីក្របខណ្ឌថ្មីបន្ថែម ។

២.៧.ការងារសម្ភារៈ និងបរិក្ខារ ៖

-បានចុះទៅផ្ទៀងផ្ទាត់សៀវភៅបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០១២ របស់មន្ទីរវប្បធម៌ និងវិចិត្រ សិល្បៈខេត្តកំពង់ចាម

-ត្រួតពិនិត្យបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០១២ របស់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពង់ស្ពឺ និងខេត្តប៉ៃលិន។

បានធ្វើសំណើសុំគោលការណ៍ធានាចំណាយចំនួន២២មុខ ក្នុងនោះមាន៖ ទិញប្រេងឥន្ធនៈ០២លើក ទិញសម្ភារៈការិយាល័យ-ទិញសម្ភារៈបច្ចេកទេស-ទិញសម្ភារៈប្រើប្រាស់សម្រាប់បោះពុម្ពតាមអង្គភាព-ទិញសម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំឧបករណ៍រថយន្ត-ទិញគ្រឿងសង្ហារឹមសម្រាប់ប្រើប្រាស់-
ទូទាត់ថ្លៃជួសជុលរថយន្ត រដ្ឋប្រចាំឆ្នាំ-ជួសជុលរបងខ្លោងទ្វារ ចាក់សាប ធ្វើរបងរោងសៀក និងរៀបចំកែលម្អអាគារសាលប្រជុំ នៅទីស្តីការ ក្រសួង-ជួសជុលកែលម្អអាគាររដ្ឋបាល នៃមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តប៉ៃលិន-ជួសជុលកែលម្អរបង ខ្លោងទ្វាររបស់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តបាត់ដំបង-ជួសជុលប្រាសាទនគរបាជ័យ ខេត្តកំពង់ចាម-ជួសជុលប្រាសាទសំបូរព្រៃគុក S2 ខេត្តកំពង់ធំ-ជួសជុលប្រាសាទបន្ទាយឆ្មារ ខេត្តបន្ទាយមានជ័យ-ជួសជុលរូបចម្លាក់បុរាណដែលស្ថិតនៅអភិរក្សដ្ឋានអង្គរ ខេត្តសៀមរាប និងគោលការណ៍ធានា ចំណាយដើម្បីបោះពុម្ពសៀវភៅជំនួយស្មារតី និងសៀវភៅផ្នត់ ។

-បែងចែកប្រេងឥន្ធនៈ ទៅតាមគម្រោងបែងចែក និងធ្វើការបែងចែកសម្ភារៈការិយាល័យជូនថ្នាក់ដឹកនាំ និងគ្រប់នាយកដ្ឋាន

-ការងារដេញថ្លៃចំនួន១១មុខ ក្នុងនោះមាន ៖ ដេញថ្លៃប្រេងឥន្ធនៈ-ទិញសម្ភារៈការិយាល័យឆមាសទី២-រៀបចំថែទាំ និងតបណ្តាញផ្សេងៗ-ជួសជុលរបងខ្លោងទ្វារ ចាក់សាប ធ្វើរបងរោងសៀក និងរៀបចំកែលម្អអាគារសាលប្រជុំ នៅទីស្តីការក្រសួង-ជួសជុលកែលម្អអាគាររដ្ឋបាល នៃមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តប៉ៃលិន-ជួសជុលកែលម្អរបង ស្ថិតនៅស្រុកថ្មគោល ខេត្តបាត់ដំបង-ជួសជុលប្រាសាទនគរបាជ័យ ខេត

កំពង់ចាម-ជួលជួលប្រាសាទសំបូរព្រៃគុក S2 ខេត្តកំពង់ធំ-ជួសជុលប្រាសាទបន្ទាយឆ្មារ ខេត្តបន្ទាយមានជ័យ និងជួលជុលរូបចម្លាក់បុរាណ ស្ថិតនៅក្នុងអភិរក្សដ្ឋានអង្គរ ខេត្តសៀមរាប

-ការងារប្រគល់-ទទួលចំនួន២៣មុខ ក្នុងនោះមាន ៖ ប្រេងឥន្ធន:០២លើក-សម្ភារ:ការិយាល័យឆមាសទី២-រៀបចំថែទាំជួសជុលឧបករណ៍ការិយាល័យ-សម្ភារ:ប្រើប្រាស់១០លើក-សម្ភារ:ផ្គត់ផ្គង់សម្រាប់ថែទាំឧបករណ៍រថយន្ត-គ្រឿងសង្ហារឹមសម្រាប់ប្រើប្រាស់-ជួសជុសរថយន្តរដ្ឋ-ជួសជុលរោងសៀក-រៀបចំកែលម្អអគារសាលប្រជុំនៅទីស្តីការក្រសួង-ជួសជុលខ្លោងទ្វារប្រាសាទនៅស្រុកបាណន់ ខេត្តបាត់ដំបង-ជួសជុលអគារមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តប៉ៃលិន-ជួសជុលប្រាសាទនគរបាជ័យ ខេត្តកំពង់ចាម និងប្រាសាទ សំបូរព្រៃគុក ខេត្តកំពង់ធំ ។

-បោះពុម្ពបដាពាក្យស្លោកដាក់តាំងបង្ហាញសម្រាប់ពិធីសន្និបាតក្រសួង ទិវាវប្បធម៌ជាតិ ០៣ មីនា និងបុណ្យផ្សេងៗសម្រាប់ដាក់តាំងនៅទីស្តីការក្រសួង ។

២.៨.ការងារសហប្រតិបត្តិការវប្បធម៌អន្តរជាតិ និងកិច្ចការអាស៊ាន ៖

-បានទទួលលិខិតចូលចំនួន៤៧២ឯកសារ មកពីគ្រប់ស្ថាប័ន អង្គការ និងពីក្រៅប្រទេស ដើម្បីជូនថ្នាក់ដឹកនាំក្រសួងត្រួតពិនិត្យ និងសម្រេច

-បានទទួលគណៈប្រតិភូមកជួបពិភាក្សាទំនាក់ទំនងការងារវប្បធម៌ និងវិចិត្រសិល្បៈ ចូលរួមអមឯកឧត្តម រដ្ឋមន្ត្រី ក្នុងការជួបភ្ញៀវជាតិ-អន្តរជាតិ និងប្រជុំពិភាក្សាការងារផ្សេងៗមានចំនួន៧២លើក

-គណៈប្រតិភូធ្វើទស្សនកិច្ចនៅក្រៅប្រទេសមានចំនួន៤៦លើក

-ឯកឧត្តម ជុច ភឿន រដ្ឋលេខាធិការ តំណាងដ៏ខ្ពង់ខ្ពស់ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានចុះហត្ថលេខាបន្តលើអនុស្សារណៈនៃការបញ្ជូនអ្នកជំនាញទៅចូលរួមវគ្គបណ្តុះបណ្តាល នៅសារមន្ទីរអូគីណាវ៉ា ប្រទេសជប៉ុន

-ឯកឧត្តម សំរាំង កំសាន្ត រដ្ឋលេខាធិការ តំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមរដ្ឋមន្ត្រី និង ឯកឧត្តមអនុរដ្ឋមន្ត្រីការបរទេស នៃសាធារណរដ្ឋអេក្វាឌ័រ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀង ស្តីពីការការពារការអភិរក្ស ការទាមទារ និងការប្រគល់សងមកវិញនូវសម្បត្តិវប្បធម៌ និងធម្មជាតិ រវាងកម្ពុជា-អេក្វាឌ័រ ។

២.៩.សាលាបណ្តុះបណ្តាលក្របខ័ណ្ឌវប្បធម៌ ៖

សាលាបានរៀបចំឯកសារស្នើសុំគោលការណ៍បើកវគ្គបណ្តុះបណ្តាលមន្ត្រីរាជការចំនួន០៣វគ្គគឺ៖ វគ្គបំពាក់បំប៉នគ្រប់គ្រងសិល្បៈមហាជន វគ្គបណ្តុះបណ្តាលការងាររដ្ឋបាល និងបទពិសោធន៍ការងារសម្រាប់មន្ត្រីក្របខណ្ឌឆ្នាំ២០១១ និងឆ្នាំ២០១២ និង វគ្គបណ្តុះបណ្តាលមន្ត្រីគ្រប់គ្រងសារមន្ទីរ ។

***ការងារសម្រេចមិនបាន ៖** ការបើកវគ្គទាំង០៣វគ្គនេះ មិនបានបើក ដោយរង់ចាំថវិកាពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

៣-ការងារបេតិកភណ្ឌរូបី ៖

៣.១.ការងារគាំពារ និងអភិរក្សសំណង់បុរាណ ៖

ក.ការងារអភិរក្សអង្គរ ៖

-បានប្រគល់វត្ថុសិល្បៈចំនួន២២មុខ ឱ្យទៅសកលវិទ្យាល័យ Palermo ប្រទេសអ៊ីតាលីខ្ញី ដើម្បីធ្វើការជួសជុលនៅអាគារថ្មបាយក្រៀមក្នុងបរិវេណអភិរក្សអង្គរ សៀមរាប

-បានទទួលអ្នកជំនាញមកពីសាលាបារាំងចុងបូព៌ាចំនួន១៦នាក់ ក្នុងនោះមានគ្រូ និងសិស្ស មកស្រាវជ្រាវ និងបង្រៀនអានអក្សរសិលាចារឹកដោយផ្ទាល់នៅក្នុងឃ្លាំង និងអ្នកជំនាញចំនួន០៧នាក់ ជាអ្នកស្រាវជ្រាវ អក្សរសិលាចារឹកនៅក្នុងឃ្លាំងចំនួន០១ថ្ងៃ

-ទទួលក្រុមការងារ Scan 3D មកពី Uni-Herdelberg មានលោកបណ្ឌិត គឹម ចំរើន និង Mr Dominik បានយកសិលាចារឹកមុនសម័យអង្គរ និងសម័យអង្គរមក Scan មានចំនួន១០ដុំ ដែលមានលេខរៀង K367 K132, K18, K908, K289, K754, K300, K70, K95, K323 រីឯលទ្ធផលវិភាគនៅប្រទេសអាឡឺម៉ង់ សម្រេចលទ្ធផលចុងក្រោយ នឹងផ្ញើឯកសារត្រឡប់មកអភិរក្សអង្គរទុកជាឯកសារផងដែរ។

ខ.ការងារស្រាវជ្រាវ និងចងក្រងឯកសារប្រវត្តិសាស្ត្រ ៖

-បានចុះទៅពិនិត្យមើលប្រជាពលរដ្ឋសង់លំនៅដ្ឋានក្នុងតំបន់២ នៃប្រាសាទបន្ទាយឆ្មារបាន០២លើក ចំនួន៣១ថ្ងៃ

-បានចុះទៅសហការជាមួយអង្គការ G.H.F រៀបជញ្ជាំងរោងទងទី៣ និងតូប៉មទី១៨ នៃប្រាសាទបន្ទាយឆ្មារ

-បានចុះទៅពិនិត្យស្ថានភាពប្រាសាទ S2 នៅសំបូរព្រៃគុក ខេត្តកំពង់ធំមុនការជួសជុលចំនួន២ថ្ងៃ។

គ.ការងារគ្រប់គ្រងរមណីយដ្ឋានវប្បធម៌ ៖

-បានរៀបចំ និងប្រមូលឧបករណ៍ដែលបានយកទៅជួសជុលប្រាសាទបន្ទាយឆ្មារកាលពីឆ្នាំ២០១២ មកពិនិត្យ និងបញ្ចូលឃ្លាំងនៅនាយកដ្ឋានវិញ

-បានរៀបចំឯកសារ ដើម្បីធ្វើបទបង្ហាញក្នុងសិក្ខាសាលាអាស៊ាន ស្តីពីការអភិរក្សបេតិកភណ្ឌវប្បធម៌ ចំនួន៣ថ្ងៃ នៅខេត្តសៀមរាប

-រៀបចំប្លង់គោលរបស់ប្រាសាទតាព្រហ្មជាប្រាសាទរណបនៃប្រាសាទបន្ទាយឆ្មារចំនួន០២ប្លង់

-បានរៀបចំឯកសារ ស្តីពីការជួសជុលប្រាសាទបន្ទាយឆ្មារចំនួន១១ប្លង់

-មន្ត្រីជំនាញសហការជាមួយបុគ្គលិកអង្គការអាឡឺម៉ង់ ជួសជុលរូបអប្សរាបាក់បែកនៅក្នុងឃ្លាំងអភិរក្ស ចំនួន១៥រូប។

ឃ.ការងារអភិរក្សជួសជុលប្រាសាទ-សំណង់បុរាណ ៖

-បានទៅចូលរួមពិនិត្យការជីកផ្នូរសពបុរាណ នៅភូមិបន្ទាយឆ្មារជើង ឃុំបន្ទាយឆ្មារ និងទៅពិនិត្យការដ្ឋានជួសជុលប្រាសាទបន្ទាយឆ្មារចំនួន០១ថ្ងៃ

-បានរៀបចំឯកសារ ដើម្បីធ្វើបទបង្ហាញក្នុងសិក្ខាសាលាអាស៊ាន ស្តីពីការអភិរក្សបេតិកភណ្ឌវប្បធម៌ "ជួសជុលប្រាសាទ" ចំនួន៥ថ្ងៃ នៅខេត្តសៀមរាប

-បានចុះទៅ០២លើកពិនិត្យមើលស្ថានភាពប្រែប្រួលនៃប្រាសាទ S8/S2 ក្រុមប្រាសាទសំបូរព្រៃគុក ខេត្តកំពង់ធំចំនួន០៧ថ្ងៃ

-បាននឹងកំពុងអនុវត្តគម្រោងថវិការដ្ឋជួសជុលប្រាសាទ ឆ្នាំ២០១៣ ចំនួន០៣កន្លែងគឺ ៖

+ទី១ ៖ **គម្រោងទល់ទ្រប្រាសាទ S2 ក្រុមប្រាសាទសំបូរព្រៃគុក ខេត្តកំពង់ធំ**

+ទី២ ៖ **គម្រោងជួសជុលប្រាសាទនគរបាជ័យ ខេត្តកំពង់ចាម**

+ទី៣ ៖ **គម្រោងជួសជុលស្ពានហាល នៃប្រាសាទបន្ទាយឆ្មារ** ។

ង.ការងារគ្រប់គ្រងសំណង់ប្រវត្តិសាស្ត្រ ៖

-បានរៀបចំឯកសារប្រាសាទក្នុងតំបន់អង្គរមុនពេលអាជ្ញាធរអប្សរាគ្រប់គ្រងមានប្លង់ប្រាសាទចំនួន ០៣ច្បាប់ និងរូបថតចំនួន៥០សន្លឹក ។

-បានធ្វើកំណាយបុរាណវិទ្យានៅប្រាសាទ S2 នៃក្រុមប្រាសាទសំបូរព្រៃគុកចំនួន០២កន្លែងគឺ ខាងក្នុងប្រាង្គ និងផ្នែកខាងក្រោយប្រាសាទមុខខាងលិច មានទំហំ១,៩០ម គុណ៧,២០ម

-បានចងក្រងឯកសារចាស់ៗ ស្តីពីសំណង់ប្រវត្តិសាស្ត្រ នៅខេត្តបន្ទាយមានជ័យចំនួន០៤ច្បាប់ និងស្តីពីប្រវត្តិប្រាសាទ នៅរមណីយដ្ឋានប្រវត្តិសាស្ត្រ ប្រាសាទសំបូរព្រៃគុក ខេត្តកំពង់ធំចំនួន០២កន្លែង ។

ច.ការងារអភិរក្សតាមបណ្តាខេត្ត ៖

-អភិរក្សដ្ឋានកំពង់ធំ និង ព្រះវិហារ ៖

+ចូលរួមសហការជាមួយអង្គការ Waseda ទាំងបច្ចេកទេសជួសជុល និងចងក្រងឯកសារការជួសជុលប្រាសាទសំបូរព្រៃគុកនៅខេត្តកំពង់ធំ

+តាមដាន និងពិនិត្យសកម្មភាពរបស់អង្គការ German Apsara Conservation Project ដែលបានទៅសិក្សាទូទៅ នៃក្រុមប្រាសាទសំបូរព្រៃគុក ។

-អភិរក្សដ្ឋានបាត់ដំបង បន្ទាយមានជ័យ និងឧត្តរមានជ័យ ៖

+បាននឹងកំពុងបន្តសហការជាមួយអង្គការ G.H.F ជួសជុលប្រាសាទបន្ទាយឆ្មារ ទាំងបច្ចេកទេសជួសជុល និងចងក្រងឯកសារបន្តបន្ទាប់

+បានបញ្ចប់ការស្រាវជ្រាវរោងទងលោកេស្វរៈ ដើម្បីបញ្ជូនឯកសារទៅអគ្គនាយកដ្ឋានបេតិកភណ្ឌ

+រៀបចំស្លាកសញ្ញាលំនៅដ្ឋានគំរូ ទំហំ២ម គុណ១.៨០ម យកទៅដាក់នៅសាលាឃុំបន្ទាយឆ្មារដើម្បីឱ្យប្រជាជនអនុវត្តឱ្យបានត្រឹមត្រូវ

+បានសម្អាតកសិណមុខខាងកើត ប៉ែកខាងត្បូង នៃប្រាសាទបន្ទាយឆ្មារបានចំនួន៦០០០ ម៉ែត្រការ៉ែ

+បានយកទូកឈើមកដាក់ក្នុងកសិណសម្រាប់បារពើកជាប្រចាំ

+បានចុះទៅមើលស្ថានភាពប្រែប្រួលនៃប្រាសាទបន្ទាយឆ្មារ និងការជួសជុលស្ពានហាលទិសអាគ្នេយ៍

+ប្រាសាទបន្ទាយឆ្មារទទួលរងដោយគ្រោះទឹកជំនន់ ធ្វើឱ្យហេដ្ឋារចនាសម្ព័ន្ធប្រាសាទមួយចំនួនបានរលុះបាក់បែកថ្មគ្រឹះ និងមន្ត្រីយើងបានខិតខំទប់ទឹកមិនឱ្យហូរចូលប្រាសាទជាបណ្តោះអាសន្ន។

ឆ.ការងារសហប្រតិបត្តិការជាមួយអន្តរជាតិ ៖

***បានសហការជាមួយអង្គការ G.H.F** ជួសជុលប្រាសាទបន្ទាយឆ្មារ ៖

ការងារជួសជុលរោងទងទី៣៖ រៀបថ្មជញ្ជាំងរោងទងបាន៦២ដុំ-ថ្មខឿនបាន០៤ដុំ-ថ្មបាតជញ្ជាំងបាន ០២ដុំ-ថ្មកំរាលបាន៦៥ដុំ-រៀបសរសរបាន១៥ដុំ-បានរើថ្មជញ្ជាំងបន្តទៅជើងចំនួន២០៧ដុំ-គូរប្លង់ថ្មពុះទទឹងបាន០៤កន្លែង-ចាប់រន្ធាថ្មីបាន០២កន្លែង-រើឈើទល់ទ្រជញ្ជាំងកាលពីឆ្នាំ២០០៧ចេញ ដើម្បីពិនិត្យមើលរចនាសម្ព័ន្ធ-ឆែក Level កម្រាលរោងទងជិតរួចរាល់ហើយ-ជួសជុលថ្មបាន១៥ដុំ មាន៤៨បំណែក និងចាក់កម្រាលបេតុងបាន៩៤ដុំ-រើថ្មជញ្ជាំងបាន២៤៣ដុំ-រើខឿនខាងក្រោយបាន១០៩ដុំ-រៀបផ្គុំថ្មបំណែកបាន៥៣ដុំ មាន១០៦ បំណែក-រើថ្មរលុះជ្រុងខាងជើងបាន៤២ដុំ-រៀបថ្មបាតជញ្ជាំងសាកល្បងបាន៦៥ដុំ-រៀបថ្មភក់បាតគ្រឹះបាន០១ដុំ និងថ្មបាយក្រៀមបាន០៣ដុំ-រើថ្មខឿនខាងក្រោយចំនួន៥៨ដុំ-រើថ្មដំបូលដែលរលុះជាប់ខឿនខាងក្រោយចំនួន ២៥ដុំ-រើថ្មដែលរលុះនៅច្រកទ្វារខាងជើងចំនួន៣៥ដុំ-រៀបជួបបាតជញ្ជាំង និងរៀបជួបជញ្ជាំងសាកល្បងចំនួន ២៣ដុំ (សាកល្បងលើកទី១)-

ជួសជុលថ្មបាតជញ្ជាំងចំនួន០៥ដុំ-ជួសជុលថ្មជញ្ជាំងចំនួន២៦ដុំ-ជួសជុលថ្មធ្នឹម
ក្រោយទ្រទ្វារនៅនឹងបាតជញ្ជាំង០១ដុំ ដោយប្រើដែក០៦ដើម និងបាញ់ការពង្រឹង-បន្តរើខឿនមុខខាងកើត ចំនួន៩៨ដុំ និងរៀបចូលវិញចំនួន៣២ដុំ-រើកម្រាលដើម្បីរៀបសាកល្បងនៅបន្ទាត់៤៧-៤៨ចំនួន៣០ដុំ-ចាប់ផ្តើម រៀបសាកល្បងកម្រាលចំនួន០៦ដុំ-រៀបសាកល្បងថ្មជញ្ជាំងចំនួន៣០ដុំ-រើថ្មសសរចំនួន៤០ដុំ-គូរប្លង់មើលពី លើថ្មរលុះនៅស្លាបខាងជើងនៃរោងទងទី៣ ទិសអាគ្នេយ៍-ជួសជុលខឿនខាងមុខ និងខាងក្រោយចំនួន១៤ដុំ និងជួសជុលថ្មកម្រាលចំនួន០៣ដុំ។ **ការងារនៅតូប៉មទី១៨៖** បានធ្វើសម្រង់ប្លង់ដែលបានជួសជុលរួច ដើម្បី ទុកជាឯកសារ-សម្អាតជុំវិញការដ្ឋាន-កាត់តម្រឹមថ្មតាមជ្រុង-រៀបថ្មកំពូលបញ្ចប់បាន៨០ដុំ រៀបថ្មរលុះបាន០៤ដុំ និងស្វានដាក់ដែកទាមបាន៦៣ដែក-បានរើរន្ធាដែកពីខាងត្បូងរួចរាល់-រើរន្ធាដែកពីខាងលិច និងខាងកើតទុកត្រឹមកំពស់២មសម្រាប់រៀបថ្មដំបូលទាំងសងខាង-ទុករន្ធាខាងជើង ដើម្បីគូរប្លង់ថ្មពីលើចុះក្រោម-រៀបថ្មមុខព្រហ្មកំពូលរួចរាល់ជាស្តាពរ-សម្អាតថ្មផ្ទៃកខាងលិច-ត្រៀមគូរប្លង់ ចុះលេខថ្ម និងស្រង់កំពស់បញ្ចប់-រើ និងរៀបទៅវិញនូវស្លាបខាងលិចចំនួន០៣រួត អស់ថ្មចំនួន៣៧ដុំ-ដាប់រំលើងថ្មជំនួសថ្មី និងបោសសម្អាតកំទេចថ្មបញ្ចប់ និងរៀបចំធ្វើផ្លូវចូលទស្សនា។

***បានធ្វើកិច្ចសហការជាមួយអង្គការ Waseda ជួសជុលប្រាសាទសំបូរព្រៃគុក ៖**

បានកំពុងដាប់ឆ្លាក់ក្បាច់ស៊ុមទ្វារនៃប្រាសាទ S1 មុខខាងកើត-បោសសម្អាតជុំវិញបរិវេណប្រាសាទ S1-តថ្មគ្រោងស៊ុម ទ្វារខាងលើ០១សន្លឹក នៃប្រាសាទ N1 បាន០២ដុំ យកទៅដាក់លើគ្រោងស៊ុមថ្មី-ធ្វើរន្ធាប្រវែង០២ម គុណ១ម ដើម្បីបញ្ចូលថ្មសន្លឹកទៅវិញ-ធ្វើកំណាយសម្អាតជើងប្រាសាទ N1 ប្រវែង២ម គុណ ០១ម-រៀបដាក់ឥដ្ឋឡើងវិញនៅចន្លោះស៊ុមទ្វារ និង ជញ្ជាំងឥដ្ឋដោយប្រើបាយអរ-ដុះលាងសម្អាតកន្លែងដែលត្រូវជួសជុលប្រវែង២ម គុណ០១ម-ជួសជុលឡើងវិញសរសរផ្គោប ប្រាសាទច្រកខាងកើតផ្ទៃក ខាងត្បូងរៀបឥដ្ឋចំនួន៤១ដុំ ដោយប្រើបាយអរអស់ចំនួន១៥ឈុត-ជួសជុលសរសរផ្គោបប្រាសាទN1 មុខខាងកើតសសរខាងត្បូងបន្តធ្ងុំឡើងដល់កន្លែងដើមវិញ រៀបឥដ្ឋចាប់ពីស្រទាប់ទី១៤ ដល់ស្រទាប់ទី៣១-ដាក់ដែកទាមនៅសើរទី២០,២២,២៥,២៧,៣៦ និងទី៣៩-រៀបចំជួសជុលសរសរផ្គោបបន្តចំនួន២៥សើរ ពីសើរទី២០ ដល់សើរទី៤៥-ប្រើដែកទាម៣លីអស់៤៥៧ស.ម ដែកទាម៥លីអស់៩២ស.ម និងដែកទាម៨លីចំនួន២៧២ ស.ម-ប្រើការ EPOXY ដើម្បីលាយចំនួន២១៦ក្រាម-រៀបសរសរជ្រុងខាងកើតនៃប្រាសាទ N1 ពីស្រទាប់ទី ៣៤ ដល់ស្រទាប់ទី៤៩-រៀបឥដ្ឋប្រាសាទ N1 ៤ស្រទាប់ ពីសើរទី១ ដល់សើរទី៤ ផ្ទៃកខាងលើបានចំនួន១០ ម៉ែត្រការ៉េ-បិទការមុខឥដ្ឋបន្ថែម១០ម៉ែត្រការ៉េ-ចាប់ផ្តើមធ្វើកំណាយរណ្តៅ១ម គុណ១,៥០ម គុណ០,៧០ម ស្រាវជ្រាវបន្តនៅក្រុងឥសានបុរៈ ដើម្បីមើលរចនាសម្ព័ន្ធរបស់ប្រាសាទ និង បានកាត់ស្មៅសម្អាតនៅប្រាសាទ ក្រុមសំបូរ ក្រុមប្រាសាទយាយព័ន្ធ ក្រុមដូនមោង និងក្រុមតាមុំ។

***បញ្ហាប្រឈម ៖**

-វិន័យការងារនៅមានកំរិតដោយមានការលំបាកប្រមូលផ្តុំមន្ត្រីជំនាញ។ កង្វះថវិកា ខ្វះពលករអណ្តែត នៅតាមប្រាសាទ ខ្វះការិយាល័យអភិរក្សនៅតាមប្រាសាទមួយចំនួន ខ្វះលិខិតបទដ្ឋានច្បាប់ផ្សេងៗ ក្នុងការ គ្រប់គ្រង ការប្រើប្រាស់ដីធ្លី និងសំណង់ក្នុងតំបន់ប្រាសាទបន្ទាយឆ្មារ និងតំបន់សំបូរព្រៃគុក ខ្វះមន្ត្រីក្របខណ្ឌផ្ទៃកកិច្ចការរដ្ឋបាល និងវិស្វករ។ អាជ្ញាធរមូលដ្ឋានសហការមិនបានល្អជាមួយនាយកដ្ឋាន ក្នុងការគ្រប់គ្រងការប្រើប្រាស់ដីធ្លី និងសំណង់ក្នុងតំបន់ប្រាសាទបន្ទាយឆ្មារ។

***សំណូមពរ ៖**

-ស្នើសុំថវិកាប្រចាំឆ្នាំឲ្យបានសមស្រប និងទាន់ពេលវេលាសម្រាប់គាំពារ អភិរក្ស និងជួសជុលប្រាសាទទូទាំងប្រទេស។ ស្នើសុំថវិកាប្រចាំឆ្នាំសម្រាប់ថែទាំរថយន្ត និងគ្រឿងចក្រ បម្រើឲ្យការងារគាំពារ និងអភិរក្សប្រាសាទបុរាណ។ ស្នើសុំបន្ថែមក្របខណ្ឌផ្នែកកិច្ចការរដ្ឋបាល និងវិស្វករ និងពលករអណ្តែតដាក់តាមប្រាសាទ ព្រមទាំងអាគារអភិរក្សដ្ឋាននៅតាមប្រាសាទសំខាន់ៗមួយចំនួន។

-សូមក្រសួងផ្តល់លិខិតបទដ្ឋានច្បាប់ផ្សេងៗ ស្តីពីការគ្រប់គ្រង និងការប្រើប្រាស់ដីធ្លីក្នុងតំបន់ដែលគ្រប់គ្រងដោយព្រះរាជក្រឹត្យ និងសូមឲ្យមានសិក្ខាសាលាថ្នាក់ក្រសួង ស្តីពីការគ្រប់គ្រង និងការប្រើប្រាស់ដីធ្លីក្នុងតំបន់ការពារ ដោយព្រះរាជក្រឹត្យ និងតំបន់ប្រាសាទសំខាន់ៗទៀត។

៣.២.ការងារសារមន្ទីរ ៖

មន្ត្រីជំនាញចំនួន០១រូប បានទៅចូលរួមធ្វើកំណាយស្រាវជ្រាវនៅស្តានីយ៍ណ្តាងស្តាន ខេត្តបាត់ដំបង ចំនួន៥ថ្ងៃ។ មន្ត្រីជំនាញចំនួន០២រូប ទៅចូលរួមផ្តិតសិលាចារឹក នៅមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តកំពង់ធំ និងក្រុមប្រាសាទសំបូរព្រៃគុកចំនួន០៥ថ្ងៃ និងមន្ត្រីជំនាញចំនួន០១រូប ទៅចូលរួមរៀបចំដាក់តាំងវត្ថុសិល្បៈ នៅសារមន្ទីរធម្មជាតិសកល សម្តេចតេជោ ហ៊ុន សែន ខេត្តព្រះវិហារ។ មន្ត្រីជំនាញចំនួន០២រូប ទៅចូលរួម បំពេញបេសកកម្មនៅខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ ក្នុងគម្រោងសហប្រតិបត្តិការរវាងក្រសួង វប្បធម៌ និងវិចិត្រសិល្បៈ និងមជ្ឈមណ្ឌលឯកសារកម្ពុជា ក្រោមប្រធានបទ ការរៀបចំពិព័រណ៌ស្តីពី របប កម្ពុជាប្រជាធិបតេយ្យនៅតាមបណ្តាសារមន្ទីរខេត្ត-ក្រុង និងការអភិវឌ្ឍសារមន្ទីរ។ មន្ត្រីជំនាញចំនួន០៤រូប ចុះ បេសកកម្មទៅខេត្តព្រៃវែង ដើម្បីស្រាវជ្រាវអំពីការងារសារមន្ទីរ និងពិនិត្យលើការតាំងពិព័រណ៌នៅសារមន្ទីរ ខេត្តព្រៃវែង និងចុះបេសកកម្មទៅខេត្តកំពង់ចាម ដើម្បីធ្វើបញ្ជីសារពើភណ្ឌ និងវាយតម្លៃវត្ថុសិល្បៈនៅអាស្រម ព្រឹទ្ធាចារ្យ ចាយ គីមហុង (តាងុយ) ស្ថិតនៅឃុំវាលវង់ ក្រុងកំពង់ចាម។

ក.សារមន្ទីរជាតិភ្នំពេញ ៖

-បានទទួលវត្ថុបុរាណខ្មែរចំនួន**១៣១មុខ** ក្នុងនោះមាន ៖

+វត្ថុសិល្បៈធ្វើពីថ្មចំនួន**០៧រូប** និងបំណែកចំនួន១៥បំណែក

+វត្ថុសិល្បៈធ្វើពីលោហៈធាតុចំនួន**១១៩រូប**

+វត្ថុសិល្បៈធ្វើពីស្ពាន់ចំនួន**០៣រូប** ពីដែកចំនួន**០១រូប** និងពីក្រដាសចំនួន**០១រូប** ។

-**ភ្ញៀវចូលទស្សនាសារមន្ទីរជាតិ** មានគណៈប្រតិភូជាន់ខ្ពស់ជាតិ-អន្តរជាតិ ភ្ញៀវជាតិ-អន្តរជាតិ សិក្ខាកាម សិស្ស និស្សិត ព្រះសង្ឃ សរុបមានចំនួន **១៥៤.០៤២នាក់** ក្នុងនោះមាន ៖

*ភ្ញៀវជាតិទិញសំបុត្រចំនួន **២៨.០០២ នាក់** ទទួលបានថវិកាចំនួន **១០.១៥០.៩៥០រៀល**

*ភ្ញៀវអន្តរជាតិទិញសំបុត្រចំនួន **១០៤.០៦៧ នាក់** ទទួលបានថវិកា **៣៥៨.៦៥៩ដុល្លាអាមេរិក**

*ភ្ញៀវចូលឥតបង់ថ្លៃចំនួន **២១.៩៧៣ នាក់**

-ជួសជុលរូបចម្លាក់បាន**១៥៤រូប** និងធ្វើបញ្ជីវត្ថុសិល្បៈចូលថ្មីបាន**៦៣រូប** ។

ខ.សារមន្ទីរឧក្រឹដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ៖

-ភ្ញៀវជាតិ-អន្តរជាតិ ព្រះសង្ឃ សិស្ស និស្សិតចូលទស្សនាចំនួន**១៨៥.៣៧៧នាក់** ក្នុងនោះភ្ញៀវអន្តរជាតិចំនួន **១៤.៣៧៨នាក់**។ ការងាររដ្ឋបាលបានរៀបចំលិខិតបទដ្ឋានឱ្យមានរបៀប មានសណ្តាប់ធ្នាប់ បានវិចខ្ចប់ឯកសារចំនួន១.៣៥០កញ្ចប់ ស្តេននេហ្គាទីវ (Negative) ហ្វីលបាន១.៥០០សន្លឹក និងបានជួសជុលកែលម្អហេដ្ឋារចនាសម្ព័ន្ធក្នុងបរិវេណសារមន្ទីរ។

***ផ្នែកវប្បធម៌ ៖**

-កង្វះថវិកា កង្វះធនធានមនុស្ស

-នៅរដូវវស្សាទឹកលិចខ្លាំងក្នុងលេណគ្រឹះបណ្តាលឲ្យប៉ះពាល់ដល់វត្ថុបុរាណមួយចំនួន ពិសេសវត្ថុពីលោហធាតុ និងវាយនភណ្ឌ។

-កង្វះខាតទីតាំង និងសម្ភារៈសម្រាប់បង្កើតរោងជាងអភិរក្ស និងជួសជុលវាយនភណ្ឌ ជាពិសេសសំពត់សូត្រ និងផ្នាំងគំនូរមួយចំនួនកំពុងប្រឈមនឹងការពុកផុយ

-វគ្គបណ្តុះបណ្តាលស្តីពីការងារចុះបញ្ជីសារពើភណ្ឌ ការងារជំនាញអភិរក្សវត្ថុសិល្បៈ មគ្គុទ្ទេសក៍ការពង្រឹងសមត្ថភាពបច្ចេកទេស និងការងារជួសជុលវត្ថុសិល្បៈ ទៅដល់មន្ត្រីខេត្ត។

-ការរៀបចំឯកសារច្បាប់គតិយុត្តស្តីពីការគ្រប់គ្រងសារមន្ទីរ បែបបទស្នើសុំបើកសារមន្ទីរ ឬបិទសារមន្ទីរ ។

***សំណូមពរ ៖**

-សុំបន្ថែមធនធានមនុស្សទៅលើតម្រូវការរបស់នាយកដ្ឋាន

-សុំឲ្យក្រសួងជួយគាំទ្រលើការងារផែនការអាទិភាពរបស់អង្គភាព ។

គ.មណ្ឌលវត្តភ្នំ ៖

-ភ្ញៀវទេសចរណ៍បរទេសចូលទស្សនាមាន: **២៨៦.០៥៥នាក់** ក្នុងនោះបរទេស**១៥០.០០០នាក់** ។

ឃ.មណ្ឌលជើងឯក ៖

-ភ្ញៀវទេសចរណ៍បរទេសចូលទស្សនាមាន: **១៨១.៣៣៩នាក់** ក្នុងនោះបរទេស**៤២.៧៩៣នាក់** ។

៣.៣.ការងារបុរាណវិទ្យា និងបុរេប្រវត្តិវិទ្យា ៖

-បានបញ្ជូនមន្ត្រីជំនាញចំនួន០២នាក់ ចូលរួមសហការជាមួយវិទ្យាស្ថានជាតិណារ៉ា នៃប្រទេសជប៉ុន សិក្សាស្រាវជ្រាវ និងអង្កេតទីតាំងស្ថានីយនៅស្រុកលង្វែក ខេត្តកំពង់ឆ្នាំង។ មន្ត្រីជំនាញចំនួន០១នាក់ ចូលរួម សហការស្រាវជ្រាវស្ថានីយបញ្ចុះសព នៅភ្នំខ្នងពើង និងភ្នំប៉ៃល ស្រុកថ្មបាំង ខេត្តកោះកុង។ មន្ត្រីជំនាញ ចំនួន០៣នាក់ ផ្លាស់ប្តូរវេនគ្នាចុះទៅសិក្សាស្រាវជ្រាវ និងផ្ទៀងផ្ទាត់ស្ថានីយបុរាណនៅស្រុកបាធាយ ខេត្ត កំពង់ចាម។ បញ្ជូនមន្ត្រីជំនាញចំនួន០២នាក់ ចូលរួមសហការធ្វើកំណាយជាមួយវិទ្យាស្ថានស្រាវជ្រាវ ដើម្បី ការអភិវឌ្ឍន៍ (បេសកកម្មស្រាវជ្រាវបុរេប្រវត្តិសាស្ត្រកម្ពុជា-បារាំង) ធ្វើកំណាយនៅស្ថានីយឈ្នាងស្ពាន ស្រុករតនមណ្ឌល ខេត្តបាត់ដំបង។ បញ្ជូនមន្ត្រីជំនាញចំនួន០៣នាក់ ចុះទៅសិក្សាស្រាវជ្រាវ ផ្ទៀងផ្ទាត់ ស្ថានីយ៍បុរាណ និងរមណីយដ្ឋានប្រវត្តិសាស្ត្រនៅស្រុកសំបូរ ខេត្តក្រចេះ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ និងស្រុកស្ទឹងសែន ខេត្តកំពង់ធំ និងសហការជាមួយសកលវិទ្យាល័យស៊ីដនី ប្រទេសអូស្ត្រាលី ចុះសិក្សាស្រាវជ្រាវឧស្សាហកម្មដែក នៅខេត្តព្រះវិហារ

-បានសហការជាមួយមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកណ្តាល ចុះទៅបោះបង្គោលដែនការពារស្ថានីយ បុរាណ នៅស្រុកកោះធំ និងស្រុកសំអោងទង ខេត្តកំពង់ស្ពឺ

-បានសហការជាមួយមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តព្រៃវែង ចុះទៅបោះបង្គោលដែនការពារស្ថានីយ បុរាណ នៅក្រុងព្រៃវែង ខេត្តព្រៃវែង

-បានសហការជាមួយវិទ្យាស្ថានស្រាវជ្រាវសម្បត្តិវប្បធម៌ ណារ៉ា ប្រទេសជប៉ុន ធ្វើបទបង្ហាញស្តីពីលទ្ធផលស្រាវជ្រាវធ្វើកំណាយនៅភូមិក្រាំងគរ ខេត្តកំពង់ឆ្នាំង នៅទីស្តីការក្រសួង

-សហការជាមួយសកលវិទ្យាល័យអូតាហ្គោ ប្រទេសញ៉ូសេលែន និងរាជបណ្ឌិតសភា ធ្វើបទបង្ហាញស្តីពីលទ្ធផលស្រាវជ្រាវថ្មីៗលើវិស័យបុរាណវិទ្យានៅស្ថានីយភ្នំខ្នងពាង ខេត្តកោះកុង និងស្ថានីយ៍ជើងឯក (ឡបុរាណ) នៅរាជធានីភ្នំពេញ នៅទីស្តីការក្រសួង

-បានត្រៀមរៀបចំលិខិតបទដ្ឋានប្រកាសបញ្ចូលស្ថានីយបុរាណ នៅខេត្តកំពតជាស្ថាពរ ទៅជាសម្បត្តិ បេតិកភណ្ឌវប្បធម៌ជាតិ និងបន្តរៀបចំបញ្ចូលស្ថានីយព្រៃបាសាក់-ប្រាសាទជីហ៊ូ និងចេតិយភ្នំយ៉ាតចូលជា សម្បត្តិបេតិកភណ្ឌជាតិ ។

នាយកដ្ឋានបុរាណវិទ្យា និងបុរេប្រវត្តិវិទ្យា សម្រេចបានលទ្ធផលល្អប្រសើរក្នុងការងារវិស័យវប្បធម៌ពិសេសផ្នែកគ្រប់គ្រងដែនដីបុរាណវិទ្យា និងកិច្ចសហការស្រាវជ្រាវជាមួយស្ថាប័នជាតិ និងអន្តរជាតិ។ លទ្ធផល សម្រេចបានជារំជួមានគឺ ៖

-ចុះពិនិត្យ និងផ្ទៀងផ្ទាត់ស្ថានីយបុរាណនៅតាមបណ្តាខេត្តចំនួន០៦ខេត្ត

-បើកសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីលទ្ធផលស្រាវជ្រាវបុរាណវិទ្យាដល់មន្ត្រីរាជការក្រោមឱវាទក្រសួង

-ចុះផ្សព្វផ្សាយ អប់រំ និងអភិរក្សស្ថានីយបុរាណនៅខេត្តកោះកុង-កំពង់ឆ្នាំង-កណ្តាល-កំពង់ស្ពឺ និងខេត្តតាកែវ។

***បញ្ហាប្រឈម ៖**

-សកម្មភាពឈូសឆាយដីធ្វើការអភិវឌ្ឍកំពុងមានការកើនឡើង ក៏ដូចជាខ្វះការជួយអន្តរាគមន៍ និងធ្វើចំណាត់ការឲ្យបានទាន់ពេលវេលាពីថ្នាក់ដឹកនាំក្រសួង ក៏ដូចជាអាជ្ញាធរដែនដី ទាំងនេះគឺជាផលប៉ះពាល់យ៉ាងខ្លាំងដល់ស្ថានីយបុរាណដែលមាននៅលើទឹក នៃព្រះរាជាណាចក្រកម្ពុជា

-ចរន្តការងារឯកសារលិខិតស្នាមមានការយឺតយ៉ាវខ្លាំង ចាប់ពីអគ្គនាយកដ្ឋានបេតិកភណ្ឌ រហូតដល់ថ្នាក់ដឹកនាំក្រសួង និងធ្វើការចំណាត់ការលិខិតមិនបានត្រឹមត្រូវដល់នាយកដ្ឋានសាមីជាអ្នកអនុវត្ត

-ខ្វះកញ្ចប់ថវិកាបេសកកម្ម ដើម្បីចុះទៅទប់ស្កាត់ ដោះស្រាយការឈូសឆាយស្ថានីយទាន់ពេលវេលា

-ខ្វះម៉ាស៊ីនព្រីនធ័រកូល័រ និងម៉ាស៊ីនថតចម្លងឲ្យបានសមរម្យ ព្រមទាំងសម្ភារៈប្រើប្រាស់ក្នុងការិយាល័យ រដ្ឋបាល ។

៣.៤.ការងារបុរាណវត្ថុ ៖

-ការងារទប់ស្កាត់ការចរាចរបុរាណវត្ថុខុសច្បាប់៖ បានសហការជាមួយនគរបាលការពារបេតិកភណ្ឌ និងសាលាដំបូងរាជធានីភ្នំពេញ ចុះឆែកឆេររុករកនៅផ្ទះលក់វត្ថុអនុស្សាវរីយ៍លេខ១២៤ និង៤៥០ សង្កាត់ទួលទំពូង១ ខណ្ឌចំការមន រាជធានីភ្នំពេញ ពាក់ព័ន្ធករណីស្វែងរកវត្ថុបុរាណមួយចំនួនដែលបានបាត់នៅវត្តរាជបូព៌ ភូមិវត្តបូព៌ សង្កាត់សាលាកម្រើក ក្រុងសៀមរាប ខេត្តសៀមរាប។ ការឆែកឆេរនេះយើងបានពិនិត្យឃើញមានវត្ថុចំនួន០៨ ដូចនឹងវត្ថុដែលបានបាត់នៅវត្តរាជបូព៌ ហើយវត្ថុទាំងនេះត្រូវបានរក្សាទុកជាបណ្តោះអាសន្ននៅសារមន្ទីរជាតិ

-បានចែកជូនតារាងស្រង់ព័ត៌មានបុរាណវត្ថុក្រៅឃ្លាំង (តាមប្រាសាទ ទីទួលបុរាណ វត្តអារាម និងទីសាធារណៈ) ដល់មន្ទីរាជធានី-ខេត្ត។ ក្នុងនោះបានទទួលព័ត៌មានត្រឡប់មកវិញមានខេត្តចំនួន០២គឺ ខេត្តស្ទឹងត្រែង និងខេត្តកំពង់ចាម

-បានសហការជាមួយនាយកដ្ឋានសារមន្ទីរ ចុះយកគោបុរាណពីខេត្តកំពង់ធំមកជូសជុល និងគ្រោងយកទៅរក្សាទុកនៅសារមន្ទីរសម្តេចតេជោ ខេត្តព្រះវិហារ

-ការងារចុះបញ្ជីសារពើភណ្ឌបុរាណវត្ថុ៖ បានសហការជាមួយនាយកដ្ឋានសារមន្ទីរ ចុះធ្វើបញ្ជីសារពើភណ្ឌវត្ថុបុរាណ នៅវត្តរាជបូព៌ និងវត្តជីក្រែង ក្នុងខេត្តសៀមរាប ដោយពិនិត្យឃើញថា វត្តទាំងពីរនេះមានវត្ថុបុរាណច្រើន។ ការចុះធ្វើបញ្ជីសារពើភណ្ឌនេះ គឺបានដំណើរការមួយរយៈ និងគ្រោងបន្តបញ្ចប់ដោយចំនួនវត្ថុបុរាណនៅវត្តទាំងពីរនេះច្រើន ចំណែកថវិកាបេសកកម្មមានកម្រិត ដូចនេះលទ្ធផលនៃការចុះធ្វើបញ្ជីសារពើភណ្ឌវត្ថុបុរាណគឺអនុវត្តបានប្រហែល៣០ភាគរយ

-ការងារប្រមូលបុរាណវត្ថុតាមបណ្តាខេត្ត ៖

+ខេត្តស្ទឹងត្រែង ៖ ព្រះពុទ្ធរូបពីមាស ប្រាក់ និងឈើចំនួន៦៦អង្គ និងជើងពានស្ពាន់ចំនួន០១ (រកឃើញនៅស្រុកថាឡាបរិវ៉ាត់)

+ខេត្តបន្ទាយមានជ័យ ៖ បុរាណវត្ថុអំពីលោហៈចំនួន០៣

-ករណីលួចបុរាណវត្ថុតាមបណ្តាខេត្ត ៖

+ខេត្តសៀមរាប ៖ បាត់បុរាណវត្ថុចំនួន២៩ នៅវត្តរាជបូព៌ ភូមិវត្តបូព៌ សង្កាត់សាលាកម្រើក ក្រុងសៀមរាប

+ខេត្តកំពង់ចាម ៖ បាត់រូបបដិមាចំនួន០១ នៅស្រុកព្រៃឈរ

ការងារផ្តល់សេវាពិនិត្យវត្ថុសិល្បៈនាំចេញ-នាំចូល ទទួលបាន ៖ ចំនួនសរុប**៦.០៣៧រូប** ទទួលថវិកាចំនួន **៥៨.១៣៩.០០០រៀល** ក្នុងនោះ ៖

+នាំចេញទៅបរទេស ៖ វត្ថុសិល្បៈថ្មីចំនួន**៥.៥១១រូប** ស្មើនឹង**៣៦.១៧១.០០០រៀល** វត្ថុសិល្បៈ ចម្លងដូចចំនួន**៣៦០រូប** ស្មើនឹង**១០.៧០៤.០០០រៀល**

+នាំចូលពីបរទេស ៖ ចំនួន**១៦៦រូប** ស្មើនឹង**១.២៦៤.០០០រៀល**

+នៅខេត្តសៀមរាប ៖ ចំនួនរូបសរុប**១៦៧រូប** (រូបនាំចេញពីខេត្តសៀមរាប) ទឹកប្រាក់ចំនួន **២.១៦០.០០០រៀល**។

***ចញ្ហាប្រឈម ៖**

-ការងារធ្វើបញ្ជីសារពើភណ្ឌបុរាណវត្ថុ និងការប្រមូលវត្ថុបុរាណពីកន្លែងអសុវត្ថិភាព មកទីសុវត្ថិភាព នៅមិនទាន់ដំណើរការបាន

-សមត្ថភាពជំនាញនៅមានកម្រិត ការធ្វើកោសល្យវិច័យរូប ការកត់ត្រាព័ត៌មានរូប

-ការបណ្តុះបណ្តាលការអនុវត្តជំនាញ និងពង្រឹងការអនុវត្តច្បាប់ដល់មន្ត្រីទទួលបន្ទុកតាមបណ្តារាជធានី-ខេត្ត នៅមានកម្រិត បើធៀបនឹងតម្រូវការការងារជាក់ស្តែង

-ការផ្សព្វផ្សាយច្បាប់ ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ជាលក្ខណៈសកលដល់មហាជននៅមានកម្រិត មិនទាន់ទូលំទូលាយ

-លទ្ធភាពថវិកានៅមានកម្រិត ពុំធានាដល់តម្រូវការការងារជាក់ស្តែង ។

***សំណូមពរ ៖**

-ស្នើសុំមន្ត្រីក្របខណ្ឌថ្មី

-ស្នើដល់គ្រប់មន្ទីរជួយបំពេញតារាងផ្តល់ព័ត៌មានមកនាយកដ្ឋានបុរាណវត្ថុឲ្យបានឆាប់ ។

៤-ការងារបេតិកភណ្ឌអរូបី ៖

៤.១.ការងារអភិវឌ្ឍវប្បធម៌ ៖

-បានបន្តស្រាវជ្រាវចងក្រងល្បែងប្រជាប្រិយខ្មែរ ដោយបានរកឃើញថ្មីបន្ថែមបាន០៥ចំណងជើង

-បានបន្តស្រាវជ្រាវអំពីប្រពៃណីទំនៀមទម្លាប់ខ្មែរក្នុងពិធីបុណ្យដារលាន និងកំពុងប្រមូលឯកសារ ដើម្បីរៀបចំសរសេរជាអត្ថបទ

-បានចុះទៅទំនាក់ទំនងជាមួយមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីស្រង់ស្ថិតិអង្គការ សមាគមទាក់ទងនឹងវិស័យ វប្បធម៌ប្រចាំឆ្នាំ២០១៣

-បានត្រួតពិនិត្យឯកសារល្បែងប្រជាប្រិយខ្មែរលើអក្ខរាវិរុទ្ធ ពាក្យពេចន៍ ខ្លឹមសារ ដើម្បីរៀបចំបោះពុម្ពជាសៀវភៅ ក្នុងឆ្នាំ២០១៤

-បានរៀបចំស្តង់សម្រាប់តាំងពិព័រណ៌វប្បធម៌ និងតុបតែងលម្អហ្វុងក្នុងពិធីបើកសន្និបាតក្រសួង នៅថ្ងៃទី២២ មករា ឆ្នាំ២០១៣ ទីស្តីការក្រសួង

-បានសិក្សាបន្ត ស្តីពីពិធីត្រណមនៅពេលខ្មោចស្លាប់តៃហោង មិនឱ្យយកសពចូលភូមិស្រុក (ស្លាប់ដោយសារក្របីវ៉ធ ធ្លាក់ពីលើដើមឈើ ឬ ខ្លាខាំ) របស់ជនជាតិព្នង

-បានសិក្សាពីពិធីបុណ្យផ្សេងៗ ពិធីសែនព្រេន ពិធីរៀបអាពាហ៍ពិពាហ៍របស់បងប្អូនជនជាតិក្រោលនៅខេត្តមណ្ឌលគីរី

-បានសិក្សាបន្តពីពិធីស្តីដណ្តឹងកូនក្រមុំជនជាតិព្នង នៅខេត្តមណ្ឌលគីរី និងជនជាតិគ្រឹងខេត្តរតនគីរី។

***ចញ្ហាប្រឈម ៖**

-ការស្រង់ស្ថិតិប្រចាំឆ្នាំអំពីចំនួនអង្គការ សមាគម មិនបានចុះតាមដានជាក់ស្តែងសុក្រឹតនៅឡើយ

-ការរៀបចំឯកសារគោលការណ៍អំពីបង្កើត គ្រប់គ្រងភូមិ និងមណ្ឌលវប្បធម៌មិនទាន់អនុវត្តបាន

-ខ្វះមន្ត្រីជំនាញក្នុងការចុះស្រាវជ្រាវវប្បធម៌ជនជាតិភាគតិច ។

***សំណូមពរ ៖**

-ស្នើសុំមន្ត្រីក្របខណ្ឌថ្មី សម្រាប់ការងារគ្រប់គ្រងរដ្ឋបាល

-ស្នើសុំសម្ភារ:ការិយាល័យបម្រើឲ្យបានគ្រប់គ្រាន់ ។

៤.២.ការងារសិល្ប:ភាពយន្ត និងផ្សព្វផ្សាយវប្បធម៌ ៖

-បានរៀបចំមហោស្រពភាពយន្តកូរ៉ែ-សប្តាហ៍ភាពយន្តចិន នៅកម្ពុជា និងបើកមហោស្រពភាពយន្តអន្តរជាតិលើកទី៤ នៅកម្ពុជា។ ចូលរួមកិច្ចប្រជុំសមាគមភាពយន្តអាស៊ីនៅប៊ូសាន កូរ៉ែខាងត្បូង-កិច្ចប្រជុំភាពយន្តអាស៊ានលើកទី១ នៅហ្វីលីពីន-កិច្ចប្រជុំភាពយន្តអាស៊ានលើកទី២ នៅហ្វ៊ូហីន ប្រទេសថៃ និងចូលរួមពិព័រណ៌ភាពយន្ត និងសន្និសីទអន្តរជាតិ នៅហ្វីលីពីន ។

-បានផ្តល់អាជ្ញាប័ណ្ណថ្មីសុំធ្វើអាជីវកម្មភាពយន្ត-វីដេអូចំនួន១១ច្បាប់

-ថតសកម្មភាពការងារក្រសួងបាន៨៥លើក និងបានតម្លើងឯកសារវីដេអូចំនួន៤២ចំណងជើង ក្នុងនោះ វីដេអូនៃការសម្តែងសិល្ប:សៀក និងរបាំ២៥ចំណងជើង

-ចុះបញ្ជីសុំផលិតខាវ៉ាអូខេខ្មែរបាន៨៣លេខ វីដេអូរឿងខ្មែរ (០១ដុំចប់)បាន០៩ចំណងជើង និងស្ប៉ាតខ្លីៗបាន១០ចំណងជើង

-ផ្តល់ទិដ្ឋាការខាវ៉ាអូខេខ្មែរបាន៨៥លេខ វីដេអូរឿងខ្មែរ(០១ដុំចប់)បាន២១ចំណងជើង ស្ប៉ាតផ្សាយពាណិជ្ជកម្មបាន០៥ចំណងជើង

-ផ្តល់ទិដ្ឋាការវីដេអូរឿងបរទេសបាន១១៤ចំណងជើង និងទទួលចុះបញ្ជីកាស្សែតនាំចូលពីបរទេសបាន២៨១ចំណងជើង

-ការងារទទួល និងសម្របសម្រួលថតភាពយន្តបរទេស បានអនុញ្ញាតថតភាពយន្តឯកសារ និងភាពយន្តរឿងវែងរបស់ផលិតកម្មបរទេសមានចំនួន១៤ផលិតកម្ម

-មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានីភ្នំពេញ សហការជាមួយនាយកដ្ឋានសន្តិសុខផ្ទៃក្នុងនៃក្រសួងមហាផ្ទៃ និងមន្ទីរខេត្តទាំង២៣ បានសហការជាមួយគណៈកម្មការអន្តរមន្ទីរ ចុះត្រួតពិនិត្យកន្លែងជួល-លក់ថាស និងដកហូតបានថាសខុសច្បាប់សរុបចំនួន២៧.៩៣៧បន្ទះ និងរឹបអូសបានសម្ភារៈមួយចំនួនទៀត ។

រយៈពេលមួយឆ្នាំនេះ នាយកដ្ឋានបានទទួលថវិកាពីការផ្តល់សេវាលើអាជីវកម្មភាពយន្ត-វីដេអូសរុបចំនួន**៦៩.៩៤៥.០០០រៀល** ដោយបង់ចូលថវិការដ្ឋ ។

***ចញ្ចាប្រឈម ៖**

-ធនធានមនុស្សខ្វះខាតអ្នកជំនាញបច្ចេកទេសគ្រប់ផ្នែក

-ការឆ្លើយតបចំពោះការស្នើសុំថតភាពយន្តបរទេស មិនទាន់អនុវត្តបានតាមការកំណត់

-បទល្មើសលួចចម្លង ចែកចាយ ផលិតផលភាពយន្តនៅតែបន្តកើតមាន

-ការចរាចរចែកផ្សាយ ផ្សព្វផ្សាយផលិតផលភាពយន្ត ពុំមានការអនុញ្ញាតពីក្រសួង នៅតែមានធ្វើសកម្មភាព

-ការប្រកួតប្រជែងនៅលើទីផ្សាររវាងផលិតផលភាពយន្តក្នុងស្រុក និងភាពយន្តបរទេស (ក្នុងស្រុកគុណភាពអន់តែតម្លៃខ្ពស់) ។

***សំណូមពរ ៖**

-ការបែងចែកកញ្ចប់ថវិកាប្រចាំឆ្នាំ គួរតម្រូវតាមការងារជាក់ស្តែង

-ស្នើសុំមន្ត្រីក្របខណ្ឌថ្មី

-សូមក្រសួងជម្រុញអនុក្រឹត្យ ស្តីពីអង្គភាពគ្រប់គ្រងសិទ្ធិរួមឲ្យបានឆាប់

-សូមក្រសួងពិភាក្សារវាងក្រសួងព័ត៌មាន អំពីការនាំចូល ចែកចាយ និងផ្សព្វផ្សាយផលិតផលភាពយន្តតាមស្ថានីយ៍ទូរទស្សន៍ តើសមត្ថកិច្ចរបស់ស្ថាប័នណាជាអ្នកទទួលខុសត្រូវ ។

៥.៣.ការងារសិល្បៈទស្សនីយភាព ៖

-ការប្រគុំតន្ត្រី និងសម្តែងសិល្បៈ (មហាជន និងអាជីព) សរុបចំនួន១.៨២២លើក ក្នុងនោះនាយកដ្ឋានសិល្បៈសម្តែងក្នុងស្រុកបាន៩២លើក និងក្រៅប្រទេសបាន០៨ប្រទេស សម្តែងបាន១៩លើក

-លោកគ្រូ អ្នកគ្រូនៃនាយកដ្ឋានសិល្បៈទស្សនីយភាព បានចុះជួយបណ្តុះបណ្តាល និងពង្រឹងជំនាញសិល្បៈទស្សនីយភាព នៅតាមបណ្តាគ្រឹះស្ថានអប់រំ អង្គការ និង សមាគមន៍សិល្បៈនានារួមមាន ៖

+អ្នកគ្រូរបាំ និងចម្រៀងបុរាណ០៤រូប បង្ហាត់ នៅមហាវិទ្យាល័យសិល្បៈនាដសាស្ត្រ

+សិល្បករបាំប្រពៃណី០២រូប បង្ហាត់បច្ចេកទេសល្ខោនខោល នៅមហាវិទ្យាល័យសិល្បៈនាដសាស្ត្រ

+តន្ត្រីករបុរាណ០១រូប បង្ហាត់សិល្បៈដល់កុមារកំព្រាខេត្តកំពត

+លោកគ្រូ០១រូប បង្ហាត់ជំនាញអាចារ្យ នៅក្រសួងធម្មការ និង សាសនា

+លោកគ្រូ អ្នកគ្រូ របាំ០៩រូប បង្ហាត់ល្ខោន និងរបាំដល់និស្សិតសកលវិទ្យាល័យកម្ពុជារៀងរាល់ថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ

+លោកគ្រូ អ្នកគ្រូរបាំប្រពៃណី របាំបុរាណ និងល្ខោនចំនួន០៧រូប បង្ហាត់បង្រៀនសិស្សនៅសាលាមធ្យមវិចិត្រសិល្បៈ

+លោកគ្រូ អ្នកគ្រូរបាំបុរាណ និងតន្ត្រីបុរាណចំនួន០២រូប បង្ហាត់បង្រៀនសិស្សខ្មែរឥស្លាម នៅគីឡូម៉ែត្រលេខ៧

+លោកគ្រូ អ្នកគ្រូ បង្ហាត់បង្រៀនក្រុមយុវជន នៅនាយកដ្ឋានសិល្បៈទស្សនីយភាព រៀងរាល់ថ្ងៃសៅរ៍ និង ថ្ងៃអាទិត្យសម្រាប់ចូលរួមកម្មវិធីសិល្បៈអង្គរសង្ក្រាន នៅខេត្តសៀមរាប

-ការងារជំនាញនៅតាមផ្នែកនីមួយៗបានបន្តហាត់សម: ល្ខោនបាសាក់-យីកេ-របាំប្រពៃណី-របាំបុរាណ ស្បែកតូច-ភ្លេងពិណពាទ្យ-សៀក-អាយ៉ៃ-ចាប៉ី និងហាត់សមតន្ត្រីសម័យ ដើម្បីចេញសម្តែងបំរើព្រឹត្តិការណ៍ ជាតិ-អន្តរជាតិ និងក្នុងពិធីបុណ្យផ្សេងៗ។ ការងារសម្តែងបម្រើព្រឹត្តិការណ៍ធំៗដែលរាជរដ្ឋាភិបាលដាក់ចុះគឺ បានតម្លើងស្នាដៃចំនួន៧ស្នាដៃមាន របាំ-រឿង ដោយមានសិល្បករចូលរួមសម្តែងជាច្រើននាក់ដូចជា ៖

+របាំអបអរសាទរទិវាបុណ្យជាតិ ៧ មករា

+រឿង ព្រះថោង នាងនាគ សម្តែងក្នុងកម្មវិធីអង្គរសង្ក្រាន្ត នៅខេត្តសៀមរាប

+របាំអបអរសាទរ ការប្រជុំការងារបេតិកភណ្ឌនៅរាជធានីភ្នំពេញ និងខេត្តសៀមរាប

+រឿង រាមកេរ្តិ៍ សម្តែងនៅមហោស្រពប្រទេសឥណ្ឌូនេស៊ី

+របាំអបអរសាទរ បុណ្យឯករាជ្យជាតិ

+របាំអបអរសាទរខួបទី៣៥ រណសិរ្សសាមគ្គីអភិវឌ្ឍមាតុភូមិកម្ពុជា

+របាំនេសាទសមុទ្រ សម្តែងបុណ្យសមុទ្រ នៅខេត្តកែប។

***ចញ្ហាប្រឈម ៖**

-ការចុះធ្វើបឋកថាអំពីសិល្បៈវប្បធម៌នៅតាមគ្រឹះស្ថានសិក្សា អង្គការ សង្គមស៊ីវិលមិនទាន់អនុវត្តបានទូលំទូលាយ

-ពុំបានអនុវត្តសម្រេចតាមគម្រោងផែនការរបស់នាយកដ្ឋាន ប៉ុន្តែបានបំពេញការងាររបស់ខ្លួនលើការងារជាក់ស្តែង ដែលរាជរដ្ឋាភិបាល និងក្រសួងបានដាក់ចុះគឺ សិល្បករ សិល្បការិនី បានចូលរួមសម្តែងជាច្រើនរយនាក់បម្រើក្នុងព្រឹត្តិការណ៍ធំៗ

-សិល្បករមានវ័យកាន់តែចាស់ មិនអាចបម្រើសកម្មភាពបាន និងចូលនិវត្តន៍បាន ។

***សំណូមពរ ៖**

-សុំគ្រូមានវ័យក្មេងមកនាយកដ្ឋាន និងសុំឲ្យសិល្បករមានវ័យចាស់ទៅបង្រៀននៅសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ

-សូមស្នើសុំមន្ត្រីជាប់កិច្ចសន្យាបន្ថែម ។

៤.៤.ការងារសិល្បៈសួនរូប និងសិល្បៈសិប្បកម្ម ៖

-ចូលរួមពិភាក្សាការបង្កើតទម្រង់ពុម្ពគម្រូសម្រាប់ចម្លាក់ពុទ្ធបដិមាករ នៅក្រសួងធម្មការ និងសាសនា

-សិក្សាស្រាវជ្រាវ និងប្រមូលផ្តុំក្បាច់ចម្លាក់ខ្មែរភាគ២ (ជំហានទី១)

-ចាប់ផ្តើមរៀបចំប្រមូលផ្តុំ

និងបញ្ចប់ចងក្រងឯកសារសម្រាប់រៀបចំមហោស្រពជាតិគំនូរវិចិត្រកម្មស្តីពី "ប្រាសាទ ព្រះវិហារ"

-ចាប់ផ្តើមស្រាវជ្រាវសម្ភារៈប្រើប្រាស់របស់ប្រជាពលរដ្ឋខ្មែរភាគ២ (ជំហានទី១)

-ចូលរួមពិភាក្សាការងារ ស្តីពីក្រុមប្រឹក្សាសូត្រកម្ពុជា លើកទី៣ នៅក្រសួងពាណិជ្ជកម្ម

-ចូលរួមសិក្ខាសាលា ស្តីពីសិល្បៈគំនូរ នៅសាធារណរដ្ឋសង្គមនិយមវៀតណាម

-រៀបចំបើកមហោស្រពគំនូរវិចិត្រកម្ម ស្តីពីប្រាសាទព្រះវិហារ (នៅខែមករា ឆ្នាំ២០១៤) ។

***ចញ្ហាប្រឈម ៖**

-មិនបានអនុវត្តការផ្សព្វផ្សាយសេចក្តីណែនាំ០១ សណាន និងការចុះធ្វើបទបង្ហាញ ស្តីពីអត្តសញ្ញាណចម្លាក់ខ្មែរ និងផ្សព្វផ្សាយកម្មវិធីចុះបញ្ជីសារពើភណ្ឌវប្បធម៌អរូបី និងការចុះបំពាក់បំប៉នក្បួនខ្នាតចម្លាក់នៅ ខេត្តពោធិ៍សាត់ និងឧត្តរមានជ័យ ដែលបញ្ហានេះពុំមានថវិកា។

***សំណូមពរ ៖**

-ស្នើសុំថ្នាក់ដឹកនាំក្រសួងមេត្តាជួយជម្រុញដល់គ្រប់មន្ទីរាជធានី-ខេត្ត ឲ្យចូលរួមចែមទៀតក្នុងសកម្មភាព ដូចជាចូលរួមមហោស្រពសិល្បៈស្នូរឲ្យជុសជុល ។

៤.៥.ការងារសៀវភៅ ការអាន ៖

-បានរៀបរៀងបោះពុម្ពសៀវភៅអនុសាសន៍របស់ សម្តេចតេជោ និងសៀវភៅទិវាវប្បធម៌ជាតិ៣ មីនា ២០១៣

-បាននឹងកំពុងទទួលស្នាដៃប្រឡងតែងនិពន្ធប្រលោមលោក-កំណាព្យរឿង ប្រចាំឆ្នាំ២០១៣

-បានឆ្លងអត្ថបទទស្សនាវដ្តីលេខ២០-២១ សម្រាប់បោះពុម្ព

-បានរៀបចំពិធីតាំងពិព័រណ៌សៀវភៅថ្នាក់ជាតិ នៅបណ្ណាល័យជាតិ រយៈពេល០៣ថ្ងៃ មានមហាជនចូលទស្សនាប្រមាណជាង៥.០០០នាក់ ។

***បណ្ណាល័យជាតិ ៖**

-ភ្ញៀវជាតិ-អន្តរជាតិចូលអានមានចំនួន: ៥.៣៩៥នាក់

-បានទទួលសៀវភៅពីស្ថាប័ននានា និងអង្គការក្រៅរដ្ឋាភិបាល (សៀវភៅគ្រប់ភាសា) ចំនួន២.៧៣២ក្បាល

-អ្នកសិក្សាស្រាវជ្រាវបានខ្ចីសៀវភៅយកទៅអានចំនួន៣.២៨៥ក្បាល (ភាសាខ្មែរ-ភាសាបរទេស)

-បានទទួលកាសែត (បរទេស-ខ្មែរ) ចំនួន៣.៥៤០ច្បាប់ និងទស្សនាវដ្តីផ្សេងៗ និងព្រឹត្តិប័ត្របរទេសចំនួន២.៤៩២ក្បាល

-បានចែកលេខ ISBN ដល់អ្នកបោះពុម្ពចំនួន៦៣៩លេខ

-ធ្វើកាតាឡុកទស្សនាវដ្តីខ្មែរបញ្ចូលក្នុងកំព្យូទ័រចំនួន២៩៧ចំណងជើង

-បានធ្វើកាតាឡុកសៀវភៅគ្រប់ប្រភេទបញ្ចូលក្នុងកុំព្យូទ័របាន១.២២០ចំណងជើង

-ធ្វើកាតាឡុកទស្សនាវដ្តីចាស់ៗ ខ្មែរ បញ្ចូលក្នុងកំព្យូទ័រចំនួន៦០៩ចំណងជើង

-តម្កល់សៀវភៅចំនួន៤៨០ចំណងជើង ស្តេនសៀវភៅចាស់ចំនួន២៩៦ក្បាល និងដាក់ក្របសៀវភៅចំនួន៧៦០ក្បាល។

***ចញ្ហាប្រឈម ៖**

-ពុំមានថវិកាសម្រាប់បោះពុម្ពទស្សនាវដ្តីក្រសួង

-រថយន្តបណ្ណាល័យចល័តខូច ចាស់ពេកមិនអាចដំណើការបាន

-ខ្វះធនធានមនុស្ស បម្រើសកម្មភាពបណ្ណាល័យជាតិ ។

***សំណូមពរ ៖**

-ស្នើសុំមន្ត្រីក្របខណ្ឌថ្មីចំនួន០៣រូប (ព័ត៌មានវិទ្យា០១រូប ភាសាអង់គ្លេស០១រូប និងភាសាបារាំង០១រូប)

-ស្នើសុំមន្ត្រីជាប់កិច្ចសន្យា ។

៥.ការអភិវឌ្ឍធនធានមនុស្ស ៖

៥.១.សកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ

*ឆ្នាំសិក្សា ២០១២-២០១៣ មាននិស្សិតសរុប**១.៥៨៣នាក់** (ស្រីមាន**៤៥៨នាក់**) ក្នុងនោះ ៖

-និស្សិតអាហារូបករណ៍មាន**៦៧៥នាក់** (**ស្រី១៨៩នាក់**)

-និស្សិតបង់ថ្លៃសិក្សាមាន**៩០៨នាក់** (**ស្រី២៦៩នាក់**)

-ក្រៅពីចំនួននិស្សិតខាងលើ សកលវិទ្យាល័យបានសហការជាមួយវិទ្យាស្ថានជាតិនៃភាសា និងអារ្យធម៌ចុងបូព៌ា "INALCO" នៃប្រទេសបារាំង បានបើកវគ្គពិសេសផ្នែកបុរាណវិទ្យាចំនួន០២លើក ដែលមាននិស្សិតសរុបចំនួន**៤៥នាក់** ក្នុងនោះស្រី**២២នាក់។** ក្នុងចំណោមនេះមាននិស្សិតជនជាតិបារាំងចំនួន**០៥នាក់** និងជនជាតិឡាវចំនួន**០២នាក់**

-បានប្រឡងជ្រើសរើសនិស្សិតអាហារូបករណ៍ឆ្នាំសិក្សា២០១៣-២០១៤ បានចំនួន**១០៥នាក់** ចែកជា ០៧មុខជំនាញ និងទទួលនិស្សិតបង់ថ្លៃចំនួន**៣៤៦នាក់**

-ផ្តល់បែបបទ និងទទួលពាក្យសុំបន្តការសិក្សាសម្រាប់ឆ្នាំសិក្សា២០១៣-២០១៤

-បើកពិព័រណ៌បង្ហាញស្នាដៃនិស្សិតសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈបាន០១លើក

-បានពង្រឹងបង្កើនគុណភាពសិក្សាស្របតាមគោលការណ៍របស់គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា តាមអនុសាសន៍របស់ក្រសួងអប់រំ យុវជន និងកីឡា ឱ្យមានលក្ខណៈស្តង់ដាជាតិ-អន្តរជាតិ បំពេញតម្រូវការទីផ្សារការងារ និងសង្គមជាតិ

-បានអនុវត្តល្អប្រសើរតាមកម្មវិធីសិក្សាពីថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន និងគ្រប់កម្រិតសិក្សានៃមហាវិទ្យាល័យទាំង៥

-បានកែសម្រួលកម្មវិធីសិក្សាឱ្យស្របតាមការវិវត្តន៍រីកចម្រើននៅក្នុងអាស៊ាន តំបន់ និងពិភពលោក

-ទន្ទឹមការសិក្សាផ្នែកទ្រឹស្តី និស្សិតបានចុះធ្វើកម្មសិក្សា (ការស្រាវជ្រាវអំពីប្រាសាទ ផ្ទះបុរាណ ស្ថានីយបុរេប្រវត្តិ សិល្បៈរបាំ តន្ត្រី របស់ជនជាតិភាគតិច នៅតាមបណ្តាខេត្ត-ក្រុង នៃព្រះរាជាណាចក្រកម្ពុជា ការចូលរួមស្តាប់បឋកថា សិក្ខាសាលា សន្និសីទ សកម្មភាពបណ្ណាល័យ ដើម្បីបំពេញចំណេះដឹងបន្ថែម ទទួលបានបទពិសោធន៍និងជាប្រភពមូលដ្ឋានជំនួយដល់ការសិក្សាស្រាវជ្រាវអំពីវិស័យវប្បធម៌សិល្បៈបុរាណ និងសម័យទំនើបតាមកម្មវិធីដែលសកលវិទ្យាល័យបានរៀបចំ

-បានបំពាក់សម្ភារៈឧបទេស ឧបករណ៍មួយចំនួនបន្ថែមទៀតដល់គ្រប់កម្រិតសិក្សា ដើម្បីភាពងាយស្រួលដល់ការរៀន និងបង្រៀន

-សហការជាមួយអគ្គនាយកដ្ឋានឧត្តមសិក្សា និងនាយកដ្ឋានស្រាវជ្រាវ នៃក្រសួងអប់រំ យុវជន និងកីឡា ពាក់ព័ន្ធការងារជំនាញ និងការផ្សៀងផ្ទាត់សន្លឹកសញ្ញាបត្រនិស្សិត ការងារបណ្តុះបណ្តាលនៅសាលាគរុកោសល្យភូមិភាគរាជធានីភ្នំពេញ និងសាលាបណ្តុះបណ្តាលនាយទាហានត្មាតពង

***ស្ថិតិនិស្សិតប្រឡងបញ្ចប់ថ្នាក់បរិញ្ញាបត្រជាប់ជាស្តាពរ ឆ្នាំសិក្សា២០១២-២០១៣ ៖**

សកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ បានបើកការប្រឡងបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រដល់និស្សិតមហាវិទ្យាល័យទាំង៥ ប្រកបដោយជោគជ័យ។ និស្សិតដែលបានប្រឡងជាប់ជាស្តាពរសរុបមានចំនួន**២៧៨នាក់** ក្នុងនោះស្រីចំនួន**៧៣នាក់** ៖

១-មហាវិទ្យាល័យស្ថាបត្យកម្ម និងនគរូបនីយវិទ្យា មាននិស្សិតប្រឡងជាប់ចំនួន**១៥៤នាក់** ក្នុងនោះស្រីចំនួន**១៧នាក់**

២-មហាវិទ្យាល័យសិល្បៈសួនរូប មាននិស្សិតប្រឡងជាប់ចំនួន**៦២នាក់** ក្នុងនោះស្រីចំនួន**២៨នាក់** (ផ្នែកតុបតែងលម្អស្ថាបត្យកម្មចំនួន**៤៣នាក់** ផ្នែកវិចិត្រកម្មចំនួន**០៨នាក់** ផ្នែកសារគមន៍នាគមន៍ចំនួន**០៥នាក់** និងផ្នែកចម្លាក់ចំនួន**០៦នាក់**)

៣-មហាវិទ្យាល័យបុរាណវិទ្យា មាននិស្សិតប្រឡងជាប់ចំនួន**៣៩នាក់** ក្នុងនោះស្រីចំនួន**១៥នាក់**

៤-មហាវិទ្យាល័យសិល្បៈនាដសាស្ត្រ មាននិស្សិតប្រឡងជាប់ចំនួន**០៩នាក់** ក្នុងនោះស្រី**០៦នាក់**

៥-មហាវិទ្យាល័យតូរ្យតន្ត្រី មាននិស្សិតប្រឡងជាប់ចំនួន**១៤នាក់** ក្នុងនោះស្រី**០៧នាក់។**

***ការងារទំនាក់ទំនងអន្តរជាតិ ៖**

ការងារទំនាក់ទំនងអន្តរជាតិមានភាពរីកចម្រើន ទទួលបានកិត្តិយសក្នុងកិច្ចការសហប្រតិបត្តិការយ៉ាង ទូលំទូលាយជាមួយដៃគូជាច្រើន និងបន្តស្វែងរកដៃគូដ៏ទៃទៀត ក្នុងគោលដៅបង្កើន ពង្រីក ពង្រឹង សហប្រតិ បត្តិការ ការផ្តល់បទពិសោធន៍ឱ្យគ្នាទៅវិញទៅមក ការបណ្តុះបណ្តាលមន្ត្រីរាជការ សាស្ត្រាចារ្យ ការផ្លាស់ប្តូរ និស្សិតអាហារូបករណ៍។

សកម្មភាពនេះសកលវិទ្យាល័យសម្រេចបាននូវការងារសំខាន់ៗរួមមាន ៖

-បន្តកិច្ចសហការសកលវិទ្យាល័យហាវ៉ៃ (USA) សកលវិទ្យាល័យណាន់ហ្សាន (ជប៉ុន) សកលវិទ្យាល័យ សូហ្វីយ៉ា (ជប៉ុន) សកលវិទ្យាល័យជាតិកូរ៉េ (សាធារណរដ្ឋកូរ៉េ) អង្គការយូណេស្កូ (UNESCO)

-មជ្ឈមណ្ឌលវប្បធម៌បារាំង (CCF) សម្ព័ន្ធសកលវិទ្យាល័យនិយាយភាសាបារាំង (AUF) លើការបង្រៀនភាសាបារាំង សកម្មភាពតាំងពិព័រណ៌

-Germany, Arts and Foundation សហប្រតិបត្តិការប្រគុំតន្ត្រី

-Korea, YTSC of Music សហប្រតិបត្តិការផ្នែកបង្ហាត់តន្ត្រី

-ការចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នារវាងមូលនិធិតន្ត្រីដើម្បីទាំងអស់គ្នា (Music for One Foundation) ប្រទេសកូរ៉េ ជាមួយសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ

-ដាក់ឱ្យប្រើប្រាស់ការបង្រៀនតូរ្យតន្ត្រីតាមOnline ឬការសិក្សាពីចម្ងាយតាមរយៈ Video Conference ដោយសហការជាមួយអភិរក្សដ្ឋានតូរ្យតន្ត្រីសឹង្ហបុរី នៃសកលវិទ្យាល័យជាតិសឹង្ហបុរី នៅមហាវិទ្យាល័យតូរ្យតន្ត្រី

-INALCO (វិទ្យាស្ថានជាតិនៃភាសា និងអារ្យធម៌ចុងបូព៌ា) សកលវិទ្យាល័យមួសុង នៃប្រទេសបារាំង សហប្រតិបត្តិការផ្លាស់ប្តូរនិស្សិត និងបានបើកវគ្គពិសេសផ្នែកបុរាណវិទ្យាចំនួន០២វគ្គ នៅសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ

-ការចូលរួមសិក្ខាសាលា ស្តីពីការគ្រប់គ្រងឆាក នៅប្រទេសហ្វីលីពីន ។

៥.២.សាលាមធ្យមវិចិត្រសិល្បៈ

***ឆ្នាំសិក្សា២០១២-២០១៣** សិស្សសិក្សានៅតាមសាលាជំនាញសរុបចំនួន: **១.០២៧នាក់** ក្នុងនោះស្រី **៥៤៣នាក់**

-សិស្សមកពីខេត្តនានាដែលសាលាទទួលឲ្យស្នាក់នៅមានចំនួន២០២នាក់ ក្នុងនោះស្រី៦៥នាក់

***សិស្សប្រឡងយកសញ្ញាបត្រ ៖** សរុបចំនួន**១៨៥នាក់** ក្នុងនោះស្រី**៧៨នាក់ ៖**

-ស្នាតកបត្រសិល្បៈមានចំនួន**៨៨នាក់** ស្រី**៣៨នាក់**

-សញ្ញាបត្រសិល្បៈមានចំនួន**៩៧នាក់** ស្រី**៤០នាក់**

-បានរៀបចំកម្មវិធីសិក្សាតាមសាលាជំនាញទាំង៥ សម្រាប់ឆ្នាំសិក្សា២០១៣-២០១៤

-ការប្រឡងចូលរៀននៅសាលាមធ្យមវិចិត្រសិល្បៈឆ្នាំសិក្សា២០១៣២០១៤ មានសិស្សប្រឡង ជាប់ចំនួន**២១៨នាក់** ស្រី**៩៣នាក់**

-បានរៀបចំបន្ទប់អាគារស្នាក់នៅរបស់សិស្សសម្រាប់ឆ្នាំសិក្សាថ្មី និងជួសជុលតុ-បន្ទប់អនាម័យ-ដំបូល អាគារបាក់បែក និងប្រព័ន្ធលូ

-បានកសាងបុស្បុក និងរូបសំណាក ដែលផ្តល់ថវិកាដោយលោក មុនី ជោត នៅសហរដ្ឋអាមេរិក និងរូបសំណាកព្រះភិរុណ០១អង្គ ជាអំណោយសប្បុរសធម៌ថ្នាក់ដឹកនាំសាលា

-បានពង្រឹងគុណភាពលើការបង្រៀនផ្នែកបច្ចេកទេស និងចំណេះទូទៅ ដល់លោកគ្រូ អ្នកគ្រូ

-សិស្សានុសិស្សចំនួន២៥នាក់ បានចូលរួមសម្តែងសិល្បៈអបអរសាទរ ថ្ងៃជ័យជំនះ ៧ មករា ២០១៣ នៅស្នាក់ការកណ្តាល គណបក្សប្រជាជនកម្ពុជា

-បានប្រគុំភ្លេងពិណពាទ្យ សូត្របទសារធញ្ញ ក្នុងពិធីបុណ្យមាឃបូជា នៅភ្នំឧត្តុង្គ

-សិស្សានុសិស្សចំនួន២២នាក់ បានចូលរួមសូត្របទយំយាម នៅក្នុងព្រះរាជពិធីតម្កល់ព្រះបរមសពព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

-ថ្នាក់ដឹកនាំសាលា និងសិល្បករ សិល្បការិនីចំនួន៨០នាក់ បានចូលរួមសម្តែងសិល្បៈក្នុងទិវាវប្បធម៌ជាតិ ០៣ មីនា ឆ្នាំ២០១៣

-សិស្សសាលាសៀក បានចូលរួមសម្តែងក្នុងទិវានារីអន្តរជាតិ នៅមជ្ឈមណ្ឌលសិល្បៈសៀក និងទស្សនីយភាព នៃនាយកដ្ឋានអភិវឌ្ឍវប្បធម៌

-សិស្សានុសិស្ស និងគ្រូចំនួន១០៤នាក់ បានចូលរួមសម្តែងសិល្បៈនៅខេត្តកំពង់ឆ្នាំង

-សិស្សានុសិស្ស និងគ្រូចំនួន២៤នាក់ បានចូលរួមសម្តែងសិល្បៈក្នុងពិធីសម្ពោធស្វ៊ីយោភាពយន្តនៅខេត្តកំពង់ស្ពឺ

-សិស្សានុសិស្ស និងគ្រូចំនួន៨៥នាក់ បានសម្តែងសិល្បៈជូនគណៈប្រតិភូបេតិកភណ្ឌពិភពលោកនៅទីស្តីការគណៈរដ្ឋមន្ត្រី

-បានទទួលគណៈប្រតិភូកាយសម្ព័ន្ធចិនចំនួន២៥រូប មកទស្សនាសាលាមធ្យមវិចិត្រសិល្បៈ ។

***ចញ្ហាប្រឈម ៖**

-ខ្វះថវិកាសម្រាប់ជួសជុល ខ្វះសម្ភារៈបច្ចេកទេស បណ្ណាល័យ សេវាទំនាក់ទំនង

-ពុំបានចូលរួមបណ្តុះបណ្តាលគរុកោសល្យបន្ថែមស្របតាមកម្មវិធីថ្មីរបស់ក្រសួងអប់រំ

-គ្រូចំណេះទូទៅចូលនិវត្តន៍ជាបន្តបន្ទាប់ ប៉ុន្តែគ្មានការជ្រើសរើសចូលថ្មីបមកបំពេញបន្ថែម

-គ្រូជំនាញចូលនិវត្តន៍ច្រើន តែការជ្រើសរើសចូលបានតិច

-ខ្វះឯកសារគោលក្នុងការបង្ហាត់បង្រៀន ខ្វះថវិកាក្នុងការចងក្រងឯកសារ ។

***សំណូមពរ ៖**

-សំណើសុំថវិកាសម្រាប់ជួសជុលអាគារ

-ស្នើសុំជំនួយឧបត្ថម្ភពីរាជរដ្ឋាភិបាលនូវសម្ភារៈបច្ចេកវិជ្ជាព័ត៌មានវិទ្យា និងបណ្ណាល័យ

-សុំទៅបណ្តុះបណ្តាលគរុកោសល្យរយៈពេលខ្លីរបស់គ្រូចំណេះទូទៅ និងបច្ចេកទេស

-សំណើសុំគ្រូចំណេះទូទៅពីក្រសួងអប់រំ យុវជន និងកីឡា

-ស្នើសុំថ្នាក់ដឹកនាំរៀបចំក្រុមស្រាវជ្រាវ ចងក្រងឯកសារ ដោយសហការជាមួយទីប្រឹក្សាក្រសួង និងថវិកាសម្រាប់ឧបត្ថម្ភក្រុមស្រាវជ្រាវ ។

៦-ការងារសេវនកម្មផ្ទៃក្នុង ៖

-ការិយាល័យសវនកម្មទាំង៣ បានចុះធ្វើសវនកម្មតាមបណ្តាមន្ទីរាជធានី-ខេត្តចំនួន១២មន្ទីរ តាមផែនការកំណត់មាន៖ រាជធានីភ្នំពេញ-កំពង់ស្ពឺ-ព្រះសីហនុ-កោះកុង-តាកែវ-កំពង់ឆ្នាំង-ពោធិសាត់-បាត់ដំបង បន្ទាយមានជ័យ-ប៉ៃលិន-មណ្ឌលគីរី និងខេត្តកំពង់ចាម។

***ចញ្ហាប្រឈម ៖**

-ខ្វះថវិកា មធ្យោបាយ សម្ភារៈ បច្ចេកទេស

-ខ្វះខាតធនធានមនុស្ស ។

***សំណូមពរ ៖**

-ស្នើសុំមន្ត្រីក្របខណ្ឌថ្មី ។

៧.ការងារអធិការកិច្ច ៖

-បានធ្វើអធិការកិច្ចរដ្ឋបាល និងហិរញ្ញវត្ថុចំនួន៣អង្គភាពគឺ ៖ មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តរតនគីរី-ខេត្តស្ទឹងត្រែង និងខេត្តក្រចេះ

-បានធ្វើអធិការកិច្ចបច្ចេកទេសចំនួន៤អង្គភាពគឺ ៖ មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តព្រះវិហារ- ខេត្តសៀមរាប-ខេត្តឧត្តរមានជ័យ និងខេត្តស្វាយរៀង

-បានធ្វើអធិការកិច្ចសិក្សាចំនួន៣អង្គភាពគឺ ៖ មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពង់ធំ-ខេត្តកំពត និងខេត្តកែប

-ការិយាល័យទទួលបណ្តឹង និងអង្កេតស្រាវជ្រាវ ៖ បានអង្កេតស្រាវជ្រាវរឿាទរដ្ឋបាលចំនួន០២លើក នៅនាយកដ្ឋានគាំពារ និងអភិរក្សសំណង់បុរាណ និង សកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ។ បានទទួលពាក្យបណ្តឹងបរិហារអនាមិកចំនួន០៥ករណី ។

***ចញ្ហាប្រឈម ៖**

-កង្វះក្របខ័ណ្ឌមន្ត្រីរាជការ

-ចំណេះដឹង និងសមត្ថភាពជំនាញរបស់មន្ត្រីនៅមានកំរិត

-សម្ភារៈបរិក្ខារដូចជា Computer Printer Photocopy machine ភាគច្រើនចាស់ហួសសម័យ ខូច និងខ្វះថវិកាជួសជុល

-ថវិកាបេសកកម្មពុំទាន់បើកបានពីនាយកដ្ឋានគណនេយ្យ ធ្វើឲ្យការងារធ្វើអធិការកិច្ចមិនទាន់សភាពការណ៍ និងប្រសិទ្ធភាព

-មិនទាន់មានគោលនយោបាយលើកទឹកចិត្តដល់មន្ត្រីរាជការអធិការកិច្ចនៅពេលបំពេញភារកិច្ចបានល្អ

-លិខិតបទដ្ឋានគតិយុត្ត និងច្បាប់នៅមិនទាន់ឆ្លើយតបតាមការវិវត្តរីកចម្រើនរបស់វិស័យវប្បធម៌។

***សំណូមពរ៖**

-ស្នើសុំក្របខ័ណ្ឌមន្ត្រីថ្មី
-ស្នើសុំក្រសួងជួយផ្តល់សម្ភារៈការិយាល័យឲ្យបានច្រើនជាងមុនបន្តិច
-សុំក្រសួងជួយសំរួលផ្តល់ថវិកាសម្រាប់បេសកកម្មឲ្យបានខ្លះមុនពេលចេញដំណើរទៅខេត្ត
-ស្នើសុំម៉ាស៊ីន Photocopy ខ្នាតមធ្យមចំនួន១គ្រឿង ។

៨.ការងារមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី-ខេត្ត ៖

មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈធានីភ្នំពេញ ៖

ការងារបេតិកភណ្ឌរូបី ៖ បានរៀបចំថែរក្សាការពារសណ្តាប់ធ្នាប់ សោភ័ណ្ឌភាព អនាម័យមណ្ឌលវត្តភ្នំបានជាប្រចាំ និងធ្វើផែនទីរមណីយដ្ឋានវត្តភ្នំសម្រាប់តាំងបង្ហាញភ្ញៀវទេសចរណ៍។ រៀបចំប្រព័ន្ធភ្លើងទឹក នៅរមណីយដ្ឋានវត្តភ្នំ និងបានសហការជាមួយក្រុមសាធារណការ កាប់មែកឈើជុំវិញវត្តភ្នំ។ សហការជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និង អង្គការយូណេស្កូ ចុះត្រួតពិនិត្យ និងកំណត់ទីតាំងភូមិបុរាណដើម្បីធ្វើកំណាយនៅភូមិមូល សង្កាត់ដង្កោ ខណ្ឌដង្កោ។ សហការជាមួយក្រុមការងាររបស់រាជបណ្ឌិតសភា និងនិស្សិតមកពីប្រទេសសឹង្ហបុរី ចុះពិនិត្យការធ្វើកំណាយឡបុរាណនៅ ស្ថានីយជើងឯក ស្ថិតនៅខណ្ឌដង្កោ រាជធានីភ្នំពេញ។

ការងារបេតិកភណ្ឌអរូបី ៖ ក្រុមសិល្បៈបានចេញសម្តែងបម្រើជូនប្រជាពលរដ្ឋក្នុងកម្មវិធីផ្សេងៗបានចំនួន១១៦លើក។ ចុះត្រួតពិនិត្យហាងអ៊ិនធើណេតបានចំនួន២៥លើក ហាងកាហ្វេចំនួន៥៥លើក រោងភាពយន្តនៅផ្សារស៊ីធីម៉លចំនួន០៧លើក កន្លែងលក់-ជួលស៊ីឌី វីស៊ីឌីចំនួន១២៥លើក និង សហការជាមួយកម្លាំងចម្រុះចុះឆែកឆេរត្រួតពិនិត្យកន្លែងលក់វត្ថុអនុស្សាវរីយ៍យីហោ ឧត្តមឆៃណា អាស៊ាន ស្ថិតក្នុងសង្កាត់ទួលទំពូងទី១ ខណ្ឌចំការមន ដើម្បីត្រួតពិនិត្យវត្ថុបុរាណ។ ចុះណែនាំ និងផ្សព្វផ្សាយដល់ទីតាំងធ្វើអាជីវកម្មសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម នៅទូទាំងរាជធានីភ្នំពេញជាប្រចាំ។ សហការជាមួយគណៈកម្មការត្រួតពិនិត្យស្លាកយីហោ ប៉ាណូផ្សព្វផ្សាយពាណិជ្ជកម្មថ្នាក់រាជធានី ចុះត្រួតពិនិត្យគ្រប់សាលាខណ្ឌ និងសម្រេចផ្តល់អាជ្ញាប័ណ្ណ (ស្លាកយីហោ ប៉ាណូផ្សព្វផ្សាយពាណិជ្ជកម្មដែលមានលក្ខណៈត្រឹមត្រូវតាមគោលការណ៍របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ) បានចំនួន២.៨៥០ច្បាប់។ ចូលរួមរៀបចំតុបតែងលម្អ (ហ្វ៊ុង, បដា, ពាក្យស្លោក, ទង់ជាតិ និងទង់ផ្កាលា ក្នុងពិធីបុណ្យជាតិ-អន្តរជាតិ) បានចំនួន៦១លើក។

មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកណ្តាល ៖

ការងារបេតិកភណ្ឌរូបី ៖ បានសហការជាមួយមន្ត្រីជំនាញ នៃនាយកដ្ឋានបុរាណវិទ្យា និងបុរេប្រវត្តិវិទ្យា ដោយមានការចូលរួមពីអាជ្ញាធរស្រុក-ឃុំ-ភូមិ ប្រជាពលរដ្ឋ បាននាំយកបង្គោលកំណត់តំបន់ការពារបេតិកភណ្ឌវប្បធម៌ជាតិចំនួន១២ដើម ទៅបោះនៅស្ថានីយបុរាណចំនួន០៣គឺ ទួលគុហាធំ ទួលកំណប់ និងទួលតាអ៊ុង ស្ថិតនៅឃុំសំពៅពូន ស្រុកកោះធំ។ បានចុះសិក្សា គូរប្លង់រួចរាល់នូវស្ថានីយចំនួន១៧កន្លែង ក្នុងនោះនៅឃុំសំពៅពូន១២កន្លែង-ឃុំជ្រោយតាកែវ០១កន្លែង និងឃុំឈើខ្មៅ០៤កន្លែង។ ចុះវាស់កំណត់ព្រំប្រទល់ទីទួលបុរាណចំនួន០៣កន្លែង នៅឃុំព្រះប្រសប់ ឃុំជ័យធំ និងឃុំកំពង់ចម្លង ស្រុកខ្សាច់កណ្តាល។ ការងារសាងសង់ក្លោងទ្វារធំចូលទៅកាន់ភ្នំព្រះរាជទ្រព្យ សម្រេចបាន៥៥ភាគរយ និង ការងារបិទការ៉ូថ្មត្រជាក់ នៅរានហាលព្រះសត្យមុនីចេតិយបានរួចរាល់ជាស្ថាពរ និងកំពុងបន្តបិទនៅតាមជណ្តើរឡើងជាបន្តទៀតចំនួន១.៥០០ម៉ែត្រការ៉េ។ ការងារសាងសង់ក្លោងទ្វារធំ និងការងារបិទការ៉ូថ្មត្រជាក់ជាអំណោយរបស់ឯកឧត្តម អ៊ិត ប្រាង និង លោកអគ្គបណ្ឌិត ប៊ុត សារង្ស រួមជាមួយសប្បុរសជនក្នុង និងក្រៅប្រទេស អស់ទឹកប្រាក់ចំនួន២៦០.០០០ដុល្លារអាមេរិក។ ឯកឧត្តម [illegible] និងលោកជំទាវ [illegible]

មួយគូដាក់ខាងមុខព្រះវិហារទន្ទឹមនៅភ្នំព្រះរាជទ្រព្យ អស់ទឹកប្រាក់ចំនួន៤០០ដុល្លាអាមេរិក និង លោកអគ្គបណ្ឌិត ប៊ុត សាវង្ស បានជួយឧបត្ថម្ភថវិកាថ្លៃភ្លើងចំនួន១.០២៦គីឡូវ៉ាត់-ម៉ោង អស់ទឹកប្រាក់ចំនួន ១.២៣១.២០០រៀល និងជួយឧបត្ថម្ភដល់ពលករអណ្តែតជាឆ្មាំចំនួន២០០.០០០រៀល។ លោកឧកញ៉ា សុខ សុខា និង លោកជំទាវ ជួយឧបត្ថម្ភប្រដាប់បំពងសម្លេង កៅអីជ័រចំនួន២០០កៅអី អស់ទឹកប្រាក់ចំនួន១.៣០០ដុល្លា សម្រាប់ប្រើប្រាស់នៅព្រះសត្យមុនីចេតីយ ភ្នំព្រះរាជទ្រព្យ។ ឯកឧត្តម អ៊ុត ប្រាង បានជួយឧបត្ថម្ភដាក់បង្គោលភ្លើងធំៗចំនួន១១ដើម អស់ទឹកប្រាក់ចំនួន១.៦៩៧ដុល្លាអាមេរិក និងប្រាក់រៀលចំនួន១.២៥៦.០០០រៀល។ បានទទួលព្រះពុទ្ធរូបអង្គតូច-ធំ ដែលសប្បុរសជនយកមកតម្កល់ក្នុងព្រះសត្យមុនីចេតិយមានចំនួន២៦៣អង្គ ។ កាលពីរាត្រីថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៣ វេលាម៉ោងប្រហែលពីររំលងអាធ្រាត្រ មានអំពើចោរកម្ម ដ៏ធ្ងន់ធ្ងរមួយបានកើតឡើងនៅក្នុងព្រះសក្យមុនីចេតីយ លើភ្នំព្រះរាជទ្រព្យ ដោយមានចោរមួយក្រុមបានលបចូលមកគាស់បំបាក់ទំពក់សោទ្វារព្រះសក្យមុនីចេតីយចូលទៅខាងក្នុង និងឡើងតាមជណ្តើរទៅកំពូលខាងលើលួចយកព្រះកោដ្ឋតម្កល់ព្រះបរមសិរីរឹកធាតុចំនួន០១ ព្រះពុទ្ធរូបតូចៗចំនួន០៧អង្គ (ពុំដឹងច្បាស់ថាវត្ថុទាំងនោះផលិតអំពីវត្ថុធាតុអ្វីពិតប្រាកដនោះទេ ដោយហេតុថាពុំមានបញ្ជីសារពើភណ្ឌ) ដែលក្នុងនោះមានព្រះពុទ្ធរូប០១អង្គ គឺជាព្រះរាជទ្រព្យរបស់អតីតព្រះមហាក្សត្រ ព្រះបរមរតនកោដ្ឋ ដែលព្រះអង្គទ្រង់ថ្វាយតម្កល់ទុកនៅទីនោះផងដែរ និងប្រាក់មួយចំនួនដែលសប្បុរសជនដាក់បាត្រ ។

ការងារបេតិកភណ្ឌអរូបី ៖ បានរៀបចំពិធីប្រារព្ធទិវាវប្បធម៌ជាតិ ០៣ មីនា លើកទី១៥ និងបើកមហោស្រព សិល្ប:មហាជន ទម្រង់របាំបុរាណ របាំប្រពៃណី អាយ៉ែរឿង អាយ៉ែឆ្លើយឆ្លង និងល្ខោនបាសាក់ ឆ្នាំ២០១៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម ហ៊ឹម ឆែម រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្ប: នៅមជ្ឈមណ្ឌល គរុកោសល្យភូមិភាគ ហ៊ុន សែន ខេត្តកណ្តាល នៅក្រុងតាខ្មៅ។ បើកមហោស្រពចម្រៀងសកលថ្នាក់ខេត្ត និងបានចូលរួមមហោស្រពតន្ត្រី ចម្រៀងថ្នាក់ជាតិ ទទួលចំណាត់ថ្នាក់លេខ១ ក្នុងចំណោមក្រុមតន្ត្រី១៨ក្រុម ។ បាននិពន្ធបទភ្លេង និងទំនុកច្រៀងថ្មីចំនួន០៦បទ ក្រៅពីនេះមន្ទីរបានដឹកនាំក្រុមសិល្ប:ទៅសម្តែងជាមិត្តភាពនៅខេត្តអាងយ៉ាង ប្រទេសវៀតណាម ចំនួន០២លើក។ ចុះត្រួតពិនិត្យអាជីវកម្មជួល-លក់ស៊ីឌី វីស៊ីឌី ដែលគ្មានទិដ្ឋាការរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្ប: ជាពិសេសការជួល-លក់ស៊ីឌី វីស៊ីឌីអាសអាភាស នៅតាមទីតាំងដែលធ្លាប់បានប្រព្រឹត្តល្មើសកន្លងមក ព្រមទាំងអប់រំណែនាំឱ្យអាជីវករអនុវត្តត្រឹមត្រូវតាមការណែនាំរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្ប:។ បានអនុញ្ញាតច្បាប់លើកស្លាកយីហោ ផ្ទាំងផ្សាយពាណិជ្ជកម្ម និងស្លាកសញ្ញាបានចំនួន១៨ច្បាប់។ បានផ្សព្វផ្សាយចែកជូនសេចក្តីណែនាំពីការពង្រឹងការងារគ្រប់គ្រងសិល្ប:សូនរូប និង សិល្ប:សិប្បកម្ម និងគម្រូរានទេញ្ពាខ្មែរដល់ ក្រុង-ស្រុក និងសិប្បករទូទាំងខេត្ត ។

មន្ទីរវប្បធម៌ និងវិចិត្រសិល្ប:ខេត្តតាកែវ ៖

ការងារបេតិកភណ្ឌរូបី ៖ បានចុះធ្វើសម្រង់ស្ថិតិស្ថានីយបុរាណចំនួន៦៧ស្ថានីយ ដើម្បីធ្វើសាលាកបត្រទទួលស្គាល់។ ចុះត្រួតពិនិត្យសំណង់ខុសច្បាប់នៅប្រាសាទតាញាណ ស្រុកគិរីវង់ និងសហការជាមួយមន្ទីរទេសចរណ៍ខេត្ត កាប់ឆ្ការព្រៃនៅប្រាសាទភ្នំដា និងប្រាសាទអាស្រមមហាឬស្សី។ ធ្វើអនាម័យសម្អាត និងជួសជុលស្លាកសញ្ញាបម្រាមផ្សេងៗដាក់ក្នុងប្រាសាទតាព្រហ្មទន្លេបាទី លាបថ្នាំ និងសរសេរឡើងវិញចំនួន០៥ស្លាក និងបានកាប់ដើមឈើដែលដុះលើប្រាសាទយាយពៅទន្លេបាទី។ បានចុះទៅស្រុកត្រាំកក់ដើម្បីស្រាវជ្រាវវត្ថុបុរាណ និងរកឃើញវត្ថុបុរាណ(យោនី) ចំនួន០១ដុំនៅផ្ទះប្រជាពលរដ្ឋ បច្ចុប្បន្នយកមករក្សាទុកក្នុងសារមន្ទីរខេត្ត និងបានទទួលវត្ថសិល្ប:អំពីធេញថ្មាមក្រពើចំនួន០១ ទំងន់៤០ក្រាម ពីប្រជា

ពលរដ្ឋឃុំអង្គរបុរី។ ចុះទៅដឹកផ្ទាំងថ្មបុរាណចំនួន១០ផ្ទាំង នៅវត្តកំពង់ហ្លួង ឃុំអង្គរបុរី យកមករក្សាទុកនៅសារមន្ទីរស្រុកអង្គរបុរី។ ស្រាវជ្រាវវត្ថុបុរាណក្រៅសារមន្ទីរដែលមានក្នុងមូលដ្ឋាន ដើម្បីធ្វើសាលាកបត្របញ្ជាក់អត្តសញ្ញាណវត្ថុបុរាណនីមួយៗ។ បានចុះត្រួតពិនិត្យប្រាសាទសែនភូវាំងសម្រាប់បោះបង្គោលដែនកំណត់ប្រាសាទ និងជញ្ជាំងប្រាសាទខាងជើងឈៀងខាងលិចមានការទ្រេតយ៉ាងខ្លាំង និងប្រឈមនឹងការខូចខាតទៅថ្ងៃអនាគត។ កាប់ឆ្ការព្រៃបោសសម្អាតទីធ្លាជុំវិញបរិវេណប្រាសាទភ្នំជីស្វរ ប្រាសាទភ្នំដា ប្រាសាទ នាងខ្មៅ ប្រាសាទសែននិមល និងប្រាសាទសែនភូវាំងចំនួន២០លើក។ ភ្ញៀវចូលទស្សនាសារមន្ទីរក្នុងខេត្ត និងនៅអង្គរបុរីសរុបចំនួន១.៥៤១ នាក់ (អន្តរជាតិ១៨៥នាក់) ។

ការងារបេតិកភណ្ឌអរូបី ៖ បាននិពន្ធ និងតម្លើងស្នាដៃថ្មីៗបាន០៨រឿង និងបទចម្រៀងបាន០៧បទ ព្រមទាំងហាត់រំលឹករឿងចាស់ៗ និងបានចងក្រងឯកសារក្បាច់យីកេហោមរោងចំនួន០១ក្បាច់ បទសាធុការចំនួន០១បទ និងចងក្រងឯកសារក្បាច់ចម្រៀងយីកេចំនួន០៩ក្បាច់។ ចងក្រងឯកសារ ស្តីពីបញ្ជាន់ក្បាលក្របី០១ច្បាប់។ ចុះត្រួតពិនិត្យកន្លែងលក់-ជួលឌីសក្នុងមូលដ្ឋានស្រុក-ក្រុងទាំង១០បានចំនួន២០លើក និងបានធ្វើកិច្ចសន្យាជាមួយអាជីវករកុំឱ្យជួល-លក់ឌីសដែលគ្មានទិដ្ឋាការ។ ចុះត្រួតពិនិត្យសិប្បកម្មចម្លាក់ពុម្ពស៊ីម៉ង់ត៍ចំនួន០៧លើក ព្រមទាំងធ្វើការណែនាំដល់អាជីវករឱ្យរក្សាត្រួតាមក្បួនខ្នាតជាតិ និងចុះស្រាវជ្រាវអំពីក្បាច់គុនបុរាណខ្មែរនៅស្រុកព្រៃកប្បាស និងស្រុកកោះអណ្តែតដើម្បីចងក្រងជាឯកសារ។ ទទួលឯកសារ មរតកក្បាច់គុនបុរាណខ្មែរជាសៀវភៅចំនួន០៥ក្បាល ពីលោកគ្រូក្បាច់គុនខ្មែរនៅព្រៃកប្បាស។ ចុះត្រួត ពិនិត្យកែលម្អ និងណែនាំការដាក់ស្លាកយីហោ ផ្ទាំងផ្សាយពាណិជ្ជកម្ម និងស្លាកសញ្ញានានានៅតាមបណ្តាស្រុក-ក្រុង។ ចុះស្រាវជ្រាវ និងប្រមូលសម្ភារៈកសិកម្មដែលប្រជាពលរដ្ឋខ្មែរប្រកបកសិកម្មកាលពីបុរាណ ដូចជា រទេះគោ ទទឹក (ទត្រងទឹក) រហាត់ទឹក និងស្មាចបាចទឹកជាដើម ដើម្បីយកមករក្សាទុកក្នុងសារមន្ទីរ ស្រុកអង្គរបុរី ។

មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពត ៖

ការងារបេតិកភណ្ឌរូបី ៖ បានចុះពិនិត្យ និងជួយសម្រួលដល់ការលើកផ្លូវ និងដាក់លូចំនួន០២កន្លែង ចូលទៅកាន់រមណីយដ្ឋានភ្នំឈ្មោក ដែលមានផ្លូវប្រវែង៣០០ម៉ែត្រ។ ចុះពិនិត្យការសាងសង់សំណង់មួយជិតគុហារព្រះម៉ែគង្គា (ភ្នំឈ្មោក) និងសំណង់ផ្ទាំងថ្ម (រាយនាមសប្បុរសជន) នៅតំបន់ការពារប្រាសាទវត្តប្រាសាទ ស្រុកអង្គរជ័យ។ សហការជាមួយការិយាល័យវប្បធម៌ស្រុកឈូក បង្ក្រាបបទល្មើសលួចគាស់កកាយនៅតំបន់ការពារប្រាសាទថ្មពូក ស្រុកឈូក និងចាប់ជនល្មើសបានចំនួន០៦នាក់បញ្ជូនទៅតុលាការ។ ផ្សព្វផ្សាយជាថ្មីដល់គ្រប់ស្រុក-ក្រុង នូវសេចក្តីណែនាំលេខ០២ ស.ណ.ន ស្តីពីការអនុវត្តកិច្ចការពារបេតិកភណ្ឌវប្បធម៌ និងរមណីយដ្ឋានទេសចរណ៍ក្នុងខេត្ត ។

ការងារបេតិកភណ្ឌអរូបី ៖ បានរៀបចំពិធីប្រារព្ធទិវាវប្បធម៌ជាតិ ០៣ មីនា លើកទី១៥ និងបើកមហោស្រពសិល្បៈមហាជន ឆ្នាំ២០១៣ ក្រោមអធិបតីភាព លោកជំទាវ ម៉ិញ កុសនី រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ នៅពហុកីឡាដ្ឋានខេត្តកំពត។ ចុះត្រួតពិនិត្យអាជីវកម្មជួល-លក់ស៊ីឌី វីស៊ីឌីចំនួន០២លើក និងធ្វើការហាមឃាត់ក្រុមហ៊ុនផលិតកម្មភាពយន្ត BBC ដែលចុះធ្វើសកម្មភាពថតមានលិខិតអនុញ្ញាតពុំសមស្របត្រឹមត្រូវតាមលក្ខខណ្ឌច្បាប់។ សហការជាមួយការិយាល័យវប្បធម៌ស្រុកទឹកឈូ ចុះស្រាវជ្រាវប្រវត្តិ និងវិធីលេងល្បែងប្រជាប្រិយខ្មែរមាន ល្បែងទាត់ត្រឡាក ល្បែងគ្របមាន់ ល្បែងដើរជើងកុក ល្បែងសីស្លាប និងល្បែងលាក់កាក់ ឬលាក់កូនក្រមុំ នៅឃុំកំពង់គ្រែង និងឃុំថ្មី។ ចុះពិនិត្យទីតាំង សិប្បកម្មចម្លាក់ពុម្ពស៊ីម៉ង់ត៍ចំនួន០៤កន្លែង នៅក្រុងកំពត និងស្រុកទឹកឈូ និងណែនាំដល់សិប្បករធ្វើចម្លាក់ពុម្ពកុំឱ្យខុសឆ្ងាយពី

លក្ខណៈខ្មាតជាតិ ពិសេសរានទេព្តាខ្មែរ។ ចុះត្រួតពិនិត្យ និងធ្វើការណែនាំចំពោះស្លាកយីហោដែលសរសេរខុសពីប្រកាសរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ នៅជុំវិញផ្សារណាត់ ក្រុងកំពត។

មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកែប ៖

ការងារបេតិកភណ្ឌរូបី ៖ បានចុះត្រួតពិនិត្យទីតាំងទួលអង្គបុរាណចំនួន០២លើក និងបានឱ្យឆ្មាំប្រាសាទបោសសម្អាត ធ្វើអនាម័យតាមផ្លូវចូលរួង និងក្នុងបរិវេណរមណីយដ្ឋានភ្នំសរសៀរបានជាប្រចាំ។ ចុះពិនិត្យទីតាំងអាស្រមជំទាវផ្កាយព្រឹកចំនួន០១លើក ដោយបានរកឃើញរូបសំណាកចំនួន០១ ធ្វើពីឈើសាត្រាវ ដែលមានអាយុកាល១៥០ឆ្នាំ ដើម្បីឱ្យសមជាកន្លែងគោរពបូជា បួងសួងសុំសេចក្តីសុខ ឯកឧត្តមអភិបាលខេត្តបានកសាងអាស្រមថ្មី និងបានធ្វើពិធីដង្ហែរូបសំណាកជំទាវផ្កាយព្រឹកចូលអាស្រមថ្មី។

ការងារបេតិកភណ្ឌអរូបី ៖ បានរៀបចំពិធីប្រារព្ធទិវាវប្បធម៌ជាតិ ០៣ មីនា លើកទី១៥ ក្រោមអធិបតីភាព លោកជំទាវ មុិញ កុសនី រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈនៅសាលប្រជុំធំសាលាខេត្តកែប។ ចុះត្រួតពិនិត្យណែនាំ ការបញ្ចាំងរឿងអាសអាភាស និងការជួល-លក់ស៊ីឌី វីស៊ីឌីដែលគ្មានទិដ្ឋាការពីក្រសួង វប្បធម៌ និងវិចិត្រសិល្បៈចំនួន១១លើក និងចុះត្រួតពិនិត្យ ណែនាំដល់ម្ចាស់សិប្បកម្មក្បាច់ចម្លាក់ពុម្ពធ្វើពី បាយអរឱ្យគោរពទៅតាមក្បួនខ្មាត និងរចនាប័ទ្មខ្មែរឱ្យបានត្រឹមត្រូវ។ ចុះត្រួតពិនិត្យស្លាកយីហោ និងស្លាក សញ្ញាផ្សេងៗចំនួន០៨លើក និងចេញលិខិតអនុញ្ញាតសុំលើកស្លាកយីហោចំនួន ០៧កន្លែង។

មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តព្រះសីហនុ ៖

ការងារបេតិកភណ្ឌរូបី ៖ បានត្រួតពិនិត្យ និងរៀបចំថែទាំបន្ទប់ដាក់តាំងរូបវត្ថុបុរាណ និងវត្ថុសិល្បៈជាប្រចាំ ។

ការងារបេតិកភណ្ឌអរូបី ៖ បានរៀបចំពិធីប្រារព្ធទិវាវប្បធម៌ជាតិ ០៣ មីនា លើកទី១៥ និងបើកមហោស្រពសិល្បៈ មហាជន ឆ្នាំ២០១៣ ក្រោមអធិបតីភាព ឯកឧត្តម សោម សុគន្ធ រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ នៅសាលាខេត្តព្រះសីហនុ។ ចុះត្រួតពិនិត្យក្រុមសិល្បៈនៅអង្គការម្លប់តាប៉ាង ក្រុមសិល្បៈយិតយោងកុមារជនបទ និង ក្រុមសិល្បៈអារក្សជនជាតិភាគតិចស្ទឹងចំនួន០៥លើក។ ចុះត្រួតពិនិត្យ និងអញ្ជើញអាជីវករជួលលក់ស៊ីឌី-វីស៊ីឌី នៅផ្សារញ៉ូស្តារចំនួន០១នាក់ និងម្ចាស់អ៊ិនធើណេតហ្គេមចំនួន០៦នាក់ មកចូលរួមប្រជុំដើម្បីធ្វើកិច្ចសន្យាគោរពច្បាប់។ បានពិនិត្យលើពាក្យសុំច្បាប់ដាក់តាំងស្លាកសញ្ញាផ្សាយពាណិជ្ជកម្មរបស់ក្រុមហ៊ុន ផល សារ៉ែត ចំនួន៧៦ច្បាប់ និងអញ្ជើញក្រុមហ៊ុនមកប្រជុំពិភាក្សា និងផ្សព្វផ្សាយប្រកាសលេខ១៧២ ប្រក.ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០២ ស្តីពីការដាក់តាំងស្លាកយីហោ ផ្ទាំងផ្សាយពាណិជ្ជកម្មដល់ក្រុមហ៊ុន និងឱ្យក្រុមហ៊ុនមុននឹងផ្តល់លិខិតអនុញ្ញាតជូនអតិថិជនចាំបាច់ក្រុមហ៊ុនត្រូវឆ្លងកាត់មន្ទីរជំនាញ ក្នុងការត្រួតពិនិត្យខ្លឹមសារស្លាកយីហោ ផ្ទាំងផ្សាយពាណិជ្ជកម្ម និងចុះត្រួតពិនិត្យធ្វើការណែនាំដល់ម្ចាស់លើកស្លាកយីហោផ្សាយពាណិជ្ជកម្មដែលអនុវត្តផ្ទុយពីប្រកាសរបស់ក្រសួង ឱ្យកែតម្រូវខ្លឹមសារឡើងវិញបានចំនួន៨៩កន្លែង។ ការផ្តល់សេវាកម្មលើវិស័យវប្បធម៌ក្នុងការិយាល័យច្រកចេញចូលតែមួយ គឺបានលិខិតអនុញ្ញាត ប័ណ្ណអនុញ្ញាតចំនួន៣៣ច្បាប់។

មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកោះកុង ៖

ការងារបេតិកភណ្ឌរូបី ៖ បានចុះពិនិត្យថែរក្សាសម្អាតទីកន្លែងបុស្បកព្រះអង្គគោកធ្លក ចេតីយ ឃុនឆាង ទីលានទាត់សី វិមានស្ពប អណ្តូងថ្ម និងវត្ថុបុរាណដែលស្រង់ចេញពីសំពៅលិចជាប្រចាំ។

ការងារបេតិកភណ្ឌអរូបី ៖ ក្រុមសិល្បៈបានចេញសម្តែងនៅខេត្តច័ន្ទបុរី ប្រទេសថៃ ក្នុងទិវាមិត្តភាព កម្ពុជា-ថៃចំនួន០១លើក និងបានទទួលក្រុមនិស្សិតមកពីប្រទេសថៃ មកបំពេញទស្សនកិច្ចសិក្សាស្រាវជ្រាវ នូវភ្លេងប្រពៃណីខ្មែរចំនួន០១លើក។ ធ្វើការត្រួតពិនិត្យអាជីវកម្មភាពយន្ត អ៊ិនធើណេត រោងការ្វៃចំនួន០៨ លើកនៅស្រុកមណ្ឌលសីមា និងក្រុងខេមរភូមិន្ទ។ ចុះត្រួតពិនិត្យអាជីវកម្មចាក់ពុម្ពស៊ីម៉ង់ត៍ អាជីវកម្មស្មាច់ ម្នាងសិលា និងអាជីវកម្មឆ្លាក់ពីឈើនៅក្រុងខេមរភូមិន្ទចំនួន០៤លើក។ ចុះពិនិត្យស្លាកសញ្ញា ផ្ទាំងផ្សាយ ពាណិជ្ជកម្មលើកថ្មីនៅឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា។ ចុះណែនាំអាជីវករដែលលើកស្លាកសញ្ញា ឱ្យមកធ្វើ ច្បាប់ចំនួន១១កន្លែង នៅក្រុងខេមរភូមិន្ទ និងណែនាំដល់អាជីវករឱ្យមកសុំច្បាប់អនុញ្ញាតពីការិយាល័យ ច្រកចេញចូលតែមួយ។ ចេញប័ណ្ណអនុញ្ញាតប្រកបអាជីវកម្មលើកស្លាកសញ្ញាចំនួន១១កន្លែង-សម្អាងការ ចំនួន០២កន្លែង-ជួល លក់ស៊ីឌីចំនួន០១កន្លែង និងអ៊ុតសក់ចំនួន០១កន្លែង និងលិខិតអនុញ្ញាតបញ្ចាំងភាពយន្ត វីដេអូលក់សំបុត្រចំនួន០១លើក និងបញ្ចាំងភាពយន្ត វីដេអូកំដរពិធីបុណ្យផ្សេងៗចំនួន០១លើក។

មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពង់ស្ពឺ ៖

ការងារបេតិកភណ្ឌរូបី ៖ បានចុះសហការជាមួយសហគមន៍សែនមនោរម្យ ឃុំហោងសំណំ ស្រុកឱរ៉ាល់ ដើម្បីត្រួសត្រាយព្រៃ បោសសម្អាតទីតាំងរមណីយដ្ឋានបុរាណវិទ្យាភ្នំចាស់ និងបានធ្វើការប្រជុំជាមួយ អាជ្ញាធរឃុំ និងសហគមន៍ឱ្យជួយការពារថែរក្សា សម្អាត និងមានអ្នកប្រចាំការឱ្យបានជាប់ជាប្រចាំ។ សហការ ជាមួយមន្ត្រីជំនាញនាយកដ្ឋានបុរាណវិទ្យា និងបុរេប្រវត្តិវិទ្យា ចុះបោះបង្គោលដែនការពារស្ថានីយ៍ បុរាណ ចំនួន០៣កន្លែងគឺ ស្ថានីយ៍បុរាណទួលប្រាសាទ នៅសង្កាត់កណ្តោលដុំ ក្រុងច្បារមន ស្ថានីយ៍បុរាណឬស្សីសាញ់ នៅឃុំសំរោងទង ស្រុកសំរោងទង និងទួលអង្គបុរាណតាព្រហ្មយាយមៅ(ថ្មបាំង) នៅឃុំត្រពាំងគង ស្រុកសំរោងទង។ បានចុះទៅស្រុកឱរ៉ាល់ ដើម្បីពិនិត្យមើលបរិស្ថានរមណីយដ្ឋានបុរាណវិទ្យាភ្នំចាស់ និងបានចុះបញ្ជីទួលអង្គបុរាណចំនួន៥១ទួលអង្គ នៅស្រុកឧដុង្គ។ ចុះទៅពិនិត្យមើលកុលាលភាជន៍ចំនួន០១គ្រួរ ដែលប្រជាពលរដ្ឋប្រទះឃើញក្នុងល្អាងភ្នំពិស្ស ក្នុងស្រុកថ្ពង ហើយយករូបនេះទៅប្រគេនវត្តភ្នំពិស្សទុកជា សក្ការៈ។ ប្រជុំផ្សព្វផ្សាយច្បាប់ការពារបេតិកភណ្ឌវប្បធម៌នៅស្រុកសំរោងទង រយៈពេលមួយថ្ងៃមានប្រជា ពលរដ្ឋ ចូលរួមចំនួន១០៥នាក់។ បានចុះសហការជាមួយអាជ្ញាធរដែនដី និងសហគមន៍ភូមិក្អែកពង ស្រុកភ្នំស្រួច ដើម្បីកាប់ឆ្ការព្រៃដែលដុះលើប្រាសាទ និងធ្វើការទល់ទ្រប្រាសាទឱ្យមានភាពរឹងមាំ។ ភ្ញៀវទេសចរណ៍ចូល ទស្សនាសារមន្ទីរនរបុរីមានចំនួន៩.០៤៦នាក់ ក្នុងនោះអន្តរជាតិចំនួន៣០នាក់។

ការងារបេតិកភណ្ឌអរូបី ៖ បានរៀបចំពិធីប្រារព្ធទិវាវប្បធម៌ជាតិ ០៣ មីនា លើកទី១៥ និងបើក មហោស្រពសិល្បៈមហាជន ឆ្នាំ២០១៣ ក្រោមអធិបតីភាព ឯកឧត្តម សំរាំង កំសាន្ត រដ្ឋលេខាធិការ ក្រសួង វប្បធម៌ និងវិចិត្រសិល្បៈ នៅមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពង់ស្ពឺ។ រៀបចំបើកមហោស្រពសិល្បៈ មហាជនទូទាំងខេត្តឆ្នាំ២០១៣ មានក្រុមសិល្បៈចូលរួមចំនួន១៥ក្រុមគឺ ទម្រង់ភ្លេងប្រពៃណី៤ក្រុម-ឆៃយ៉ាំ ២ក្រុម-អាយ៉ៃរឿង២ក្រុម-របាំ៤ក្រុម និងល្ខោននាដកម្ម៣ក្រុម ការជ្រើសរើសទទួលលទ្ធផលគឺ ក្នុងទម្រង់ នីមួយៗទទួលបានពីលេខ១ ដល់លេខ៣ ដោយមានថវិការអមជាមួយ។ បានចូលរួមប្រណាំងគោលឿន អបអរបុណ្យចូលឆ្នាំថ្មី មានគោចំនួន៣៦នឹម។ បញ្ជូនគ្រូរបាំចុះទៅបណ្តុះបណ្តាលសិល្បៈរបាំនៅមណ្ឌល កុមារកំព្រាខេត្តកំពង់ស្ពឺ មណ្ឌលកុមារកំព្រាអង្គការក្តីសង្ឃឹមថ្មី នៃកុមារកម្ពុជា នៅស្រុកសំរោងទង និងនៅ សាលាបឋមសិក្សាសម្បត្តិឧត្តម នៅស្រុកគងពិសី។ ចុះតាមដានមើលការបញ្ចាំងភាពយន្តវីដេអូតាមហាង ការ្វៃចំនួន២៦លើកនៅក្រុងច្បារមន ស្រុកភ្នំស្រួច ស្រុកសំរោងទង និងស្រុកឧដុង្គ។ ចុះត្រួតពិនិត្យ

និងពង្រឹងអាជីវកម្ម សេវាកម្មសិល្បៈសូនរូប និងសិល្បៈសិប្បកម្មឱ្យរក្សាតាម ក្បួនខ្នាតក្បាច់ចម្លាក់ខ្មែរ នៅស្រុកសំរោងទង ស្រុកភ្នំស្រួច ស្រុកឧដុង្គ និងស្រុកគងពិសី និង ចុះពង្រឹងដល់សហគមន៍ដែលបណ្តុះបណ្តាលរួចអំពីរុក្ខជាតិវល្លិ៍ និងស្លឹក នៅស្រុកគងពិសីចំនួន០២លើក។ ការិយាល័យច្រកចេញចូលតែមួយ បានអនុញ្ញាតច្បាប់ប្រកបអាជីវកម្មលើវិស័យវប្បធម៌ និងវិចិត្រសិល្បៈសរុបចំនួន២២ច្បាប់ ទទួលថវិកាសរុបចំនួន១.២៦៣.០០០រៀល និងបានបង់ចូលថវិការដ្ឋ។

មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពង់ឆ្នាំង ៖

ការងារបេតិកភណ្ឌរូបី ៖ បានសហការជាមួយអាជ្ញាធរមូលដ្ឋានគ្រប់ថ្នាក់ និងប្រជាពលរដ្ឋកំណត់ព្រំប្រទល់ទូលបុរាណចំនួន៤៣កន្លែង។ សហការជាមួយប្រតិភូវិទ្យាស្ថាន ណាវ៉ា ប្រទេសជប៉ុន និងនិស្សិតកម្ពុជា ចុះធ្វើកំណាយនៅឃុំលង្វែក ស្រុកកំពង់ត្រឡាចចំនួន០២លើក។ សហការជាមួយអាជ្ញាធរមូលដ្ឋានទប់ស្កាត់ការជីកកកាយនៅតំបន់ប្រវត្តិសាស្ត្រ ក្នុងស្រុកកំពង់ត្រឡាច (អតីតខ្សែក្រវ៉ាត់ការពារក្រុងលង្វែក) ចំនួន០៣ករណី និងកំពុងធ្វើស្លាកសញ្ញាបោះនៅទីទូលបុរាណ។ សហការជាមួយឆ្មាំប្រាសាទចុះត្រួតពិនិត្យ និងសម្អាតជុំវិញបរិវេណប្រាសាទចំនួន២៦លើក និងត្រួតពិនិត្យការហូរច្រោះចូលគ្រឹះប្រាសាទ នៅប្រាសាទកំពង់ព្រះ។ ចុះពិនិត្យវត្ថុបុរាណដែលប្រជាពលរដ្ឋរាយការណ៍ចំនួន០៤លើក លទ្ធផលមិនសម្រេច មូលហេតុវត្ថុទាំងនោះមានវត្ថុធាតុដើមជាស៊ីម៉ង់ត៍។ នៅវត្តកំពង់ត្រឡាចលើមានភ្ញៀវទេសចរណ៍ជាតិ-អន្តរជាតិចំនួន ៦.៨៧៦នាក់ ចូលទស្សនារូបគំនូរបុរាណក្នុងព្រះវិហារ ។

ការងារបេតិកភណ្ឌអរូបី ៖ បានរៀបចំទិវាវប្បធម៌ជាតិ ០៣ មីនា លើកទី១៥ និង បើកមហោស្រពចម្រៀងខ្មែរសកល ឆ្នាំ២០១៣ ក្រោមអធិបតីភាព ឯកឧត្តម អ៊ុក សុជាតិ រដ្ឋលេខាធិការ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ នៅសាលាខេត្តកំពង់ឆ្នាំង។ បញ្ជូនក្រុមសិល្បៈមហាជន៣ក្រុមចូលរួមមហោស្រព ថ្នាក់ភូមិភាគ នៅរាជធានីភ្នំពេញ។ ចុះត្រួតពិនិត្យការបញ្ចាំងវីដេអូតាមរោងការ ហ្វេ និងអាហារដ្ឋានផ្សេងៗ ចំនួន៦៥លើក-ភាពយន្តជាលក្ខណៈឯកជនចំនួន១៨លើក-ការបញ្ចាំងប្រគុំតន្ត្រីរបស់ក្រុមហ៊ុនលក់ផលិតផល ផ្សេងៗចំនួន១៥លើក និងសហការជាមួយមជ្ឈមណ្ឌលវប្បធម៌បាវាំងបញ្ចាំងភាពយន្តចល័តជូនប្រជាពលរដ្ឋ ទស្សនាចំនួន០២លើក។ ចេញច្បាប់អនុញ្ញាតដល់សេវាកម្មភាពយន្ត-វីដេអូចំនួន៤៩ច្បាប់។ ចុះស្រង់ស្ថិតិ និងផ្សព្វផ្សាយអំពីក្បួនខ្នាតចម្លាក់ក្បាច់ខ្មែរ និងបានបំផុសចលនាក្រុមសិប្បកម្មចូលរួមមហោស្រពចម្លាក់ខ្មែរ "រាន្តទេព្តា" នៅរាជធានីភ្នំពេញ។ បានស្រាវជ្រាវជ្រើសរើសវីរៈសិល្បករ ដើម្បីបញ្ចូលជាមរតកមនុស្សរស់ចំនួន០១នាក់-បានតាក់តែងអត្ថបទក្បាច់គុនខ្មែរ០១អត្ថបទ-រឿងនិទានទាក់ទងនឹងប្រាសាទស្រី ប្រាសាទប្រុស០១អត្ថបទ និងប្រាសាទថ្មមប្តី០១អត្ថបទ-សារគាឃុំច្រណូក០១អត្ថបទ-ប្រវត្តិភ្នំរាប់បាត្រ០១អត្ថបទ និងស្រាវជ្រាវប្រពៃណីម៉ាឡុតរបស់ជនជាតិចាម០១អត្ថបទ។ ច្រកចេញចូលតែមួយស្រុកកំពង់ឆ្នាំង បានចេញច្បាប់អនុញ្ញាតស្លាកយីហោចំនួន៨៥កន្លែង-ថតរូបចំនួន០៧កន្លែង-សម្អាងការចំនួន០៥កន្លែង និងអ៊ុតសក់ធ្វើក្រចកចំនួន១០កន្លែង ។

មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តពោធិសាត់ ៖

ការងារបេតិកភណ្ឌរូបី ៖ បានចុះត្រួតពិនិត្យបឹងទន្លេអុំ និងធ្វើស្ថិតិវត្ថុបុរាណក្រៅឃ្លាំងនៅវត្តព្រះធាតុ។ ចុះត្រួតពិនិត្យរូបចម្លាក់ថ្មកែវដែលធ្វើថ្មី និងអនុញ្ញាតការនាំចេញរូបចម្លាក់ព្រះពុទ្ធចំនួន០១រូប (កម្ស់១ម៉ែត្រ ២តឹក) និងបាទាំងពេជ្រ (កម្ស់១ម៉ែត្រ ២តឹក)។ ទទួលរបចម្លាក់ចំនួន១០រប ពីឧត្តម

សេនីយ៍ទោ ចាន់ សុភារុធ មករក្សាទុកនៅសារមន្ទីរខេត្ត។ រៀបចំវត្ថុបុរាណជាប្រនៀល (យោនី) មករក្សាទុកនៅក្រៅឃ្លាំងសម្រាប់គោរពបូជារបស់អ្នកស្រុកនៅឃុំស្រែស្តុក ស្រុកកណ្តៀង។ ចុះទៅបោះបង្គោលព្រំទីទួលបុរាណ នៅវត្តសុវណ្ណស្លាកែត ស្ថិតនៅឃុំបឹងកន្ធូត ស្រុកក្រគរចំនួន០១លើក និងចុះត្រួតពិនិត្យទីទួលបុរាណ នៅឃុំក្បាលត្រាច ស្រុកក្រគរចំនួន០១លើក។ ចុះទៅស្រុកវាលវែង ដើម្បីពិនិត្យទីតាំងប្រាសាទបុរាណ លទ្ធផលពិនិត្យឃើញថា មានណ្ឌាងធម្មជាតិចំនួន០៩កន្លែង មានថ្មធំៗដែលមានលក្ខណៈជារមណីយដ្ឋានធម្មជាតិ។ បានអមដំណើរប្រតិភូក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ចុះពិនិត្យណ្ឌាងបុរេប្រវត្តិ នៅឃុំក្រពើពីរ ស្រុកវាលវែង។ ចុះត្រួតពិនិត្យការជីកកាយដីជួសជុលផ្លូវលំ នៅឃុំស្រែស្តុក ត្រង់ចំណុចបឹងទន្លេអុំចំនួន០១លើក លទ្ធផលទទួលបានគឺ ដីនៅបឹងទន្លេអុំត្រង់ចំណុចជ្រុងខាងជើងឈាងខាងកើត ក្រោយស្នាក់ការគណបក្សប្រជាជនឃុំ ត្រូវបានជីកអស់ចំនួន១០៥ឡាន ដើម្បីយកអាចម៍ដីមកជួសជុលផ្លូវលំចំនួន០៣កន្លែង ។

ការងារបេតិកភណ្ឌអរូបី ៖ បានចុះទៅបង្ហាត់សិល្បៈដល់កុមារកំព្រាខេត្ត-សិល្បៈកុមារអង្គការចេរភាព និងសិល្បៈមហាជនសរុបបានចំនួន៤២លើក។ ចុះតាមដានការចាក់បញ្ចាំងវីដេអូតាមហាងកាហ្វេចំនួន២៣ លើក និងត្រួតពិនិត្យទិដ្ឋាការតាមតូបលក់ស៊ីឌី វីស៊ីឌី បានចំនួន១៨លើក (ភាគច្រើនស៊ីឌី វីស៊ីឌី ដែលគ្មានទិដ្ឋាការជាផលិតកម្មក្រៅប្រទេស)។ ចុះស្រង់ និងជម្រុញអាជីវករឱ្យមកធ្វើច្បាប់លើវិស័យវប្បធម៌ នៅស្រុកបាកានចំនួន០៣លើក និងស្រុកក្រគរចំនួន០៤លើក ។

មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តបាត់ដំបង ៖

ការងារបេតិកភណ្ឌរូបី ៖ បានទំនាក់ទំនងជាប់ជានិច្ចជាមួយក្រុមការងាររបស់សុរិយោដី ដែលធ្វើការវាស់វែងដីនៅភូមិប្រគាប ដើម្បីរក្សាទុកជាសម្បត្តិបេតិកភណ្ឌជាតិ និង ដោះស្រាយទំនាស់ដីទួលបុរាណក្រៃព័ន្ធ នៅសង្កាត់ស្លាកែត ក្រុងបាត់ដំបង រួចជាស្ថាពរ។ ចុះកំណត់ទួលបុរាណបានចំនួន០៨ទួលគឺ នៅស្រុកថ្មគោល និងស្រុករតនមណ្ឌល។ បានទៅផ្តិតមេដៃទទួលជាកម្មសិទ្ធិទួលបុរាណចំនួន១៩ទួល ទុកជាសម្បត្តិបេតិកភណ្ឌជាតិ។ ចុះទៅឃុំអន្លង់រុន ស្រុកថ្មគោល ដើម្បីពិនិត្យ និងទទួលយកវត្ថុបុរាណចំនួន០២ដុំ គឺ "ស្នាណាទ្រានី" និង "ជើងទម្រលឹង្គ" យកមករក្សាទុកក្នុងសារមន្ទីរខេត្ត។ អនុញ្ញាតឱ្យនាំវត្ថុសិល្បៈថ្មីចេញក្រៅខេត្តចំនួន៩០រូប។ ភ្ញៀវចូលទស្សនាសារមន្ទីរខេត្តចំនួន១.២៧០នាក់ក្នុងនោះអន្តរជាតិចំនួន១៧១នាក់។ បានបោះពុម្ពសៀវភៅមគ្គុទេសក៍ ស្តីពីសមុច្ច័យសារមន្ទីរខេត្តជាភាសាខ្មែរបានចំនួន១០០ក្បាល។

ការងារបេតិកភណ្ឌអរូបី ៖ បានរៀបចំពិធីប្រារព្ធទិវាវប្បធម៌ជាតិ ០៣ មីនា លើកទី១៥ និងបើកមហោស្រពសិល្បៈមហាជនឆ្នាំ២០១៣។ ហាត់រំលឹករបាំចាស់ត្រៀមសម្រាប់កម្មវិធីផ្សេងៗ និងរៀបចំចងក្រងឯកសារតម្លើងរបាំសេះប្រុស និងសរសេរអត្ថបទឡោនអាយ៉ងបាន២ឈុត។ បានចុះបណ្តុះបណ្តាលពីការតែងនិពន្ធ-ដឹកនាំរឿង និងការសម្តែងដល់អង្គការទស្សនពិភពលោកបានចំនួន០៣វគ្គ រយៈពេល៩ថ្ងៃ មានសិក្ខាកាមចំនួន១០៦នាក់។ ចុះទៅត្រួតពិនិត្យកន្លែងលក់ស៊ីឌី-វីស៊ីឌីខុសច្បាប់ចំនួន០៥កន្លែង ដកហូតថាសខុសច្បាប់ចំនួន១.២៣៦បន្ទះ នៅស្រុកមោងឬស្សី។ ចុះទៅធ្វើការសាកសួរ និងធ្វើកំណត់ហេតុពីការចុះបង្ក្រាបផ្ទះអាជីវកម្មបញ្ចុលសម្លេងរឿងភាគថៃចំនួន០៣កន្លែង និងអញ្ជើញអាជីវករចំនួន០៣នាក់ មកធ្វើការណែនាំ ស្តីពីការប្រកបអាជីវកម្មគ្មានច្បាប់អនុញ្ញាត។ បានចុះធ្វើការណែនាំពីការធ្វើច្បាប់អាជីវកម្មសិប្បកម្មដល់អាជីវករក្នុងក្រុងបាត់ដំបង។ បណ្ណាល័យខេត្តបានបើកទ្វារជូនសាធារណៈជនចូលអានរៀងរាល់ថ្ងៃលើកលែងថ្ងៃឈប់សំរាក។ ការិយាល័យច្រកចេញចូលតែមួយ (ក្រុងបាត់ដំបង និងស្រុកបរវេល) បានចេញលិខិតអនញ្ញាតចំនួន១៦៧សេវា ។

មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តប៉ៃលិន ៖

ការងារបេតិកភណ្ឌរូបី ៖ បានត្រួតពិនិត្យ និងថែរក្សាចេតិយភ្នំយ៉ាត និងកន្លែងកសាងប្រាសាទប្រាំពីរជាន់បានចំនួន០៥លើក ។

ការងារបេតិកភណ្ឌអរូបី ៖ បានរៀបចំពិធីប្រារព្ធទិវាវប្បធម៌ជាតិ ០៣ មីនា លើកទី១៥ និង បើកមហោស្រពសិល្បៈមហាជន ឆ្នាំ២០១៣ ក្រោមអធិបតីភាព ឯកឧត្តម ម៉ី មគ្គ អភិបាលរងខេត្តប៉ៃលិន នៅមន្ទីរវប្បធម៌ខេត្ត។ ចុះស្រង់ស្ថិតិ និងចុះផ្សព្វផ្សាយដល់អាជីវករជួល-លក់ឌីសក្នុងក្រុងប៉ៃលិនឱ្យធ្វើច្បាប់អាជីវកម្ម នៅច្រកចេញចូលតែមួយវិញ ព្រោះក្រសួងវប្បធម៌ និងវិចិត្រសិល្បៈបានធ្វើប្រតិភូកម្មមកការិយាល័យច្រកចេញចូលតែមួយហើយ។ បន្តហាត់ក្បាច់បាត និងរបាំ ដូចជារបាំក្ងោក គោះត្រឡោក និងកន្សែងស្នេហ៍រៀងរាល់សប្តាហ៍។ ចុះត្រួតពិនិត្យ និងធ្វើការណែនាំពីក្បួនខ្នាតចម្លាក់ខ្មែរដល់អាជីវករដែលបើកអាជីវកម្មផ្នែកសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម។ ចេញច្បាប់អនុញ្ញាតអាជីវកម្មសម្ពាធការ អ៊ុតសក់ចំនួន០២កន្លែង នៅស្រុកសាលាក្រៅ។ ការិយាល័យច្រកចេញចូលតែមួយបានទទួលពាក្យស្នើសុំ និងចេញអាជ្ញាប័ណ្ណអនុញ្ញាតរយៈពេលខ្លីចំនួន០៦អាជ្ញាប័ណ្ណ និងរយៈពេលវែងចំនួន០៣អាជ្ញាប័ណ្ណ ។

មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តបន្ទាយមានជ័យ ៖

ការងារបេតិកភណ្ឌរូបី ៖ បានចុះជាប្រចាំជាមួយក្រុមយុវជនស្ម័គ្រចិត្តសម្តេចតេជោ ដែលចុះវាស់វែងដីធ្លីជូនប្រជាពលរដ្ឋ នៅស្រុកថ្មពួក ស្រុកភ្នំស្រុក ស្រុកស្វាយចេក និងស្រុកព្រះនេត្រព្រះ ដើម្បីពិនិត្យមើលក្រែងមានប៉ះពាល់ដល់ទួលបុរាណ ស្ថានីយបុរាណ។ ចុះបញ្ជីក្បាលដីទួលបុរាណ និងកំណត់ព្រំដែនស្ថានីយបុរាណនៅទូទាំងខេត្តសម្រេចបាន៦០ភាគរយ។ ចាក់ដីផ្លូវចូល និង ក្នុងបរិវេណសារមន្ទីរទេពកោសា-ស្នាយដើម្បីងាយស្រួលសម្រាប់ភ្ញៀវទេសចរណ៍មកទស្សនា។ ភ្ញៀវចូលទស្សនាសារមន្ទីរខេត្តសរុបចំនួន១០៧នាក់ (អន្តរជាតិ១៥នាក់) សារមន្ទីរទេពកោសា-ស្នាយចំនួន១៥៧នាក់ (អន្តរជាតិ២២នាក់) ប្រាសាទបន្ទាយឆ្មារ សរុបចំនួន៣.៤៥៣នាក់ (អន្តរជាតិ៨៥៣នាក់) និង ប្រាសាទបន្ទាយទ័ពចំនួន២៣៥នាក់ (អន្តរជាតិ៣៥នាក់)។

ការងារបេតិកភណ្ឌអរូបី ៖ បានរៀបចំពិធីបើកមហោស្រពសិល្បៈមហាជន ឆ្នាំ២០១៣ នៅក្នុងបរិវេណ ផ្សារពាត្រី TM។ ចុះស្រង់ស្ថិតិ និងត្រួតពិនិត្យរោងភាពយន្តចំនួន០១កន្លែង-កន្លែងជួលលក់ស៊ីឌីចំនួន៥០ កន្លែង និងកន្លែងបញ្ចាំងវីដេអូចល័តចំនួន១១កន្លែង និងបានត្រួតពិនិត្យវត្ថុសិល្បៈនាំចេញពីខេត្តទៅតាមគោលដៅក្នុងប្រទេសបានចំនួន១៨លើក។ មន្ត្រីការិយាល័យគ្រប់ជំនាញបាននឹងកំពុងចុះមូលដ្ឋានស្រុក ដើម្បីស្រង់ស្ថិតិ ត្រួតពិនិត្យអាជីវកម្មប្រកបអាជីវកម្មលើវិស័យវប្បធម៌ និងវិចិត្រសិល្បៈតាមស្រុកនានាក្នុងខេត្ត។

មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តឧត្តរមានជ័យ ៖

ការងារបេតិកភណ្ឌរូបី ៖ បានចុះទៅសិក្សាលើផលប៉ះពាល់ទៅលើស្ថានីយបុរាណដែលស្ថិតនៅក្នុងបរិវេណផ្ទៃដីកសិកម្ម នៃក្រុមហ៊ុនឯកជន នៅស្រុកអន្លង់វែង។ ចុះស្រាវជ្រាវរុករកទួលប្រាសាទ និងកំណត់ទីតាំងដោយម៉ាស៊ីន GPS ចំនួន១៣កន្លែង នៅស្រុកត្រពាំងប្រាសាទ និងតាមទួលប្រាសាទ នៅស្រុកអន្លង់វែង និងចូលរួមស្រាវជ្រាវរកឃើញទួលប្រាសាទថ្មីចំនួន០៤ទួលគឺ ទួលប្រាសាទថ្មី ទួលបង្គោលគោក គ្រួស ទួលប្រាសាទគួយ និងទួលប្រាសាទប្រិយ នៅស្រុកអន្លង់វែង។ បានចូលរួមវាស់ប្លង់ស្ថានីយបុរាណដើម្បីធ្វើប្លង់កម្មសិទ្ធរបស់រដ្ឋចំនួន០៣ទួល (ទួលប្រាសាទគ្រឹះវែរយៀវ និងទួលប្រាសាទគោកសំរោង បទួល

គោកព្រះសាម៉ែរ) នៅស្រុកសំរោង និង ចូលរួមផ្តិតមេដៃធ្វើប្លង់កម្មសិទ្ធិដីរដ្ឋលើទូលប្រាសាទរហាលត្រាច។ ចុះត្រួតពិនិត្យប្រាសាទព្រហ្មកិលដែលប្រជាពលរដ្ឋបានដាក់វានទេព្តានៅលើគ្រឹះថ្មប្រាសាទ និងបានធ្វើការណែនាំឱ្យយកចេញវិញ។ ចុះត្រួតពិនិត្យប៉ាណ្ដា នៅទូលប្រាសាទកប់គង និងស្លាកសញ្ញាទូលប្រាសាទភ្នំដី ដែលប៉ះពាល់ទៅលើគម្រោងស្ពានឡើងវិញផ្លូវជាតិលេខ៥៦។ ចុះត្រួសត្រាយព្រៃនៅតាមប្រាសាទ និងទូលប្រាសាទនានានៅស្រុកត្រពាំងប្រាសាទ ស្រុកចុងកាល់ និងក្រុងសំរោង។ ចុះវាស់វែងដីធ្វើប្លង់កម្មសិទ្ធសាធារណៈរបស់រដ្ឋលើទូលប្រាសាទស្រះព្រិចជាមួយមន្ត្រីសូរិយោដី នៅសង្កាត់កូនក្រៀល ក្រុងសំរោង។ សហការជាមួយនគរបាលការពារបេតិកភណ្ឌ ក្នុងការចុះទប់ស្កាត់សកម្មភាពជីកកាយដីជើងទេរស្រះបុរាណភ្នំដី ព្រមទាំងធ្វើការឃាត់ខ្លួនមនុស្សចំនួន០៨នាក់ និងសម្ភារៈមួយចំនួន ដោយធ្វើការអប់រំ និងធ្វើកិច្ចសន្យាចាក់ដីបំពេញកន្លែងដែលបានជីក និងបានឱ្យត្រឡប់ទៅផ្ទះវិញ។ ចុះបញ្ជីសារពើភណ្ឌវត្ថុសិល្បៈនៅក្រៅឃ្លាំងចំនួន០២ នៅស្រុកបន្ទាយអំពិល ។

ការងារបេតិកភណ្ឌអូរបី ៖ បានរៀបចំពិធីប្រារព្ធទិវាវប្បធម៌ជាតិ ០៣ មីនា លើកទី១៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម ហ៊ឹម ឆែម រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ នៅសាលប្រជុំធំសាលាខេត្តឧត្តរមានជ័យ។ ចូលរួមមហោស្រពសិល្បៈមហាជនភូមិភាគ៦ ទទួលចំណាត់ថ្នាក់លេខ១។ បានចុះពិនិត្យអាជីវកម្មស្នាដៃភាពយន្ត-វីដេអូ និងចុះណែនាំអាជីវករជួលមេក្រូ ធុងបាស់ វីដេអូចល័ត និងស៊ីឌី-វីស៊ីឌីឲ្យគោរពច្បាប់នៅក្រុងសំរោង ស្រុកបន្ទាយអំពិល ស្រុកអន្លង់វែង និងស្រុកត្រពាំងប្រាសាទ។ ធ្វើរបាយការណ៍ជូនគណៈកម្មការអន្តរក្រសួងបង្ក្រាបបទល្មើសភាពយន្ត-វីដេអូ ស្តីពីក្រុមហ៊ុនសាន់ដេ ចុះចាប់ថាស និងកុំព្យូទ័របញ្ចូលបទភ្លេងជាមួយព្រះរាជអាជ្ញា ដោយមិនបានសហការជាមួយមន្ទីរវប្បធម៌។ ចុះពិនិត្យ និងណែនាំដល់សកម្មភាពធ្វើពុម្ពស៊ីម៉ង់ និង សកម្មភាពធ្វើពុម្ពរានទេព្តាតាមរចនាបថខ្មែរ នៅស្រុកអន្លង់វែង ស្រុកចុងកាល់ ស្រុកត្រពាំងប្រាសាទ និងក្រុងសំរោង។ ចុះពិនិត្យគុណភាពសិល្បៈមហាជន នៅក្រុងសំរោង និងស្រុកត្រពាំងប្រាសាទ។ ចងក្រងឯកសារ ស្តីពីពិធីជញ្ជាត់ព្រលឹង នៅក្រុងសំរោង ដើម្បីតម្លើងរបាំថ្មី និងចុះសិក្សាស្រាវជ្រាវអំពីពិធីបញ្ចូលមេមត់ នៅស្រុកចុងកាល់។ ចុះពិនិត្យជាប្រចាំការដាក់តាំងស្លាកយីហោផ្ទាំងផ្សាយពាណិជ្ជកម្មនានាទូទាំងខេត្ត ។

មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តព្រះវិហារ ៖

ការងារបេតិកភណ្ឌរូបី ៖ បានចុះវាស់វែង និងកំណត់ព្រំដីតំបន់អភិរក្សប្រាសាទបុរាណជាមួយក្រុមការងារបច្ចេកទេសសុរិយោដី និងយុវជនស្ម័គ្រចិត្តរបស់សម្តេចតេជោ នៅស្រុកគូលែនចំនួន០២កន្លែង ស្រុករវៀងចំនួន០២កន្លែង និងស្រុកត្បែងមានជ័យចំនួន០១កន្លែង។ ចុះទៅពិនិត្យនូវការបិទផ្សាយដីតំបន់អភិរក្សប្រាសាទក្រពុំឈូក នៅស្នាក់ការក្រុមការងារបច្ចេកទេសសុរិយោដី និងយុវជនស្ម័គ្រចិត្តរបស់សម្តេចតេជោ នៅឃុំរំដោះ ស្រុករវៀងចំនួន០១លើក។ ប្រធានក្រុមអភិរក្សប្រចាំស្រុកគូលែន បានជូនដំណើរក្រុមការងារបច្ចេកទេសសុរិយោដី និងយុវជនស្ម័គ្រចិត្តរបស់សម្តេចតេជោទៅកំណត់ព្រំ និងបោះបង្គោលបំពេញសាលាកប័ត្រដីតំបន់អភិរក្សប្រាសាទបុរាណនៅឃុំស្រយ៉ង់បានចំនួន០៧កន្លែង និងដឹកនាំក្រុមអភិរក្សទាំងអស់ចុះទៅត្រួតពិនិត្យអំពីសកម្មភាពជនទុច្ចរិតលួចកាប់ឈើនៅក្នុងតំបន់អភិរក្សប្រាសាទខ្នាសែនកែវ ស្ថិតនៅឃុំភ្នំពេញ ស្រុកគូលែន។ ចូលរួមធ្វើប័ណ្ណកម្មសិទ្ធិដីប្រាសាទចំនួន១៧កន្លែង និងទទួលប័ណ្ណរឹងចំនួន០៦កន្លែង។ បានទទួលវត្ថុបុរាណចំនួន០៧ដុំ (០២ដុំពីមន្ត្រីការិយាល័យវប្បធម៌ និងវិចិត្រសិល្បៈស្រុករវៀង និង០៥ដុំទៀតពីប្រជាពលរដ្ឋ)។ ឆ្មាំត្រួសត្រាយព្រៃតាមប្រាសាទនានាបានចំនួន១១៧.៣៦០ម៉ែត្រការ៉េ និងភ្ញៀវចូលទស្សនាតាមប្រាសាទនានាសរុបចំនួន២.៩៨៩នាក់ អន្តរជាតិចំនួន១៨៨នាក់។

ការងារបេតិកភណ្ឌអរូបី ៖ បានរៀបចំពិធីប្រារព្ធទិវាវប្បធម៌ជាតិ ០៣ មីនា លើកទី១៥ និង បើកមហោស្រពសិល្បៈមហាជន ឆ្នាំ២០១៣ ក្រោមអធិបតីភាព ឯកឧត្តម ម៉េង ហួរ រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ នៅមន្ទីរវប្បធម៌ ខេត្តព្រះវិហារ។ ក្រុមសិល្បៈបានទៅសម្តែងក្នុងទិវារំលឹកខួបអនុស្សាវរីយ៍ថ្ងៃជ័យជំនះ ០៧ មករា និងការដាក់តាំងពិព័ណ៌រួមគ្នារវាងកម្ពុជា និងថៃ នៅក្នុងខេត្ត។ បានចេញទៅសម្តែងសិល្បៈនៅប្រទេសឡាវចំនួន០១លើក។ ចុះត្រួតពិនិត្យ និងស្រង់ស្ថិតិសិល្បៈភាពយន្ត ស្ថិតិសិល្បៈសូនរូប សិល្បៈសិប្បកម្ម និងស្ថិតិអភិវឌ្ឍវប្បធម៌។ អនុញ្ញាតច្បាប់អាជីវកម្មវិស័យវប្បធម៌នៅស្រុកសង្គមថ្មី ស្រុកជ័យសែន ស្រុកឆែប និងស្រុកគូលែន សរុបចំនួន២៥ច្បាប់។ ការិយាល័យច្រកចេញចូលតែមួយក្រុងព្រះវិហារ បានចេញលិខិតអនុញ្ញាតការប្រគុំតន្ត្រីស្រាបៀលីអូចំនួន០៥ថ្ងៃ និង តន្ត្រីស្រាបៀយីងដឹម០១ថ្ងៃ ។

មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តសៀមរាប ៖

ការងារបេតិកភណ្ឌរូបី ៖ បានសហការជាមួយអាជ្ញាធរឃុំ-ស្រុក ចុះទប់ស្កាត់ប្រជាពលរដ្ឋចំនួន០៨គ្រួសារ ដែលបានរំលោភជីកលុបត្រពាំងប្រិយ ជាត្រពាំងបុរាណ នៅឃុំនគរភាស ស្រុកអង្គរជុំ និងបានឱ្យធ្វើកិច្ចសន្យាបញ្ឈប់ការជីកលុបជាបន្ត និងសហការជាមួយអាជ្ញាធរឃុំជប់តាត្រាវ ចុះឃាត់បញ្ឈប់ការជីកគ្រឹះសាងសង់ព្រះវិហារថ្មី នៅលើទួលប្រាសាទ នៅឃុំជប់តាត្រាវ ស្រុកអង្គរធំ។ សហការជាមួយគណៈកម្មការចម្រុះ ចុះត្រួតពិនិត្យការបាត់បង់វត្ថុបុរាណចំនួន០៦មុខ ស្មើ២៩គ្រឿង នៅវត្តរាជបូណ៌ ក្នុងសង្កាត់សាលាកំរើក ក្រុងសៀមរាប។ សហការជាមួយអាជ្ញាធរស្រុកអង្គរធំ ចុះត្រួតពិនិត្យរូបបដិមាករចំនួន០២រូប ដែលរកឃើញនៅឃុំលាងដៃ ស្រុកអង្គរធំ បានប្រគល់ជូនអាជ្ញាធរអប្សរាដើម្បីរក្សាទុក។ សហការជាមួយមេភូមិចុះត្រួតពិនិត្យការរំលោភចាក់ដីលុបត្រពាំងវៀន (ត្រពាំងបុរាណ) ស្ថិតនៅសង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ពីប្រជាពលរដ្ឋចំនួន១១គ្រួសារ។ សហការជាមួយក្រុមប្រឹក្សាស្រុកពួក ចុះរុករកឃើញត្រពាំងបុរាណថ្មីចំនួន ០២កន្លែង មិនទាន់ចុះបញ្ជីសារពើភណ្ឌគឺ ត្រពាំងរាជ និងត្រពាំងរហាល នៅឃុំសំរោងយា។ សហការជាមួយអាជ្ញាធរអប្សរា អាជ្ញាធរស្រុកជីក្រែង ចុះត្រួតពិនិត្យការ សាងសង់លំនៅដ្ឋានមួយកន្លែងនៅលើដីទួលប្រាសាទវត្តលោកយួន ពីប្រជាពលរដ្ឋ និងធ្វើកិច្ចសន្យាបញ្ឈប់ការសាងសង់បន្ត ស្ថិតនៅឃុំកំពង់ក្តី ស្រុកជីក្រែង។ ចុះបញ្ជីសមុច្ច័យបុរាណវត្ថុ នៅវត្តរាជបូព៌ ក្រុងសៀមរាបបានចំនួន១៦៩រូប។ ចុះស្រង់ព័ត៌មានបុរាណវត្ថុក្រៅឃ្លាំងនៅតាមស្រុក-ក្រុងទាំង១២ក្នុងខេត្តបានចំនួន២១លើក រកឃើញបុរាណវត្ថុជាចម្លាក់បំណែកថ្មចំនួន១៧០ដុំ-សសរពេជ្រ០៨ដុំ-ផ្តែរ០៣ផ្ទាំង-សិលាចារឹក០២ផ្ទាំង និងដុំមូល៦៦ដុំ។ ផ្តល់លិខិតអនុញ្ញាតនាំចេញវត្ថុសិល្បៈចម្លងចំនួន៩៨ច្បាប់
ក្នុងនោះចរាចរក្រៅប្រទេសមានវត្ថុសិល្បៈចម្លងចំនួន១៤៣រូប។

ការងារបេតិកភណ្ឌអរូបី ៖ បានរៀបចំពិធីប្រារព្ធទិវាវប្បធម៌ជាតិ ០៣ មីនា លើកទី១៥ ឆ្នាំ២០១៣ នៅរោងមហោស្រពស្មាមញ្ញឹមអង្គរ និងបានរៀបចំប្រឡងចម្រៀងជាសកលបុរាណ-សម័យ ដើម្បីជ្រើសរើសទៅប្រឡងថ្នាក់ជាតិ។ ចុះជួយកែលម្អបច្ចេកទេសសម្តែង និងពង្រឹងការដឹកនាំដល់ក្រុមល្ខោនបាសាក់ឆាកកប្លែងកុមារវែន្លាត ក្រុមភ្លេងគ្រឹម និងភ្លេងធម្មឹង នៅក្រុងសៀមរាប ស្រុកពួក ស្រុកប្រាសាទបាគង និងស្រុកអង្គរជុំបានចំនួន៣១លើក និងចុះបង្ហាត់សិស្សសាលាសិល្បៈបុរាណខ្មែរ និងក្រុមសិល្បៈដែលគាំទ្រដោយអង្គការនានាបានចំនួន២៥០ថ្ងៃ។ ចុះត្រួតពិនិត្យ ណែនាំការថតចម្លងលក់-ជួលឌីស គ្រប់ប្រភេទ និងការបញ្ចាំងភាពយន្ត ចាក់ធុងបាស់រាំកំសាន្តឱ្យចូលរួមអនុវត្តតាមលិខិតបទដ្ឋានច្បាប់ នៅក្រុងសៀមរាប និងនៅតាមស្រុកបានចំនួន១០៦កន្លែង។ ចុះត្រួតពិនិត្យណែនាំកែលម្អដល់អាជីវករ-សិប្បករដែលកំពុងបម្រើសេវាកម្មទាក់ទងនឹងជំនាញសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម នៅផ្សារចាស់ ផ្សារកណ្តាលអង្គរ ផ្សារជាប់ត្រីកោណ ក្នុងក្រុងសៀមរាប និងក្នុងស្រុកសូទ្រនិគមចំនួន១១៦លើក។ ចុះត្រួតពិនិត្យទីតាំងអាជីវកររលើកស្ទាក់យីហោឱ្យអនុវត្តតឹមត្រូវតាមការណែនាំចំនួន៣១លើក និងរៈលើស្ទាក់យីហោខសការណែនាំចំនួន០៣

ផ្ទាំង នៅក្រុងសៀមរាប។ ចុះស្រាវជ្រាវប្រវត្តិល្បែងប្រជាប្រិយបានចំនួន០២គឺ ល្បែងបោះអង្គុញ និងល្បែងទាញព្រ័ត។ ការិយាល័យច្រកចេញចូលតែមួយក្រុងសៀមរាប បានផ្តល់ច្បាប់បម្រើសេវាកម្មរាំកំសាន្ត ផ្សព្វផ្សាយផលិតផល លើកស្លាកយីហោ ប្រគុំតន្ត្រី កាត់សក់ អ៊ុតសក់ លក់សៀវភៅ ថតរូប និងគ្រឿងបំពងសម្លេងចំនួន១៧៣ច្បាប់។

មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពង់ធំ ៖

ការងារបេតិកភណ្ឌរូបី៖ បានចុះបញ្ជីបុរាណវត្ថុក្រៅឃ្លាំងនៅតាមស្រុកចំនួន៧៧ដុំ។ សហការជាមួយ Waseda ធ្វើការជួសជុលប្រាសាទសំបូរព្រៃគុកគឺ បានជួសជុលរៀបឥដ្ឋជញ្ជាំងប្រាសាទ N1 ច្រកទ្វារខាងកើតចំនួន១១ស្រទាប់។ បានធ្វើច្រកទ្វារប្រាសាទ N1 រួចរាល់-ជួសជុលផ្នែកខាងកើតនៃប្រាសាទ N1 ព្រមទាំងធ្វើរបាំងការពារមិនឱ្យរថយន្តបើកឆ្លងកាត់កំពែងប្រាសាទយាយព័ន្ធ និងប្រាសាទតោ-ជួសជុលសរសេរផ្ចោបប្រាសាទ N1 ចំនួន០៦ស្រទាប់ឥដ្ឋ-ផ្គាមសិលាចរឹកនៅតំបន់ប្រាសាទសំបូរចំនួន០៩ផ្ទាំងគឺ N1, N4, N5, N20/21, N25, S6, K6/2 និង កាត់ស្មៅដែលដុះនៅលើប្រាសាទចំនួន១០ប្រាសាទ។ ចុះពិនិត្យថ្មធម្មជាតិបានប្រេះស្រាំលើព្រះបដិមា ស្ថិតនៅភ្នំសន្ទុក និងចុះជាមួយមន្ត្រីរាជបណ្ឌិតសភា ពិនិត្យសិក្សាទូលសន្លុងកន្ទប នៅឃុំសាលាវិស័យ ក្នុងស្រុកប្រាសាទបល្ល័ង្ក ដើម្បីសុំគោលការណ៍ទប់ស្កាត់ និងអភិរក្សទូលនេះ។ ត្រួសត្រាយយកល្បាស់ព្រៃចេញ សម្រាប់ដាំកូនឈើអនុស្សាវរីយ៍បានទំហំ៥.០០០ម៉ែត្រការ៉េនៅប្រាសាទសំបូរព្រៃគុក និងចាក់ដីចំនួន៧ឡានតាមផ្លូវចូលទៅប្រាសាទនានាក្នុងតំបន់ប្រាសាទសំបូរព្រៃគុក។ បានយកល្បាស់ព្រៃចេញពីមុខអភិរក្សដ្ឋានដល់ស្ពានអូរគ្រួកែ និងបានយាមល្បាតតាមប្រាសាទជាប្រចាំ។ ទទួលវត្ថុបុរាណចំនួន០១ដុំ "ថ្មគោលព្រះពុទ្ធសាសនា" ពីវរៈសេនាតូចលេខ១នៃតំបន់សឹករងកំពង់ធំ ដើម្បីយកមករក្សាទុកនៅសារមន្ទីរខេត្ត។ ភ្ញៀវចូលទស្សនាសារមន្ទីរសរុបចំនួន៣១៧នាក់ (អន្តរជាតិចំនួន១៣៧នាក់) រមណីយដ្ឋានភ្នំសន្ទុកចំនួន១៣.១០៩នាក់ (អន្តរជាតិចំនួន៩៨៩នាក់) ប្រាសាទអណ្តែតចំនួន៣៥៤នាក់ (អន្តរជាតិចំនួន១៥២នាក់) វត្តប្រាសាទ (ស្រុកសន្ទុក) ចំនួន២៣២នាក់ (អន្តរជាតិចំនួន៨២នាក់) និងប្រាសាទសំបូរព្រៃគុកចំនួន១៤.១២៤នាក់ (អន្តរជាតិចំនួន៥.៤៧២នាក់)។

ការងារបេតិកភណ្ឌអរូបី ៖ បានហាត់ឡើងវិញល្ខោនបាសាក់០១រឿង-យីកេ០១រឿង និងបានបង្ហាត់ក្បាច់បាត និងរបាំដល់សិស្សថ្នាលរៀងរាល់ថ្ងៃអាទិត្យ។ បានស្រង់ព័ត៌មាន ស្តីពីល្បែងប្រជាប្រិយខ្មែរតាមបណ្តាក្រុង-ស្រុកចំនួន៦១ល្បែង ដើម្បីចងក្រងជាសៀវភៅ និងចុះស្រាវជ្រាវភាសាជនជាតិដើមភាគតិច (គួយ) បានចំនួន៣៣២ពាក្យ នៅប្រាសាទបល្ល័ង្ក។

មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពង់ចាម ៖

ការងារបេតិកភណ្ឌរូបី ៖ បានចុះត្រួតពិនិត្យទូលមួយកន្លែង នៅស្រុកកំពង់ចាម ដើម្បីចុះបញ្ជីជាទូលបុរាណ និងត្រួតពិនិត្យកាំភ្លើងបុរាណចំនួនពីរដើម នៅស្រុកមេមត់។ បានទប់ស្កាត់សំណង់អត់ច្បាប់ក្នុងតំបន់ប្រាសាទនគរបាជ័យចំនួន០៥លើក និងបោសសម្អាតទីធ្លាប្រាសាទបានចំនួន១៩លើក។ បានសហការជាមួយរដ្ឋអំណាចស្រុកមេមត់ធ្វើកំណត់ត្រាអំពីវត្ថុបុរាណដែលរក្សាទុកនៅវត្តដូនវ័ត្ន។
បានស្រាវជ្រាវរកឃើញទូលប្រាសាទនៅមានទម្រង់ចំនួន០២កន្លែង នៅស្រុកអូរាំងឪ ដែលកសាងអំពីថ្មបាយក្រៀម និងភ្លោងទ្វារកសាងអំពីអំពីថ្មភក់។ បានត្រួតពិនិត្យការចូលមកគង់នៅរបស់ព្រះសង្ឃ និងការជួសជុលដំបូលវិហារនៅក្នុងកំពែងទី២ នៃប្រាសាទនគរបាជ័យ។ បានបោះបង្គោលទប់ស្កាត់មិនឱ្យរថយន្តចូល និងធ្វើស្លាកសញ្ញាចំនួន០៣ផ្ទាំង ហាមមិនឲ្យសាងសង់សំណង់ផ្សេងៗ និងបពាះសពកងតំបន់ប្រាសាទនគរបាជ័យ។ បានត្រួត

ពិនិត្យស្ថានភាពវិហារ និងរូបគំនូរបុរាណនៅវត្តមហាលាភ ក្នុងស្រុកកោះសូទិន និងបានបញ្ឈប់ការសាងសង់សំណង់ឥតច្បាប់ក្នុងបរិវេណប្រាសាទទឹកឆា។ បានចូលរួមជួសជុលនិងទល់ទ្រក្លោងទ្វារចូលប្រាសាទនគរបាជ័យ ជាមួយអ្នកជំនាញរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងពិនិត្យសំណង់លូទឹកឆ្លងកាត់ផ្លូវ ព្រមទាំង ចូលរួមដាំកូនឈើក្នុងតំបន់ប្រាសាទនេះផងដែរ។ បានទទួលវត្ថុបុរាណចំនួន០១ដុំគឺ "លិង្គព្រះឥសូរ" ពី ការិយាល័យវប្បធម៌ និងវិចិត្រសិល្បៈស្រុកព្រៃឈរ ។

ការងារបេតិកភណ្ឌអរូបី ៖ បានបើកមហោស្រពចម្រៀងបុរាណ-សម័យ-ល្ខោននាដកម្ម-ល្ខោនកំប្លែង-អាយ៉ៃរឿង-ភ្លេងប្រពៃណី-ភ្លេងសម័យ ទទួលលទ្ធជោគជ័យ។ បានហ្វឹកហាត់សិល្បករ សិល្បការិនី ដែលមាន អាយុចាប់ពី១៦ឆ្នាំ ដល់២៥ឆ្នាំ ដើម្បីធ្វើការបណ្តុះបណ្តាលបន្តវេន និងបានផ្តល់ច្បាប់អាជីវកម្ម សេវាកម្មវប្បធម៌ដល់ក្រុមសិល្បៈមហាជនចំនួន៦៧ក្រុម។ បានត្រួតពិនិត្យអាជីវកម្មជួល-លក់ស៊ីឌី វីស៊ីឌីដែលគ្មានទិដ្ឋាការចំនួន០២លើកនៅស្រុកអូរាំងឪ។ បានស្រង់ស្ថិតិសិល្បៈសូនរូប និងសិល្បៈសិប្បកម្មបានចំនួន១៣ ស្រុកនៅទូទាំងខេត្ត។ បានផ្សព្វផ្សាយ និងជម្រុញឱ្យអាជីវករចូលរួមធ្វើច្បាប់លើកស្លាកសញ្ញា ផ្ទាំងផ្សាយ ពាណិជ្ជកម្ម និងស្លាកសញ្ញាផ្សេងៗ។

មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តក្រចេះ ៖

ការងារបេតិកភណ្ឌរូបី ៖ បានថែរក្សា និងសម្អាតជាប្រចាំនូវវត្ថុបុរាណនៅក្នុងសារមន្ទីរ និងរៀបចំទៅតាមលក្ខណៈបច្ចេកទេស។ ចុះពិនិត្យ និងពង្រឹងសហគមអភិរក្ស និងអភិវឌ្ឍទីទួលប្រាសាទ ឱ្យជួយថែរក្សាជាប្រចាំនូវព្រៃធម្មជាតិនៅតាមទីទួលប្រាសាទនានាដែលបានបោះបង្គោលការពារកន្លងមក កុំឱ្យមានការបាត់បង់ពីពួកកាប់ទន្ទ្រានយកដី។ ទទួលនិស្សិតមកពីសកលវិទ្យាល័យន័រតុន ចំនួន២០៥នាក់ មកធ្វើកម្មសិក្សានៅសារមន្ទីរខេត្ត និងភ្ញៀវមកទស្សនាវិហារបុរាណ នៅភូមិរកាកណ្តាល សរុបចំនួន១.០៦៨នាក់ ក្នុងនោះអន្តរជាតិចំនួន៥៤៨នាក់។ បានចូលរួមជាមួយក្រុមស្រាវជ្រាវនៅរាជបណ្ឌិតសភា ធ្វើការសិក្សាស្រាវជ្រាវផ្ទាំងសិលានៅក្នុងសារមន្ទីរ និងនៅវិហារសសរ១០០។

ការងារបេតិកភណ្ឌអរូបី ៖ បានរៀបចំពិធីប្រារព្ធទិវាវប្បធម៌ជាតិ ០៣ មីនា លើកទី១៥ ឆ្នាំ២០១៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម ឃឹម សារិទ្ធ រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។ បានចុះបង្ហាត់សិល្បៈមហាជននៅឃុំថ្មគ្រែ សម្រាប់សម្តែងក្នុងពិធីបុណ្យចូលឆ្នាំថ្មី។ ចុះពិនិត្យកន្លែងធ្វើអាជីវកម្មបញ្ចាំងវីដេអូលក់កាហ្វេបានចំនួន៣៨លើកនៅទូទាំងខេត្ត។ បានផ្សព្វផ្សាយក្បាច់ខ្មែរនៅសិប្បកម្មអំពីឈើចំនួន០៥កន្លែង ចម្លាក់ពុម្ពស៊ីម៉ងចំនួន០២កន្លែង នៅសង្កាត់ក្រចេះ។ បានណែនាំ និងជម្រុញអាជីវករអ៊ុតសក់ កាត់សក់ សម្អាងការ បណ្ណាគារដែលមិនទាន់មានច្បាប់អនុញ្ញាតធ្វើអាជីវកម្ម ឱ្យមកសុំច្បាប់អនុញ្ញាតប្រកប របរអាជីវកម្មរបស់ខ្លួនតាមការណែនាំរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដើម្បីទទួលបាននូវការគ្រប់គ្រង ល្អ និងបង់ចំណូលចូលរដ្ឋ។ ការិយាល័យច្រកចេញចូលតែមួយ បានចេញលិខិតអនុញ្ញាតប្រកបអាជីវកម្ម វិស័យវប្បធម៌ និងវិចិត្រសិល្បៈបានចំនួន២២ច្បាប់ ទទួលថវិកាបង់ចូលរដ្ឋសរុបចំនួន២.៨១១.០០០រៀល ។

មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តស្ទឹងត្រែង ៖

ការងារបេតិកភណ្ឌរូបី ៖ បានចុះទៅត្រួតពិនិត្យវត្ថុបុរាណដែលបានរក្សាទុកក្នុងសាលាស្រុកថាឡាបរិវ៉ាត់ និងតាមទីទួលនានា និងការជីកស្តារស្រះបុរាណនៅបរិវេណតំបន់ប្រតិបត្តិការសឹករងខេត្ត។ ចុះទៅស្រុកថាឡាបរិវ៉ាត់ចំនួន០៣លើក ដើម្បីរៀបចំធ្វើពិធីជីករំកិលផ្ទាំងថ្មគូថគាព្រហ្ម ដែលស្ថិតនៅចំកណ្តាលផ្សែយកទៅទុកនៅកន្លែងថ្មី តែពំទាន់បានសម្រេច ព្រោះពំមានគ្រឿងចក្រធំដែលអាចសែយកទៅដល់ទីតាំង

ថ្មី។ បានត្រួតពិនិត្យ និងទទួលព្រះពុទ្ធរូបចំនួន៦៦អង្គ និងវត្ថុបុរាណចំនួន០២ដុំ មករក្សាទុកក្នុងសារមន្ទីរខេត្ត។ បានជូនក្រុមបុរាណវិទ្យាមកពីអភិរក្សដ្ឋានអង្គរចំនួន០៣នាក់ ពិនិត្យមើលផ្នាំងថ្មគូថតាព្រហ្ម នៅស្រុកថាឡាបរិវ៉ាត់។ បានពិនិត្យកន្លែងដែលប្រជាពលរដ្ឋបានជញ្ជូនដុំឥដ្ឋចេញពីទួលប្រាសាទ៨ល្វែង ហើយបានរាយការណ៍ជូនអាជ្ញាធរស្រុក ដើម្បីជួយអន្តរាគមន៍ទប់ស្កាត់រាល់ការជីកបំផ្លាញទួលប្រាសាទដែលមាននៅក្នុងស្រុកថាឡាបរិវ៉ាត់។

ការងារបេតិកភណ្ឌអរូបី ៖ បានសហការជាមួយអង្គការភូមិខ្ញុំចុះទៅឃុំក្បាលរមាស ដើម្បីបង្ហាត់របាំរបស់ជនជាតិដើមភាគតិចគ្រឹង។ បានចុះណែនាំដល់អាជីវករដែលប្រកបអាជីវកម្មសេវាកម្មវប្បធម៌ទាំងអស់ឱ្យមកដាក់ពាក្យសុំធ្វើអាជីវកម្មប្រចាំឆ្នាំនៅច្រកចេញចូលតែមួយ។ ចុះណែនាំដល់អាជីវករដែលប្រកបអាជីវកម្ម លក់ស៊ីឌី-វីស៊ីឌីចំនួន០២កន្លែងឱ្យយកស៊ីឌី-វីស៊ីឌីមកចុះបញ្ជីនៅការិយាល័យជំនាញស្ថិតនៅក្រុងស្ទឹងត្រែង ។ ចុះត្រួតពិនិត្យស្លាកសញ្ញាចំនួន២០កន្លែង នៅក្រុងស្ទឹងត្រែង។ ការិយាល័យច្រកចេញចូលតែមួយ បានចេញអាជ្ញាប័ណ្ណចំនួន៤១ច្បាប់ជូនដល់អាជីវករ។

មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តរតនគីរី ៖

ការងារបេតិកភណ្ឌរូបី ៖ បានចុះត្រួតពិនិត្យនៅតំបន់ការពារគ្រឹះប្រាសាទព្រះពុទ្ធដែលក្រុមហ៊ុនម៉ាងយ៉ាងបានឈូសឆាយដីចូលចំនួន០១លើក និងពិនិត្យឃើញថាមានជនល្មើសលួចចូលកាប់ឈើនៅតំបន់គ្រឹះប្រាសាទព្រះពុទ្ធនេះនៅពេលយប់។ ជូនក្រុមការងារអង្គការក្រៅរដ្ឋាភិបាល ចុះផ្តិតរូបថតនៅប្រាសាទតាក់ណាំង គ្រឹះប្រាសាទព្រះពុទ្ធ និងមជ្ឈមណ្ឌលវប្បធម៌ ដើម្បីផ្សព្វផ្សាយតាមប្រព័ន្ធទំនើប Internet។

ការងារបេតិកភណ្ឌអរូបី ៖ បានចុះត្រួតពិនិត្យតាមហាងបញ្ចាំងវីដេអូ-កន្លែងលក់ស៊ីឌី វីស៊ីឌីចំនួន១៣លើក។ ចុះត្រួតពិនិត្យ និងហ្វឹកហាត់ដល់ក្រុមសិល្បៈមហាជនចំនួន២០លើក និងដឹកនាំក្រុមសិល្បៈមហាជនទៅសម្តែងនៅប្រទេសវៀតណាមចំនួន០១លើក។ ចុះត្រួតពិនិត្យសិប្បកម្មគ្រប់ប្រភេទនៅស្រុកអូរយ៉ាដាវ-ស្រុកវ៉ឺនសៃ-ស្រុកលំផាត់-ស្រុកកូនមុំ និងក្រុងបានលុង ឲ្យគោរពតាមក្បាច់ និងរចនាបថខ្មែរបានចំនួន១១លើក។ បានសិក្សាស្រាវជ្រាវល្បែងប្រជាប្រិយមួយគឺ ល្បែងហូតឈើ ដើម្បីធ្វើឯកសារផ្ញើជូនក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងចុះទៅស្រុកបរកែវ ដើម្បីស្រាវជ្រាវប្រវត្តិសង្ខេបមរតកមនុស្សរស់នៅទីនោះ។

មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តមណ្ឌលគីរី ៖

ការងារបេតិកភណ្ឌរូបី ៖ បានចុះត្រួតពិនិត្យទីតាំងកំពូលភ្នំដោះក្រមុំ ដើម្បីឱ្យសប្បុរសជនសាងសង់សាលាសំណាក់មួយខ្នងបន្ថែមទៀត បានពន្លត់ភ្លើងឆេះព្រៃក្បែរទីអាស្រមនៃមជ្ឈមណ្ឌលវប្បធម៌ជនជាតិភ្នំដោះក្រមុំ និងចាត់មន្ត្រីនៅប្រចាំការលើភ្នំធ្វើការថែរក្សា សម្អាតអនាម័យ និងដោះស្រាយឱ្យមានទឹកគ្រប់គ្រាន់ សម្រាប់ភ្ញៀវទេសចរណ៍។ បានចាក់សាបនៅខាងឆ្វេងរោងអ្នកតាស្រុះបានចំនួន១៦ម៉ែត្រការ៉ែ។ បានសហការជាមួយមន្ត្រីខណ្ឌរដ្ឋបាលព្រៃឈើ ចុះវាស់វែងដីដែលជាមជ្ឈមណ្ឌលភ្នំដោះក្រមុំមួយកន្លែង នៅបរិវេណភ្នំលោកយាយផ្លុំ សម្រាប់ទុកជាដីដាំកូនឈើអនុស្សាវរីយ៍ប្រមាណជា០៨ហិចតា។

ការងារបេតិកភណ្ឌអរូបី ៖ បានរៀបចំពិធីប្រារព្ធទិវាវប្បធម៌ជាតិ ០៣ មីនា លើកទី១៥ និង បើកមហោស្រពសិល្បៈមហាជន ឆ្នាំ២០១៣ ក្រោមអធិបតីភាព ឯកឧត្តម សំរាំង កំសាន្ត រដ្ឋលេខាធិការ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។ ចុះទៅបង្ហាត់បង្រៀនរបាំដល់សិស្សមណ្ឌលចំការតែ ក្រុមរបាំសហគមន៍ពូតាំង បុគ្គលិកធនាគារអេស៊ីលីដាខេត្ត ព្រមទាំងបង្ហាត់ក្មេងៗនៅក្នុងវត្តសែនមនោរម្យឱ្យចេះប្រគុំភ្លេងឆៃយ៉ាំ។ បានចុះជួយកែលម្អរបាំចំនួន០៣របាំ ដល់ក្រុមសិល្បៈកមារកំព្រា នៅមណ្ឌលបរិអេសសេកាខេត្ត។ បានហាត់រៀនភ្លេង

ពិណពាទ្យ-មហោរី-ភ្លេងប្រពៃណី និងរបាំសម្រេចជាស្តាពរ។ ចុះត្រួតពិនិត្យកន្លែងលក់ស៊ីឌី-វីស៊ីឌីខុសច្បាប់ចំនួន០៦កន្លែង ដកហូតថាសខុសច្បាប់ចំនួន២.២៣៤បន្ទះ ដោយសហការជាមួយនគរបាលក្រុងសែនមនោរម្យ។ រៀបចំតម្លើងឧបករណ៍ភ្លេងបែបជនជាតិឆ្នៃប្រឌិតបាន០២គ្រឿងធ្វើអំពីដើមឬស្សី។ ចុះសិក្សាស្រាវជ្រាវ ចងក្រងឯកសារអំពីប្រភេទសម្លៀកបំពាក់ប្រពៃណីរបស់បងប្អូនជនជាតិព្នងបានចំនួន២៨មុខ និងបានធ្វើកិច្ចសម្ភាស ស្តីពីប្រវត្តិដាំដើមរកការបស់បងប្អូនជនជាតិដើមភាគតិច។ ចុះស្រង់ស្ថិតិវប្បធម៌នៅតាមបណ្តាឃុំ-ស្រុកនៅក្នុងខេត្ត។ បានចូលរួមតាំងពិព័រណ៌ ស្តីពីការរីកចម្រើនវិស័យវប្បធម៌ខ្មែរ នៅខេត្តដាកណុង ប្រទេសវៀតណាម។ ការិយាល័យច្រកចេញចូលតែមួយ ក្រុងសែនមនោរម្យ បានចេញលិខិតអនុញ្ញាតច្បាប់អាជីវកម្មលើវិស័យវប្បធម៌សរុបចំនួន២២ច្បាប់ ។

មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តព្រៃវែង ៖

ការងារបេតិកភណ្ឌរូបី ៖ បានបន្តការស្រាវជ្រាវរកបេតិកភណ្ឌគ្រប់ប្រភេទនៅតាមបណ្តាស្រុក-ក្រុងទូទាំងខេត្ត។ បានបន្តរៀបចំកន្លែងដាក់បង់ថ្មសម្រាប់ភ្ញៀវអង្គុយលេងនៅទីទួលបូជនីយដ្ឋានទួលបារាយអណ្តែតចំនួន៧១បង់ ជាអំណោយឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្ត និងសប្បុរសជន។ ចាក់ដីបន្ថែមចំនួន៨៧រថយន្ត នៅទីទួលបារាយអណ្តែត និងធ្វើរបងរបាំងការពារទឹកជំនន់ប្រវែង១៨ម៉ែត្រ ដែលជាអំណោយសប្បុរសជនក្នុងខេត្ត។ កសាងផ្លូវចាក់បេតុងប្រវែង៦៥ម៉ែត្រ ទទឹង០២ម៉ែត្រ ខាងជើងបរិវេណទីទួលបារាយអណ្តែត ដែលជាអំណោយពីសប្បុរសជន។ ដាក់ស្លាកសញ្ញាឈ្មោះដើមឈើចំនួន៧៨ស្លាក នៅទីទួលបារាយអណ្តែត។ បានស្តារ និងជីកស្រះបន្ថែមចំនួន០២កន្លែង នៅប្រាសាទព្រៃដើមស្រុកស្រុកស៊ីធរកណ្តាល ដែលជាអំណោយពីសប្បុរសជន។ ភ្ញៀវជាតិ-អន្តរជាតិចូលទស្សនាសារមន្ទីរខេត្តសរុបចំនួន១៧៥នាក់ និងទួលបារាយអណ្តែតសរុបមានចំនួន១.៨៤២នាក់។
សាងសង់របងសារមន្ទីរប្រវែង៥៧ម៉ែត្រ-ជួសជុលពិដានសារមន្ទីរ
និងរៀបចំវត្តុបុរាណនៅសាលពិព័រណ៌ចំនួន០៣លើក។

ការងារបេតិកភណ្ឌអរូបី ៖ បានយកក្រុមអាយ៉ៃរឿង និងចាប៉ីដងវែងទៅចូលរួមមហោស្រពសិល្បៈមហាជនថ្នាក់ភូមិភាគ នៅខេត្តកំពង់ចាម។ បានបង្ហាត់របាំជូនពរដល់សិស្សមណ្ឌលកុមារកំព្រាខេត្ត និងសិស្សវិទ្យាល័យព្រះអង្គឌួងជារៀងរាល់ខែ។
ចុះពង្រឹងគុណភាពក្រុមសិល្បៈមហាជនល្ខោនបាសាក់នៅស្រុកបាភ្នំ ស្រុកព្រះស្តេច និងស្រុកកញ្ជ្រៀច និងពង្រឹងក្រុមរបាំសិស្សវិទ្យាល័យបាភ្នំ។ ចុះពិនិត្យអាជីវកម្មវីដេអូលក់កាហ្វេនៅក្រុងព្រៃវែង និងស្រុកនានាចំនួន០៦លើក និងចុះពិនិត្យសិប្បកម្មពុម្ពស៊ីម៉ង់ត៍គ្រប់ប្រភេទតាមបណ្តាស្រុក-ក្រុង ដើម្បីឱ្យអាជីវករជួយរក្សាក្បាច់ចម្លាក់ខ្មែរឱ្យបានគង់វង្ស។ ពិនិត្យស្លាកយីហោគ្រប់ប្រភេទនៅស្រុកកំពង់លាវ ស្រុកពាមរក៍ ស្រុកកំពង់ត្របែក និងក្រុងព្រៃវែងចំនួន០៣លើក និងចុះពិនិត្យកន្លែងបង្កើតភូមិវប្បធម៌នៅស្រុកបាភ្នំចំនួន០១លើក ។

មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តស្វាយរៀង ៖

ការងារបេតិកភណ្ឌរូបី ៖ បានចុះផ្សព្វផ្សាយច្បាប់ ស្តីពីការការពារសម្បត្តិបេតិកភណ្ឌវប្បធម៌ជាតិដល់ប្រជាពលរដ្ឋចំនួន១៣លើក និងសហការជាមួយគណៈកម្មាធិការវាស់វែងដីធ្លីជាលក្ខណៈប្រព័ន្ធដើម្បីចុះបញ្ជីទួលបុរាណបានចំនួន១៧ប្លង់នៅស្រុកស្វាយជ្រំ។ លើកស្លាកសញ្ញាសម្គាល់ប្រាសាទបុរាណ និងទួលបុរាណបានចំនួន០៧ស្លាកសញ្ញា។ ចុះស្រាវជ្រាវវត្តុបុរាណ និងចងក្រងប្រវត្តិផ្សេងៗចំនួន០៣លើក និងទទួលវត្តុបុរាណជាព្រះពុទ្ធរូបចំនួន០១ព្រះអង្គ ពីឃុំចន្ទី ស្រែករមាសហែក យកមករក្សាទុកនៅសារមន្ទីរខេត្ត។ ចុះ

សហការជម្រុញឱ្យឆ្មាំប្រាសាទព្រៃបាសាក់ធ្វើអនាម័យជុំវិញប្រាសាទ ថែរក្សាការពារប្រាសាទបុរាណ និងជួយ ជួសជុលស្លាកសញ្ញាសម្គាល់ប្រាសាទឱ្យបានល្អ។

ការងារបេតិកភណ្ឌអូរបី ៖ បានរៀបចំពិធីប្រារព្ធទិវាវប្បធម៌ជាតិ ០៣ មីនា លើកទី១៥ ឆ្នាំ២០១៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម ហ៊ឹម ឆែម រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ នៅសាលប្រជុំឆ្នេរទន្លេ។ ដឹកនាំក្រុមសិល្បករ សិល្បការិនី ទៅចូលរួមសម្តែងរបាំនៅប្រទេសវៀតណាមចំនួន០១លើក។ បាននិពន្ធតម្លើងអាយ៉ៃរឿងបាន០១រឿង ចូលរួមមហោស្រពសិល្បៈមហាជនភូមិភាគ នៅខេត្តកំពង់ចាម។ ចុះបង្ហាត់បង្រៀនរបាំដល់ក្រុមអង្គការ នៅឃុំពោធិតាហោ០១ក្រុម និងភូមិរោងបន្លែ០១ក្រុម-ដល់សមាគមន៍យុវជនខេត្ត-សាលាគរុកោសល្យខេត្ត និងបង្ហាត់បង្រៀនផ្នែកសម្អាងការ ជាត់មុខ និងធ្វើម៉ូតសក់នៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត (មន្ទីរការងារខេត្ត)។ ចុះត្រួតពិនិត្យការធ្វើអាជីវកម្មលើវិស័យភាពយន្ត-វីដេអូបានចំនួន៧៥លើក និងសហការជាមួយការិយាល័យវប្បធម៌ស្រុក អាជ្ញាធរដែនដីធ្វើការណែនាំដល់អាជីវកម្មភាពយន្ត-វីដេអូនៅទូទាំងខេត្តឱ្យអនុវត្តត្រឹមត្រូវតាមច្បាប់។ អនុញ្ញាតបើកអាជីវកម្មជួល-លក់ថាសចំនួន១៥ច្បាប់ និងដាក់ពាក្យសុំបើកថ្មី០៣កន្លែង។ ចុះត្រួតពិនិត្យសិប្បកម្មនៅតាមបណ្តាស្រុកបានចំនួន ០៧លើក និងចុះសហការជាមួយការិយាល័យវប្បធម៌ស្រុកស្វាយជ្រំ ស្រាវជ្រាវអ្នកចេះផលិតនូវផលិតផលអំពីណ្តាក់ ឬស្សី ផ្តៅ ដើម្បីបង្កើនមុខរបរ និងជួយពង្រឹងដល់ពូកគាត់ដើម្បីកុំឱ្យបាត់បង់នូវវត្ថុសិល្បៈទាំងនោះ។ ចុះធ្វើការត្រួតពិនិត្យការដាក់តាំងស្លាកយីហោ ផ្ទាំងផ្សាយពាណិជ្ជកម្មចំនួន៣១លើក និងបានចេញលិខិតអនុញ្ញាតលើកស្លាកសញ្ញា ស្លាកយីហោគ្រប់ប្រភេទចំនួន១២ផ្ទាំង ព្រមទាំងអញ្ជើញអាជីវករដែលធ្វើអាជីវកម្មពាក់ព័ន្ធនឹងវិស័យវប្បធម៌មកប្រជុំណែនាំឱ្យសុំច្បាប់បើកអាជីវកម្មចំនួន០៧លើក។

មន្ទីរាជធានី-ខេត្ត ដោយបានពិនិត្យជារួមឃើញថា បញ្ហាប្រឈម និងសំណូមពរគឺមាន ៖

១-ការងារបេតិកភណ្ឌរូបី ៖

***បញ្ហាប្រឈម ៖**

-បទល្មើសលួចវត្ថុបុរាណនៅតែកើតមានឡើង ជនមួយចំនួនបានបំពានយកដីទួលបុរាណ ដីជាគ្រឹះប្រាសាទ និងបានចាក់ដីលុបត្រពាំងបុរាណយកធ្វើកម្មសិទ្ធិរបស់ខ្លួន

-ការចុះបញ្ជី ការបោះបង្គោលកំណត់ព្រំដី និងការធ្វើប្លង់កម្មសិទ្ធិដីទួលបុរាណ ដីប្រាសាទ មិនទាន់អនុវត្តបានទាំងស្រុងនៅតាមខេត្ត

-ប្រាសាទមួយចំនួនទទួលរងការចាស់ទ្រុឌទ្រោម ប្រេះស្រាំ ខ្វះមធ្យោបាយជួសជុល

-ខ្វះមន្ត្រីជំនាញបម្រើការងារបេតិកភណ្ឌ ។

២-ការងារបេតិកភណ្ឌអូរបី ៖

***បញ្ហាប្រឈម ៖**

-សិល្បករមានវ័យកាន់តែចាស់ និងចូលនិវត្តន៍ ខ្វះអ្នកបន្តវេន

-មន្ទីរមួយចំនួនមានក្រុមសិល្បៈអាជីព រាល់ការបម្រើសកម្មភាពពឹងផ្អែកលើសិល្បៈមហាជន

-ខ្វះការបណ្តុះបណ្តាល បំពាក់បំប៉នជំនាញសិល្បៈទស្សនីយភាពដល់ក្រុមសិល្បៈមហាជន

-ការចុះបញ្ជីបេតិកភណ្ឌអូរបីតាមទម្រង់ ០១-០២ តាមការណែនាំរបស់ក្រសួង គឺខេត្តមួយចំនួនមិនទាន់អនុវត្តបាន

-ខ្វះមន្ត្រីជំនាញចុះសិក្សាស្រាវជ្រាវពីវប្បធម៌ជនជាតិភាគតិច ក៏ដូចជាមន្ត្រីជំនាញបម្រើសកម្មភាពសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម ។

៣-សំណូមពរ ៖

-គ្រប់មន្ទីរ ស្នើសុំមន្ត្រីក្របខណ្ឌថ្មីបំពេញបន្ថែមនៅមន្ទីរថ្នាក់ក្រុង-ស្រុក និងសុំបន្ថែមមន្ត្រីកិច្ចសន្យា និងពលករអណ្តែត

-សុំជួសជុលសារមន្ទីរខេត្តកំពង់ឆ្នាំង និងបណ្ណាល័យខេត្តកំពង់ចាម

-ខេត្តកោះកុងស្នើសុំសារមន្ទីរមួយខ្នង និងឃ្លាំងមួយ សម្រាប់ដាក់បេតិកភណ្ឌក្រោមទឹក

-ស្នើសុំធ្វើផ្លូវចូលប្រាសាទព្រះពុទ្ធ និងតំបន់ប្រាសាទយក្ខណាំង នៅខេត្តរតនគីរី

-ស្នើក្រសួងជួយអន្តរាគមន៍ជាមួយសមត្ថកិច្ចគយតាមច្រកព្រំដែន និងនៅព្រលានយន្តហោះខេត្ត សៀមរាបឲ្យសហការបង្កើនការត្រួតពិនិត្យ និងទប់ស្កាត់វត្ថុសិល្បៈនាំចេញ ដែលគ្មានលិខិតអនុញ្ញាត

-សូមក្រសួងរៀបចំក្រុមការងារគ្រប់គ្រងព្រះសក្យមុនីចេតីយ នៅភ្នំព្រះរាជទ្រព្យ ខេត្តកណ្តាល ឲ្យបានឆាប់ ដើម្បីដំណើរការគ្រប់គ្រងបន្តទៀត

-សូមក្រសួងជម្រុញឲ្យមានលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យវប្បធម៌ឲ្យចេញបានឆាប់ សម្រាប់ជាមូលដ្ឋានអនុវត្តជំនាញនៅតាមខេត្ត

-រាល់លិខិតដែលមន្ទីរស្នើសុំជួយធ្វើអន្តរាគមន៍បន្ទាន់ (ពាក់ព័ន្ធការងារបេតិកភណ្ឌ) សូមក្រសួងធ្វើការឆ្លើយតបឲ្យបានឆាប់ ដើម្បីឲ្យមន្ទីរមានមូលដ្ឋានធ្វើការដោះស្រាយ ។

សេចក្តីសន្និដ្ឋាន ៖

សកម្មភាពការងាររយៈពេលមួយឆ្នាំនេះ មានដំណើរការយ៉ាងសកម្ម ក្នុងកិច្ចថែរក្សាការពារលើកតម្កើង កេរតំណែលសម្បត្តិបេតិកភណ្ឌរូបី-អរូបី និងអភិវឌ្ឍសកម្មភាពវប្បធម៌គ្រប់ជំនាញនៅតាមមូលដ្ឋាន។ យើងបានបង្កើនការផ្សព្វផ្សាយអំពីសក្តានុពលវប្បធម៌ជាតិ ពង្រឹងការផ្តល់សេវាកម្មបម្រើសេវាកម្មពាក់ព័ន្ធវិស័យវប្បធម៌ និងបានជម្រុញបង្កើតផលិតកម្មសិប្បកម្មវប្បធម៌ដោយប្រជាពលរដ្ឋបានខិតខំបង្កើតស្នាដៃធានាគុណភាព និងរក្សាខ្នាតនូវផលិតផលវប្បធម៌ដើម្បីបម្រើគោលដៅពាណិជ្ជកម្ម និងទេសចរណ៍ ព្រមទាំងទទួលបានផលជួយសម្រួលដល់ជីវភាពរស់នៅបានមួយកម្រិត និងបានចូលរួមអភិវឌ្ឍសេដ្ឋកិច្ចជាតិ ស្របតាមការរីកចម្រើនរបស់សង្គមជាតិ។ លទ្ធផលសកម្មភាពការងារដែលសម្រេចបានមកនេះ អាស្រ័យដោយកិច្ចខិតខំប្រឹងប្រែងយកអស់កម្លាំងកាយ កម្លាំងបញ្ញា ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់របស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ទាំងថ្នាក់កណ្តាល និងថ្នាក់រាជធានី-ខេត្ត។

យោងតាមការធ្វើតុល្យការ នៃការងារវប្បធម៌ ក្នុងរយៈពេលមួយឆ្នាំនេះ ឃើញថា ការអនុវត្តផែនការអាទិភាព និងផែនការសកម្មភាពការងារ ឆ្នាំ២០១៣ ៖

•ថ្នាក់កណ្តាល មានផែនការសកម្មភាពចំនួន**១៨៧សកម្មភាព** អនុវត្តបាន**១០២សកម្មភាព** ស្មើ**៥៤,៥៤ភាគរយ** ក្នុងនោះអង្គភាពសម្រេចបានលើផែនការអាទិភាពដូចតទៅ ៖

***ផែនការអាទិភាពទី១ ៖** ជម្រុញឱ្យកម្ពុជា ក្លាយជាមជ្ឈមណ្ឌលផ្សព្វផ្សាយសិល្បៈទស្សនីយភាព

-មានចំនួន**០៩**សកម្មភាព អនុវត្តបាន**០៥**សកម្មភាព ស្មើ**៥៥,៥៥ភាគរយ**

***ផែនការអាទិភាពទី២ ៖** ប្រែក្លាយកម្ពុជា ជាដែនដីស្វាគមន៍នៃការថតខ្សែភាពយន្ត

-មានចំនួន**១១សកម្មភាព** អនុវត្តបាន**០៨សកម្មភាព** ស្មើ**៧២,៧២ភាគរយ**

***ផែនការអាទិភាពទី៣ ៖** ជម្រុញឱ្យកម្ពុជា ក្លាយជាទីកន្លែងផ្សព្វផ្សាយផលិតផលវប្បធម៌

-មានចំនួន**៣៣**សកម្មភាព អនុវត្តបាន**១៣**សកម្មភាព ស្មើ**៣៩,៣៩ភាគរយ**

***ផែនការអាទិភាពទី៤ ៖** ថែរក្សា ការពារ អភិវឌ្ឍតំបន់បេតិកភណ្ឌវប្បធម៌ ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចជាតិ

-មានចំនួន**៣០**សកម្មភាព អនុវត្តបាន**១៣**សកម្មភាព ស្មើ**៤៣,៣៣ភាគរយ**

***ផែនការអាទិភាពទី៥ ៖** ពង្រឹង ពង្រីកសមត្ថភាពស្ថាប័ន ភាពជាដៃគូអភិវឌ្ឍ ដើម្បីបង្កើនប្រសិទ្ធភាព ការងារ និង សេវា

-មានចំនួន**១០៤**សកម្មភាព អនុវត្តបាន**៦៤**សកម្មភាព ស្មើ**៦១,៥៣ភាគរយ** ។

•ថ្នាក់រាជធានី-ខេត្ត មានផែនការសកម្មភាពសរុបចំនួន**៣៧៧**សកម្មភាព អនុវត្តបាន**២៤៥**សកម្មភាព ស្មើ**៦៤,៩៨ភាគរយ** ។

ទន្ទឹមនឹងសកម្មភាពការងារសម្រេចបាន និងការងារសម្រេចមិនបាន ដែលបានលើកឡើងខាងលើនេះ យើងក៏ពិនិត្យឃើញថា គ្រប់អង្គភាព ជារួមមានបញ្ហាប្រឈមប្រហាក់ប្រហែលគ្នាគឺ ៖

-ធនធានមនុស្ស មិនទាន់ឆ្លើយតបទៅនឹងទំហំការងារ

-លទ្ធភាពផ្តល់ថវិកាដល់អង្គភាព ពុំទាន់ធានាដល់កិច្ចអនុវត្តគម្រោងផែនការ

-សមត្ថភាព និងបទពិសោធន៍របស់មន្ត្រីរាជការនៅមានកម្រិត

-ការបណ្តុះបណ្តាល បំពាក់បំប៉នជំនាញ ពុំទាន់ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង

-គ្មានសង្គតិភាពរវាងអង្គភាពកសាងផែនការសកម្មភាព ជាមួយអង្គភាពកសាងផែនការថវិកា

-កង្វះមធ្យោបាយក្នុងការចុះស្រាវជ្រាវ រុករកបេតិកភណ្ឌ និងធ្វើសកម្មភាពវប្បធម៌ នៅតាមតំបន់ដាច់ស្រយាល

-បរិយាកាសមិនអំណោយផលដល់ការបំពេញភារកិច្ច "ខេត្តមួយចំនួនទទួលរងគ្រោះទឹកជំនន់" ។

សកម្មភាពការងារដែលនៅសេសសល់អនុវត្តមិនទាន់បានសម្រេចនៅឆ្នាំ២០១៣នេះ គ្រប់អង្គភាពនឹងបន្តអនុវត្តក្នុងផែនការប្រចាំឆ្នាំ២០១៤ទៀត ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ ។

សូម **ឯកឧត្តម** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

រដ្ឋមន្ត្រី

ចម្លងជូន ៖

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-គណៈកម្មការអប់រំ ធម្មការ វប្បធម៌ ទេសចរណ៍ ព្រឹទ្ធសភា

-គណៈកម្មការទី ៧ រដ្ឋសភា

-ទីស្តីការគណៈរដ្ឋមន្ត្រី (នាយកដ្ឋានសរុប)

-ក្រសួងផែនការ (វិទ្យាស្ថានជាតិស្ថិតិ)

-ក្រុមសង្កេតការសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ទីស្តីការគណៈរដ្ឋមន្ត្រី)

-ឯកសារ-កាលប្បវត្តិ